OLD VERSION

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Mar-2016, 13:53
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី៣៧៥**

ចៅក្រមសាលាដំបូង៖

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

ក្រឡាបញ្ជីសាលាដំបូង៖

កញ្ញា ជា ស៊ីវហ័ង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក សេង លាង

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

ជនជាប់ចោទ៖

លោក នួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ នួន ជា៖

លោក សុន អរុណ

លោក លីវ សុវណ្ណា

មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោក សំ សុគង់

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង លាង | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡេា ជុនធី | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី សៀង ចាន់ថី (2-TCCP-1015) | ខ្មែរ |
| លោកស្រី ខូង មួយ (2-TCCP-259) | ខ្មែរ |
| លោក អ៊ុច ស៊ុនឡាយ (2-TCCP-1014) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោកស្រី សៀង ចាន់ធី** (2-TCCP-1015)

សួរបន្តដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៣
សួរដោយលោក សេង លាង ផ្តើមពី ........ ទំព័រ ៩
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........ ទំព័រ ១៧

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោកស្រី ខុន មួយ** (2-TCCP-259)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣០
សួរដោយលោក ឡោ ជុនធី ផ្តើមពី ........ ទំព័រ ៣២
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី ........ ទំព័រ ៣៩
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........ ទំព័រ ៥២

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោក អ៊ុច ស៊ុនឡាយ** (2-TCCP-1014)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៦២
សួរដោយលោក វ៉ែន ពៅ ផ្តើមពី ........ ទំព័រ ៦៣
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី ........ ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី បន្តបញ្ចប់ ហើយនិងស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1014 ហើយក៏មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុង 2-TCCP-259។

ក្រឡាបញ្ជីសវនាការលោកស្រី ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នេះរឿងក្តីនេះ មានវត្តមាន លើកលែងតែលោកស្រី អង់តា ហ្គីសសេ មេធាវីការពារក្តីឲ្យលោក ខៀវ សំផន បានជូនដំណឹងមកថា នឹងអវត្តមានដោយធុរៈផ្ទាល់ខ្លួន ពីថ្ងៃនេះដល់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ហើយនិងលោក វ៉ិចទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា អវត្តមាននៅថ្ងៃនេះដោយមិនមានមូលហេតុ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មបន្តនៅថ្ងៃនេះ គឺលោកស្រី សៀង ចាន់ថី បន្ទាប់មកគឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1014។ ហើយនៅថ្ងៃនេះផងដែរ មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបទៀតដែលមានរហស្សនាម 2-TCCP-259។ នៅក្នុងអំឡុងពេលនៃការថ្លែងទុក្ខសោកនេះ មានបុគ្គលិកអង្គការ ធី.ភី.អូ គឺលោក ឆាយ ម៉ារីដេត ដែលអង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលិក អង្គការ ធី.ភី.អូ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៧:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់ អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈ ឈឺខ្នង់ ឈឺចង្កេះ ធឹងធោងពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន ៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៩:១១]

លោកស្រី សៀង ចាន់ថី យើងបានទទួលព័ត៌មានថា លោកស្រីតែងតែមានការត្រូវទៅបន្ទប់ទឹកជាញឹកញាប់ ដូច្នេះសូមស្រីកុំអលអែកអី ប្រសិនបើលោកស្រីត្រូវការនោះ លោកស្រីគ្រាន់តែជាលើកដៃទៅ ហើយមិនបាច់សុំទេ គ្រាន់តែជាសញ្ញាថា លើកដៃទៅ យើងនឹងអនុញ្ញាតឲ្យលោកស្រីអាចទៅបន្ទប់ទឹកនៅក្នុងអំឡុងពេលដែលពាក់កណ្តាលទីនៃកិច្ចដំណើរការសវនាការបាន។ នេះជារឿងចាំបាច់នៃមនុស្សគ្រប់រូបដែលតម្រូវការ ស្ថានភាពបែបនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី -- ក្រុមមេធាវី

នាំតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិបន្តការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ កាលពីម្សិលមិញ លោកស្រីបាននិយាយអំពីការរំលោភនារីពីរនាក់ដែលមានដើមកំណើតជាជនជាតិវៀតណាម ដែលឪពុករបស់លោកស្រីបានឃើញដោយផ្ទាល់ភ្នែក។ អ៊ីចឹងខ្ញុំសូមឲ្យលោកស្រីរៀបរាប់ឲ្យបានលម្អិតបន្តិចទាក់ទងនឹងព្រឹត្តិការណ៍នេះ ហើយតើនារីនោះជាអ្នកណាដែរ ហើយការដែលហេតុការណ៍ដែលកើតឡើងនេះមានផលប៉ះពាល់យ៉ាងដូចម្តេចដែរទៅលើរូបលោកស្រី?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

[០៩:១០:៥០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយហេតុថា នេះមិនមែនជាអង្គហេតុដែលជាប់ពាក់ព័ន្ធផ្ទាល់ ដែលកើតចេញពីអំពើដែលនាំឲ្យមានការឈឺចាប់ដល់ជនរងគ្រោះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនោះទេ វាជាការបង្ហាញនូវអង្គហេតុទូទៅ ដែលលក្ខណៈពិសេសមួយទៀតនោះ គឺដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់មិនបានឃើញ ឬក៏ដឹងដោយផ្ទាល់ពីអង្គហេតុនេះទេ ដែលជាអង្គហេតុនៃការដឹងតៗគ្នាពីមាត់មួយទៅមាត់មួយផ្សេងទៀត។ ដូច្នេះខ្ញុំសូមជំទាស់ចំពោះសំណួរនេះបាទ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំឃើញថាវាមានភាពពាក់ព័ន្ធសួរសំណួរនេះ ថាដើម្បីឲ្យដឹងថាតើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះប៉ះទង្គិចអារម្មណ៍យ៉ាងម៉េចដែរ ពីព្រោះថាគាត់កាលណោះក៏ជានារីដើមកំណើតវៀតណាមដែរនៅពេលនោះ។ អ៊ីចឹងសំណួរខ្ញុំៗចង់ដឹងថា តើព្រឹត្តិការណ៍នេះប៉ះពាល់ជា

លក្ខណៈបុគ្គលទៅលើដើមបណ្ដឹងរដ្ឋប្បវេណីនេះយ៉ាងណាដែរ ពីព្រោះថានេះវាជាកម្មវត្ថុនៃសវនាការរបស់យើង។ ខ្ញុំសូមឲ្យលោកប្រធានអនុញ្ញាតឲ្យលោកលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីនេះឆ្លើយតបនឹងសំណួរនេះ ដើម្បីបញ្ជាក់ធៀបទៅនឹងរូបគាត់ឲ្យផ្ទាល់តែម្ដង។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១២:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវី គង់ សំអុន ហើយ -- ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ។

**លោកស្រី សៀង ចាន់ថី៖**

**ឆ៖** សូមឲ្យគាត់សួរម្ដងទៀត ដើម្បីឲ្យច្បាស់។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រីបាននិយាយកាលពីម្សិលមិញអំពីនារីពីរនាក់មានដើមកំណើតជាវៀតណាមនៅក្នុងភូមិរបស់លោកស្រី ដែលត្រូវបានគេរំលោភ។ ខ្ញុំចង់ដឹងថា តើលោកស្រីអាចរៀបរាប់លម្អិតបានដែរឬទេអំពីព្រឹត្តិហេតុនេះ ហើយនិងអំពីផលប៉ះពាល់ ដែលប៉ះពាល់មកលើរូបលោកស្រីដោយផ្ទាល់នៅសម័យនោះៗ។

[០៩:១៣:៤៥]

**ឆ៖** ចាស ខ្ញុំអាចរៀបរាប់បាន។ ព្រោះជនរងគ្រោះពីរនាក់នុ៎ង គាត់ម្ដាយគាត់ជាវៀតណាម ហើយគាត់រស់នៅក្នុងភូមិជាមួយគ្នាខ្ញុំ ហើយគាត់ទាំងពីរនាក់ធ្វើការរែកដីជាមួយខ្ញុំ។ ពេលដែលគេចាប់គាត់យកទៅ ខ្ញុំអត់បានដឹងទេ ប៉ុន្តែគ្រាន់ថាបាត់គាត់ពីកន្លែងធ្វើការ ខ្ញុំក៏សួរមិត្តភក្ដិហ្នឹងខ្សឹបសួរ មិនមែនសួរឮៗទេ ខ្សឹបសួរគ្នាថា "បងស្រអែមឌី ហើយនិងស្រីទូចទៅណាហើយ? គេថាគេយកទៅវៃចោលហើយ។" ដល់ពេលហ្នឹង ខ្ញុំមកផ្ទះ មកផ្ទះពេលយប់ បានឮសួរប៉ាខ្ញុំខ្សឹបប្រាប់ខ្ញុំទៀត គាត់ថាកូនអើយក្នុងភូមិយើងគ្រួសារ សាក់ប៊ុនថុន ហ្នឹងគេយកទៅវៃចោលអស់ហើយ។ ដូច្នេះប៉ាខ្លាច។ ខ្លាចៗ កូនយើងគេយកទៅចាប់រំលោភ គេមុនយកវៃចោល គេចាប់រំលោភទៀត។ ពេលដែលឮសួរប៉ាខ្ញុំនិយាយ ខ្ញុំភ័យតក់ស្លុតជាខ្លាំង ព្រោះអី ខ្ញុំនឹកឃើញថា ថ្ងៃណាមួយពេលណាមួយ ខ្ញុំនឹងៗគេយកទៅដូចគ្នា។ ព្រោះខ្ញុំ

ជាកូនកាត់វៀតណាមដូចគ្នា។ ខ្ញុំតែងតែគិតរហូត។ ពេលធ្វើការ កាលណាជួបមេកង ខ្ញុំអត់ហ៊ានមើលមុខគេទេ ខ្ញុំឈ្ងោកមុខ ខ្ញុំគេចពីគេ។ ពេលណាឃើញគេអ៊ីចឹង ខ្ញុំខំធ្វើការរត់ ដើម្បីឱ្យគេឃើញថា យើងធ្វើការសកម្ម កុំឱ្យគេយកទៅវាយចោល។ ពេលហ្នឹងអ្នស ពេលព្រឹក ខ្ញុំរស់បានមួយព្រឹក ពេលដល់ពេលថ្ងៃរសៀលម៉ោងពីរ ម៉ោងបី ខ្ញុំចាប់ផ្ដើមភ័យព្រួយបារម្ភ ព្រោះខ្លាចគេយកទៅវាយចោល។ ការភ័យខ្លាចរបស់ខ្ញុំ គឺជាប់រហូត។ រហូតដល់ពេលប៉ាខ្ញុំគាត់ដាច់ចិត្តធ្វើអត្តឃាត ដូចខ្ញុំរៀបរាប់ប្រាប់អង្គតុលាការទាំងមូលពីម្សិលអ៊ីចឹង។ ការភ័យខ្លាចរបស់ខ្ញុំ ភ័យរហូតៗទាល់តែៗគេរំដោះបាន បានខ្ញុំឈប់ភ័យ។ នេះជារឿងពិត ខ្ញុំបានឮៗមែន ប៉ុន្តែក្នុងអារម្មណ៍របស់ខ្ញុំ ដែលជាជនជាតិវៀតណាម ជាកូនកាត់ដូចគ្នា គឺមានភាពភ័យខ្លាចរហូត ខ្លាចណាស់។ ខ្លាចតែគេយកទៅ មិនដឹងពេលណា ម៉ោងណា។ តែឃើញប្រធានសហករណ៍ ឬមួយប្រធានកងគេមកអ៊ីចឹង ភ័យញ័រអស់ហើយ។ ញ័រដៃ ញ័រជើងអស់ហើយ។ ធ្វើការ ជួនកាលលើកដីមួយបង្គី សែង គេធ្វើពីរនាក់ ខ្ញុំធ្វើតែម្នាក់ឯងទេ ព្រោះអីបងប្អូនដែលមិត្តភក្តិដែលនៅធ្វើការជាមួយគ្នាហ្នឹង គេ -- ខ្ញុំគេអត់ស្ដីរកខ្ញុំ ខ្ញុំខ្សឹបសួរគេថា “ថី បានពួកអ្អែង អត់ស្ដីរកខ្ញុំ?” “ហ៊ីអ្អែង ឪម៉ែអញប្រាប់ថា ឯងកូនកាត់វៀតណាមអ៊ីចឹង គាត់មិនឱ្យស្ដីរកទេ។ តែគេយកអ្អែងទៅវៃចោល គេយកដោយពួកអញដែរហើយ អញអត់ហ៊ានស្ដីរកទេ។” ម្ល៉ោះហើយការងារគេធ្វើពីរនាក់ ខ្ញុំធ្វើតែម្នាក់ឯងទេ ព្រោះគេខ្លាចៗមានពាក់ព័ន្ធជាមួយគេ គេស្លាប់ជាមួយខ្ញុំដែរ។ ម្ល៉ោះហើយ ខ្ញុំធ្វើការអីធ្វើតែម្នាក់ឯង។ ភាពភ័យខ្លាចហ្នឹងហើយដែលខ្ញុំចងចាំរហូតមកទល់សព្វថ្ងៃ។

[០៩:១៧:៣៧]

**ស៖** ខ្ញុំសូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរចុងក្រោយមួយទៀត។

កាលពីម្សិលមិញ លោកស្រីបាននិយាយអំពីការបាត់បង់បងប្រុសលោកស្រីទាំងពីរ គឺ ចន្ថា ហើយនិង ចាន់ថន។ ខ្ញុំចង់សូមឱ្យលោកស្រី និយាយបានលម្អិតបន្តិច ចែកជូនតុលាការ ថាតើមានរឿងអីកើតឡើងចំពោះពួកគាត់ ហើយលោកស្រីទទួលអារម្មណ៍យ៉ាងណាដែរ នៅពេលដែលលោកស្រីដឹងអំពីការបាត់ខ្លួនរបស់ពួកគាត់ទាំងអស់នុ៎ង?

**ឆ៖** ខ្ញុំសូមនិយាយពីបង ចន្ថា ខ្ញុំ។ បងចន្ថា ខ្ញុំគាត់ជានាយទាហាន។ គាត់ទាហាន លន់ នល់ គាត់ពាក់ស័ក្តិ១។ ហើយរឿងរ៉ាវគាត់ ក៏ខ្ញុំបាននិយាយច្រើនដែរពីម្សិលមិញ ដោយគេចាប់គាត់ពីឃុំបាសាក់ ភូមិ៧សាលាបង្រៀន គេហៅបាយ៉ាប នៅក្នុងស្រុកស្វាយជ្រំដែរ។ គេចងគាត់ ដោយចោទគាត់ថាគាត់ហ្នឹង គាត់កាប់ដើមជ្រៃយកមកធ្វើទ្រើងនទោង ហើយនិងគាត់ភ្លួរ គាត់អត់ចេះភ្លួរទេ ព្រោះគាត់ធ្លាប់

តែរៀន ធ្លាប់តែធ្វើទាហាន ដល់ឲ្យគាត់ទៅភ្ជួរ គាត់អត់ចេះភ្ជួរ។ ពេលនុ៎ងគោផ្អើលទៅ មុតជើងគោ ដល់ពេលមុតជើងគោ គេថាគាត់ហ្នឹងប្រឆាំងនឹងអង្គការ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អង្គការ។ វាក៏ចាប់គាត់ចង១ ចងហើយបណ្ដើរតាមកង់វ៉ែគាត់រហូត។ ពេលនុ៎ង ខ្ញុំនៅបាចទឹកពេលល្ងាច។ ស្រាប់ខ្ញុំក្រលេកទៅឃើញ គេវ៉ៃភឹង១ ពីណា គេចងវ៉ៃ ស្រាប់តែក្រលេកទៅឃើញ បងសោះ។ ឃើញបងគេចងវ៉ៃដូចសត្វ ដូចធាតុ។ ប្រជាជនចាស់ កាលណាគេឃើញហ្នឹង គេទាញដងរែក ទាញធាងត្នោតដាក់បងខ្ញុំភឹង១។ គាត់ក្រលេកមើលឃើញហៅខ្ញុំ ឲ្យប្រាប់ម៉ែផង បងគេចាប់យកទៅមន្ទីរស្រុកហើយ អូន។ ខ្ញុំអត់ហ៊ានប្រាប់ម៉ែខ្ញុំ ប៉ាខ្ញុំទេ ព្រោះម្ដាយខ្ញុំ គាត់មានជំងឺម្យ៉ាង កាលណាតែឮអី គាត់ស្ទះដង្ហើម។ ខ្ញុំអត់ហ៊ានប្រាប់។

គេវ៉ៃគាត់តាំងពីបាសាក់មកមិនតិចគីឡូទេ ឆ្ងាយណាស់ទម្រាំដល់មន្ទីរស្រុក ឆ្ងាយណាស់ ប្រហែលជាជាប់១០គីឡូហើយ គេវ៉ៃរហូត។ បងខ្ញុំបែកឈាមពេញខ្លួនទាំងអស់។ ខ្ញុំមើលអត់ចង់ស្គាល់បងទេ ឮសម្ដីបងរត់ទៅមើលនឹងគេ។ រត់ទៅឃើញ បងអញសោះ ក្រឡេកឃើញប្អូន គ្រាន់តែ ក្រឡេកមើលទៅអ៊ីចឹង ប្អូនអើយ ប្រាប់ម៉ែ ប្រាប់ប៉ាផង បងគេចាប់ហើយ។ អារម្មណ៍តាំងពីនុ៎ងមក ខ្ញុំរាល់ថ្ងៃ សូម្បីតែគេចាប់ចោរប្លន់ ចោរលួចអីក៏ដោយ តែគេវ៉ៃមុខខ្ញុំ ខ្ញុំឃើញ ទិដ្ឋភាពហ្នឹងដូចគេវ៉ៃបងខ្ញុំអ៊ីចឹង ខ្ញុំមិនអាចបំភ្លេចបានទេ។

[០៩:២១:១៤]

ហើយរឿងមួយទៀត បងខ្ញុំ បងចាន់ថន បងទី១ គាត់ជាប៉ូលិស ប៉ូលិសលន់នល់ គាត់ក៏ពាក់ស័ក្តិ១ដែរ។ ពេលថ្ងៃមួយបងខ្ញុំគាត់មានជំងឺស្ពឹក កាលណាខែវស្សា គាត់ទៅធ្វើការនៅក្នុងទឹកអត់បានទេ គាត់ស្ពឹក គាត់ចុកជើង គាត់សុំគេធ្វើការលើគោក។ ដល់ពេលហើយ ខ្ញុំដំបៅជើង ខ្ញុំនៅក្នុងផ្ទះបាយ គេឲ្យធ្វើការនៅលើគោក។ ខ្ញុំនៅផ្ទះបាយ ស្រាប់តែយប់ងងឹត១ហ្នឹង ខ្ញុំកំពុងតែរៀបចាន រៀបឆ្នាំងឲ្យគេ ឮមេកងគេ គេប្រជុំ គេជំនុំគ្នា "គេថាអាចាន់ថន អាហ្នឹងឲ្យតែវស្សាឡើង ប្រើវា វាស្ពឹករហូត អាហ្នឹងទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ។ ទុកវានាំតែចង្អៀត។ កង់ប្រវត្តិសាស្ត្រតែគេវិលទៅមុខ វិលទៅមុខហើយ តែលើកដៃវា បាក់ដៃ លើកជើងវា បាក់ជើង។ អាហ្នឹងទុកមិនចំណេញដកចេញមិនខាត ចាំថ្ងៃណាដកវាចេញ។" ខ្ញុំឮអ៊ីចឹង ខ្ញុំភ័យញ័រអស់ហើយ ខ្ញុំខំដើរផងរត់ផង ពីផ្ទះបាយមកប្រហែលជាពីរបីរយម៉ែត្រ។ ខ្ញុំមកដល់ ខ្ញុំសួរប៉ាខ្ញុំ ម៉ែខ្ញុំ។ ប៉ាម៉ែ បងចាន់ថន ទៅណាហើយ? គាត់ថា នៅហ្នឹងកូន។ ខ្ញុំហៅគាត់មកខ្សឹបប្រាប់ ខ្ញុំថា បងអើយបង បងឯងចាប់ពីថ្ងៃហ្នឹងទៅ បងឯងខំធ្វើការឲ្យគេទៅណា

ព្រោះអី ខ្ញុំឮគេជំនុំគ្នាអំមិញ តារ៉េង អាប៊ុកែម អាប៊ុរ៉ាយ វាថា បងឲ្យតែខែវស្សាឡើង បងធ្វើពុត បងស្ពឹក ទុកបងក៏មិនចំណេញ ដកចេញក៏មិនខាតដែរ។ វានិយាយអ៊ីចឹង។ បងខ្ញុំញ័រអស់ហើយ។ ឱបប៉ាខ្ញុំ ឱបម៉ែខ្ញុំ ម៉ែអើយ ប៉ាអើយ ជួយខ្ញុំផងធ្វើម៉េចបើខ្ញុំឈឺអ៊ីចឹង។ ខ្ញុំថា បងឯង ខំធ្វើការឲ្យគេទៅ ឈឺយ៉ាងម៉េចក៏ដោយក៏ខំដែរបង ខំដូចខ្ញុំអ៊ីចឹងទៅ កណ្ដៀតរត់កណ្ដៀតនេះទៅ។ គាត់ថា បងធ្វើអត់រួចទេអូនអើយ បងស្ពឹកជើង។ គាត់ញ័រអស់ហើយ ម៉ែខ្ញុំ បងខ្ញុំ យំឱបគ្នាទាំងអស់គ្នា។ មិនមែនយំឮដូចខ្ញុំអ៊ីចឹងទេ យំខ្សឹបអស់លោក គឺយំខ្សឹប យំមិនហ៊ានឲ្យគេឮទេ។ ទុក្ខវេទនារបស់បងខ្ញុំ របស់គ្រួសារខ្ញុំជំនាន់ហ្នឹងពិបាកណាស់។ ហើយខ្ញុំជឿថា ក្នុងប្រទេសយើងទាំងមូលក៏មានគេពិបាកលើសខ្ញុំទៀតដែរ។ ក៏មានគេកើតទុក្ខដូចខ្ញុំដែរ។ តែខ្ញុំចង់ឲ្យប្រជាជនខ្មែរទាំងមូល និងអន្តរជាតិទាំងអស់ដឹងថា វាមានពិតមែនការទុក្ខលំបាក ការភ័យខ្លាចជំនាន់ប៉ុលពត គឺមាន។

[០៩:២៤:០៩]

បន្ទាប់មក បងខ្ញុំទ្រាំរហូត បងចាន់ថន ទ្រាំរហូតដល់ខែប្រាំង គាត់ទៅបោកស្រូវ។ ឆ្នាំ៧៧ ខ្ញុំចាំថា ខែច្រូត ចុងឆ្នាំហើយ។ ដូចឆ្នាំ៧៧ ហ្នឹង ខ្ញុំទៅច្រូតនឹងគេដែរ រាល់ថ្ងៃឃើញបងទៅ។ ដល់ពេលថ្ងៃហ្នឹងបាត់បងខ្ញុំ ខ្ញុំសួរពូរ៉េកបាយ “ពូៗឃើញ បងចាន់ថន ទេ? ថា ហ៊ឹស ចាន់ថន នៅហ្នឹងតើ!” គេអត់ហ៊ានប្រាប់ខ្ញុំទេ។ ដល់ហើយខ្ញុំទៅសួរមេកង ប្រុងទៅសួរអាអ្នកសម្លាប់ហ្នឹង ខ្ញុំអត់ដឹងទៀត ខ្ញុំទៅសួរគាត់ចាប់ដៃខ្ញុំជាប់ “អ្ហែងកុំទៅ ចាំទៅផ្ទះវិញសួរម៉ែសួរឪ សួរប៉ាដឹងហើយ”។ ខ្ញុំចាប់ផ្ដើមខ្ញុំសង្ស័យហើយ ព្រោះអីដូចថាអ្នកភូមិ កាលណាគេយកមនុស្សទៅវ៉ៃចោលអ៊ីចឹង សភាពនៅក្នុងភូមិ គេមានភាពដូចថាស្ងប់ស្ងាត់ គេខ្លាច គេនិយាយអីគ្នាខ្សឹបៗ។ ដល់ពេលហើយ ល្ងាចឡើង ខ្ញុំមកសួរប៉ាខ្ញុំ ម៉ែខ្ញុំ។ គាត់កំពុងយំអោបគ្នាហ្នឹង។ ប៉ាខ្ញុំ ហើយម៉ែខ្ញុំ គាត់ស្រឡាញ់គ្នា តែមានរឿងអី គាត់ទៅអោបគ្នាហ្នឹង។ ដល់ពេលអ៊ីចឹងទៅ ខ្ញុំមកដល់សួរប៉ាៗ? ប៉ាថា “អីហា!”។ ម៉ែខ្ញុំថា ខ្ញុំឃើញម៉ែយំ “ម៉ែថី? ម៉ែៗឈឺទៀតអី?” “ម៉ែអត់ឈឺទេកូន”។ ខ្ញុំថា “ម៉ែបងចាន់ ថន ទៅណា អត់ឃើញទៅបោកស្រូវ ម៉ែ?” “គេយកទៅហើយកូន គេយកទៅសែងអីវ៉ាន់ល្ពប។” កាលជំនាន់ហ្នឹង តែសែងអីវ៉ាន់ល្ពប គឺគេយកទៅវ៉ៃចោលហើយ។ ម៉ែខ្ញុំថា “យកទៅសែងអីវ៉ាន់ល្ពបហើយកូន បងមិនមកវិញទេ។” ពេលហ្នឹងប៉ាខ្ញុំគាត់ថា “ចាន់ថន ណា៎ វាទៅស្រាតអាវថ្មីៗទុកទាំងអស់ហ្នឹងកូនអើយ។” ប៉ាថា “ចាន់ថន អ្ហែងម៉េចមិនស្លៀកខោកូន? ស្លៀកខោជើងវែងទៅ ខ្លាចមូសខាំ។” ទៅសែងអីវ៉ាន់ល្ពប គាត់ថា “ទៅដល់ហ្នឹងមូសលែងខាំហើយប៉ា។” គាត់ស្លៀកតែខោអាវរហែកៗ គាត់ប៉ះជាមួយនឹងកំណាត់ខ្មៅព្រៃរបស់ម្ដាយខ្ញុំ ដែលគាត់

កាន់ទុក្ខប្រពន្ធគាត់ស្លាប់។ ប្រពន្ធគាត់ស្លាប់មិនទាន់បានប៉ុន្មានខែផង គេយកគាត់ទៅវ៉ៃចោលទៀត។ គាត់ស្លៀកខោអាវរហែកៗ គ្មានខោអាវថ្មីស្លៀកទេ ព្រោះទុកខោអាវថ្មីឲ្យប្អូនៗស្លៀក។ ពេលវាយកបងខ្ញុំទៅវ៉ៃចោល គ្នាប្អូននាក់។ ពូមួយគាត់មានគងសំណុំ។ ចាស់ៗ គេថាគងសំណុំកាប់មិនមុត។ បងប្រុសខ្ញុំវាមក -- វាសម្លាប់ហើយ វាមកនិយាយ។ វាថា "អាចាន់ ថន មិនទាន់បានវ៉ៃផង វាសន្លប់បាត់ហើយ។ វ៉ៃតែអាដែកសោះ វាសន្លប់បាត់ហើយ។ ខ្ញុំឮផ្ទាល់ៗនឹងត្រចៀករបស់ខ្ញុំ។ ផ្ទះខ្ញុំនៅជិតផ្ទះបាយនេះ ខ្ញុំទៅសុំអំបិល សុំអីអ្នករោងបាយហ្នឹង ខ្ញុំឮ។ វាយកខោអាវ យកកំបិតមកសំលៀងហ្នឹង នឹងផ្ទះបាយ ឃើញខោអាវសុទ្ធតែឈាម។ វាសម្លាប់ហើយ ប្រឡាក់ឈាមទៅ វាយកត្រាំចានដែកនៅផ្ទះបាយ ទុកបោក។

[០៩:២៧:៤០]

វាសម្លាប់ហើយ វាយកមកនិយាយទៀត។ ខ្ញុំថា ម្តាយខ្ញុំគាត់ គាត់មានការតក់ស្លុតខ្លាំងណាស់ ព្រោះផ្ទួនៗគ្នា។ ក្នុងឆ្នាំ៧៧ ហ្នឹងគឺគ្រួសារខ្ញុំមានទុក្ខផ្ទួនៗគ្នា ព្រោះអីប្រពន្ធបង ចាន់ ថន គាត់ឆ្លងទន្លេ។ ឆ្លងទន្លេ ចាស់ៗគាត់ថាព្រាយក្រឡាភ្លើង បានបីថ្ងៃ គាត់ស្លាប់ទៅ។ មិនបានប៉ុន្មានខែផង គាត់ក៏គេយកទៅវ៉ៃចោលទៀត។ ហើយប៉ាខ្ញុំ ក៏គាត់ធ្វើអត្តឃាត ហើយបងប្រុសខ្ញុំទី២ បងចន្ថា ក៏គេយកទៅសម្លាប់នៅមន្ទីរស្រុកហ្នឹងទៀត។ ដូច្នេះម្តាយខ្ញុំ គាត់ឃុំខ្លួននៅក្នុងផ្ទះបីខែ។ គាត់អត់ចេញក្រៅ។ ពេលណាកូនយកបាយឲ្យពិសាទៅ គាត់ពិសាទៅ។ បើកូនមិនយកទេ ខ្ញុំទៅធ្វើការបាត់អីចឹងទៅ ប្អូនៗខ្ញុំហ្នឹង យកទៅ។ គាត់ចង់តែធ្វើអត្តឃាតដែរ ព្រោះគាត់អាសោចអសាប្តី អសោចសាកូន។ គាត់ស្តាយកូន ស្តាយប្តីគាត់។ រហូតដល់សម័យយើងរំដោះ ក៏គាត់នៅតែយំ។ ជួនកាលគាត់អង្គុយៗគាត់យំអីចឹង។ ខ្ញុំសួរថា "ម៉ែៗឯងថី?" "នឹកប៉ាអ្ហែង នឹកបងអ្ហែង នៅភ្នែក។" រហូតដល់គាត់ឈឺ គាត់គាំងបេះដូងស្លាប់ទៅម្តាយខ្ញុំ។ រឿងហ្នឹង កាលណាខ្ញុំពេលណា គឺខ្ញុំទឹកភ្នែកពេលហ្នឹង ព្រោះអីខ្ញុំនឹកឃើញរឿងហ្នឹង ដូចជានៅថ្មីៗនៅនឹងភ្នែក ជិតជាប់ក្នុងអារម្មណ៍ខ្ញុំ។

[០៩:៣០:១០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន យើងខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណលោកប្រធាន ដោយយើងសួរចប់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា

ដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បើសិនជាមាន។ សូមអញ្ជើញ!

**លោក សេង លាង៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ហើយជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ។ ថ្ងៃនេះ ខ្ញុំបាទមានសំណួរមួយចំនួនចង់ឲ្យលោកស្រីជួយបំភ្លឺដល់អង្គសវនាការ។ សំណួរដំបូងរបស់ខ្ញុំនោះ ចង់ឲ្យលោកស្រីបញ្ជាក់បន្តិចថាតើនៅក្នុងអំឡុងពេលដែលពួកខ្មែរក្រហមកាន់អំណាចនុ៎ង តើលោកស្រីរស់នៅទីកន្លែងណា?

[០៩:៣១:២៨]

**លោកស្រី សៀង ចាន់ចី៖**

**ឆ៖** ខ្ញុំរស់នៅក្នុងភូមិឫស្សីព្រៃ ឃុំចម្លង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

**ស៖** លោកស្រីជួយបញ្ជាក់បន្តិចបានទេថា តើឪពុកម្ដាយរបស់លោស្រីហ្នឹងជាជនជាតិអ្វីដែរ អាចជម្រាបបានទេ?

**ឆ៖** ម្ដាយខ្ញុំខ្មែរសុទ្ធ ឪពុកខ្ញុំ ជីតាខ្ញុំ និងយាយខ្ញុំវៀតណាមនៅស្រុកខ្មែរ។ ដូច្នេះ ប៉ាខ្ញុំជាជនជាតិវៀតណាម ប៉ុន្តែគាត់បានទិញត្រកូលគេ ត្រកូលខ្មែរ។ គាត់រៀនខ្មែរ គាត់ធ្វើការជាមន្ត្រីរាជការ។

**ស៖** អ៊ីចឹងមានន័យថា លោកស្រី -- ឪពុកលោកស្រីគឺជាវៀតណាម ហើយម្ដាយលោកស្រីជាជនជាតិខ្មែរ ហើយលោកស្រីជាកូនកាត់វៀតណាម។ តើអ្វីដែលខ្ញុំនិយាយត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ក្រៅពីឪពុករបស់លោកស្រី ម្ដាយលោកស្រី និងបងប្អូនប្រុសស្រីរបស់លោកស្រី គាត់ចេះនិយាយភាសាវៀតណាមដែរទេ?

**ឆ៖** អត់ចេះទេ បងប្អូនខ្ញុំអត់ចេះវៀតណាមទេ ចេះតែប៉ាខ្ញុំម្នាក់ឯង។

**ស៖** តើលោកស្រីមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ អាចប្រាប់បានទេ ហើយពួកគេមានឈ្មោះអីខ្លះ?

**ឆ៖** បងប្អូនខ្ញុំទាំងអស់ប្រាំបីនាក់។ បងទី១ឈ្មោះ ជ្រូក ចាន់ថន, បងទី២ឈ្មោះ ជ្រូក ចន្ថា, បងទី៣ ឈ្មោះ ជ្រូក ចាន់ធីតា, បងបងទី៤ឈ្មោះ ជ្រូក ចាន់ធាវី, ទី៥ ខ្ញុំ ខ្ញុំដាក់ឈ្មោះ ឥឡូវដាក់ឈ្មោះ សៀង ចាន់ថី, ប្អូនទី៦ឈ្មោះ ធឿង មុន្នី, ប្អូនទី៧ឈ្មោះ ជ្រូក ចន្នី, និងប្អូនពៅឈ្មោះ ហ៊ិន មុន្នី។

**ស៖** បាទអរគុណលោកស្រី។ តើលោកស្រីអាចប្រាប់បានទេថា តើនៅក្នុងភូមិរបស់លោកស្រីហ្នឹងប្រជាជនទូទៅដឹងថាគ្រួសាររបស់លោកស្រីជាគ្រួសារវៀតណាមដែរឬយ៉ាងណា?

[០៩:៣៥:០០]

**ឆ៖** ចាស គេដឹង ព្រោះប៉ាខ្ញុំ គាត់ដូចវៀតណាម ព្រោះគាត់ស។ គាត់សៗដូចវៀតណាម គេដឹង គេស្គាល់ៗថា គាត់ជាជនជាតិវៀតណាម។

**ស៖** កាលពី កាលពីម្សិលមិញ លោកស្រីបានមានប្រសាសន៍ថា បើខ្ញុំមិនច្រឡំទេ គឺនៅក្នុងភូមិរបស់លោកស្រី មានគ្រួសារវៀតណាមបីគ្រួសារផ្សេងទៀត រួមទាំងគ្រួសាររបស់លោកស្រីផង បួនគ្រួសារ។ តើអ្វីដែលខ្ញុំនិយាយហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** មានតែបីគ្រួសារ ទាំងគ្រួសារខ្ញុំ។

**ស៖** បាទ អរគុណ លោកស្រីដែលជួយបំភ្លឺខ្ញុំ។ តើលោកស្រីអាចប្រាប់បានទេថា នៅក្នុងរបបខ្មែរក្រហមនោះ លោកស្រីមានធ្លាប់ឮថា តើពួកខ្មែរក្រហមមានធ្លាប់ជជីកសួរដេញដោល ដើម្បីរកឲ្យឃើញថានរណាជាគ្រួសារវៀតណាម ដែរឬទេ?

**ឆ៖** គេមិនជជីកសួរអីទេ ព្រោះដូចថា គេស្គាល់ពីដើមមកអ៊ីចឹងថា អ្នកណាជាកូនកាត់វៀត-ណាម គ្រួសារវៀតណាម គឺគេស្គាល់។ បើគ្រួសារពីរនាក់ទៀតនុ៎ង គាត់ម្ដាយគាត់ហ្នឹង ជាវៀតណាម គាត់និយាយខ្មែរអត់ច្បាស់ទេ។ គាត់អត់ដូចប៉ាខ្ញុំទេ ប៉ាខ្ញុំគាត់និយាយខ្មែរច្បាស់ ព្រោះគាត់នៅស្រុកខ្មែរ គាត់និយាយខ្មែរច្បាស់។

**ស៖** ក្រៅពីឪពុករបស់លោកស្រីដែលជាជនជាតិវៀតណាមនោះ តើបងប្អូនរបស់លោកស្រីហ្នឹង ត្រូវគេចាត់ទុកថាជាជនជាតិវៀតណាមដែរ ឬក៏យ៉ាងណា?

**ឆ៖** គេនិយាយថាកូនកាត់យួន ភាសាហ្នឹង គេនិយាយថា “ហ៊ឺ! កូននុ៎ង កូនកាត់យួន”។

[០៩:៣៧:៣៦]

**ស៖** បាទ អរគុណលោកស្រី។ កាលពីម្សិលមិញ ហើយក៏ដូចជាថ្ងៃនេះដែរ លោកស្រី កាលពីម្សិលមិញ លោកស្រីបានមានប្រសាសន៍ថា ប្រជាជនចាស់មើលងាយគ្រួសារលោកស្រី ដោយចោទថា

ជាសក្តិភូមិ ជាសាច់ឈាមវៀតណាម ហើយថ្ងៃនេះក៏បាននិយាយទៀតថា នៅក្នុងកងរបស់លោកស្រីហ្នឹង គឺគេមិននិយាយចូលលោកស្រីទេ ដោយសារថាលោកស្រី នៅពេលដែលលោកស្រីសួរគេថា មូលហេតុអ្វីបានជាគេមិននិយាយរកលោកស្រី គេថាលោកស្រីជាកូនកាត់វៀតណាម ខ្លាចគេយកទៅសម្លាប់ទៅ ដោយទាំងគេ។ តើដែលខ្ញុំលើកនេះ គឺវាត្រឹមត្រូវដែរឬទេ?

**ឆ៖** ជារឿងត្រឹមត្រូវហើយ។

**ស៖** ចុះក្រៅពីការចាត់ទុកថាជាជនជាតិវៀតណាម ក្រៅពីការមិនរាប់រកនុំង តើពួកខ្មែរក្រហមមានបានប្រព្រឹត្តអ្វីទៅលើក្រុមគ្រួសាររបស់លោកស្រី ដែលលោកស្រីកត់សម្គាល់ថា មានលក្ខណៈខុសប្លែកពីប្រជាជនខ្មែរដទៃទៀតដែរឬទេ? ឧទាហរណ៍ថា ដូចជារបបអាហារ ឬអ្វីៗផ្សេងទៀត។

**ឆ៖** ការហូបចុក បើប្រជាជននៅក្នុងភូមិហ្នឹង គេហូបអី យើងហូបនុំងដែរ។ គេចែកបបរចែកបាយប៉ុន្មានអីចឹង គេចែកដូចគ្នា។

**ស៖** លោកស្រីច្បាស់ទេថា គេចែករបបអាហារស្មើៗគ្នាដូចប្រជាជនដទៃទៀតដែរ?

**ឆ៖** ច្បាស់ហើយ ព្រោះខ្ញុំនៅរោងបាយហ្នឹង។ គេចែកមួយចានៗដូចគ្នាអីចឹង គ្រាន់ថា ហូបឆ្អែតមិនឆ្អែតអី អត់ដឹង។ កាលណាខ្ញុំហូបមិនអស់អីចឹង ខ្ញុំយកទៅឲ្យបងខ្ញុំ ប៉ាខ្ញុំទៀតទៅ។ ខ្ញុំរំលែកទៅព្រោះខ្ញុំនៅរោងបាយ ខ្ញុំអាចសុំបាយក្តាំងអីគេហូបបានអីចឹង ខ្ញុំរបបខ្ញុំមានអីចឹង ខ្ញុំយកទៅរំលែកឲ្យប៉ាខ្ញុំឲ្យបងខ្ញុំ។ ពេលដែលប៉ាខ្ញុំ ឃើញខ្ញុំយកបាយទៅឲ្យហ្នឹង គាត់លើកចានឡើងគាត់ស្រក់ទឹកភ្នែក គាត់សួរកូនឯងហូបឆ្អែតឬនៅកូន? ខ្ញុំថា ខ្ញុំឆ្អែតហើយប៉ា ប៉ាពិសាទៅ ប៉ាហូបទៅ។

[០៩:៤០:១២]

**ស៖** អរគុណលោកស្រី។ ប៉ុន្តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី គឺឯកសារលេខ 22366 ERN ជាភាសាអង់គ្លេស 01192660 និងជាភាសាបារាំង 01206358 និងជាភាសាខ្មែរ 00492094 លោកស្រីបានលើកឡើងថា៖ "បងប្អូនខ្ញុំទាំងអស់សុទ្ធតែកូនកាត់វៀតណាម គឺពួកខ្មែរក្រហម ធ្វើបាបក្រុមគ្រួសារខ្ញុំខ្លាំងណាស់ សូម្បីតែបបរក៏ចែកឲ្យមិនស្មើគេដែរ។ គឺគេឲ្យប្រជាជនចាស់បីវែក ហើយឲ្យពួកខ្ញុំតែមួយវែកកន្លះតែប៉ុណ្ណោះក្នុងម្នាក់ ហើយនិយាយថា កុំតវ៉ាអីស៊ី តវ៉ាអីស៊ីទៅ គេមិនយកទៅសម្លាប់សំណាងហើយ ខំធ្វើការទៅកុំខ្ជិល។ គឺពួកខ្ញុំធ្វើការគ្មានពេលសម្រាកនោះទេ។ គឺពួកខ្ញុំធ្វើការក្នុងសម័យនោះ វេទនាជាទីបំផុត គឺធ្វើការគ្មានរដូវប្រាំង និងរដូវវស្សារហូតដល់ឆ្នាំ១៩៧៦។" តើអ្វីដែលលោកស្រីឡើងនៅពេលនេះ ហើយនិងអ្វីដែលលោកស្រីបាននិយាយប្រាប់នៅក្នុង

ពាក្យដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺលោកស្រីប្រកាន់យកមួយណាដែរ?

**ឆ៖** កាលដែលយើងធ្វើរោងបាយដំបូងគឺមានលក្ខណៈដូចអ៊ីចឹង ដល់ពេលខាងក្រោយមក ដូចថា រៀងធូរៗបន្តិចទៅ មុនដំបូងគេតឹងតែងណាស់ គេចែកបបរចែកអីឱ្យហូប ស្រូវអង្ករអីគេចែកឱ្យតិចតួចអ៊ីចឹងមែន។ ចាស ដល់ពេលចុងក្រោយមក ដូចថាយើងខាងសហករណ៍គេធ្វើស្រូវបានអ៊ីចឹង ខែប្រាំងគេឱ្យយើងហូបឆ្អែត ដល់ពេលខែវស្សាបានគេបង្អត់យើងទៀត។

**ស៖** អរគុណលោកស្រីដែលបានឆ្លើយតបសំណួរនេះ។ នៅក្នុងរបបខ្មែរក្រហម តើលោកស្រីមាននៅចាំបានទេថា តើមានពេលណាដែលការប្រព្រឹត្តរបស់ជនជាតិវៀតណាមចាប់ផ្តើមមានស្ថានភាពអាក្រក់នោះ ឬក៏វាអាក្រក់តាំងពីដើមមក តើលោកស្រីអាចប្រាប់បានទេ?

[០៩:៤៣:០០]

**ឆ៖** អរគុណ។ ពេលដែលខ្ញុំចាំគឺ ចាប់ផ្តើមពីពេលដែលវៀតណាមវ៉ៃចូលម្តងហើយ ទ័ពវៀត-ណាមដកទៅវិញ ហ្នឹងបានគេចាប់ផ្តើមធ្វើទុក្ខបុកម្នេញជាមួយជនជាតិវៀតណាម និងជនជាតិដទៃៗទៀត តាមដែលខ្ញុំចាំ ព្រោះកាលនោះខ្ញុំនៅក្មេងដែរ។ ខ្ញុំប្រាប់បានតាមដែលខ្ញុំអាចចាំបាន ខ្ញុំឆ្លើយបាន។

**ស៖** លោកស្រីអាចដឹងពីមូលហេតុនៃការចាប់ផ្តើមប្រព្រឹត្តអាក្រក់នេះ ដោយសារមូលហេតុអីដែរ លោកស្រីអាចដឹងបានទេ?

**ឆ៖** តាមដែលការខ្ញុំយល់ គឺកាលនោះមកពីខាងវៀតណាមគេវ៉ៃចូល។ ដល់ពេលអ៊ីចឹងទៅ គេចោទប្រកាន់យើងថា យើងចូលដៃចូលជើងយួន ក្បាលយួន ខ្លួនខ្មែរ។ គេច្រើននិយាយភាសាហ្នឹង ភាសាខាងប្រធានសហករណ៍ សហករណ៍អី គេច្រើនជំនុំគ្នាអ៊ីចឹង យើងឮ។

**ស៖** បាទ អរគុណលោកស្រី។ ម្សិលមិញ ខ្ញុំបានស្តាប់ឮលោកស្រីមានប្រសាសន៍ថា ប្រធានសហករណ៍ហ្នឹងគាត់តែងតែចោទ ហៅឪពុករបស់លោកស្រីថា តាធឿង តាឯងវៀតណាមសុទ្ធ ហើយលោកស្រីមានប្រសាសន៍ថា ឪពុករបស់លោកស្រីមានការភ័យខ្លាចខ្លាំង។ តើគាត់មានប្រតិកម្មអីតបនឹងការនិយាយយ៉ាងនេះរបស់កម្មាភិបាលខ្មែរក្រហមហ្នឹងដែរទេ?

[០៩:៤៥:០០]

**ឆ៖** ចាស គាត់ឮសូរអ៊ីចឹង គាត់ភ័យណាស់។ តែមុខគេ គាត់មិនហ៊ានមើលផង។ គាត់ដើរគេចគេរហូត រហូតដល់គាត់ភ័យ គាត់អត់ហ៊ាន ហូបបាយអីក៏មិនបាន អីក៏មិនបាន ព្រោះគាត់គិតថា គាត់ថ្ងៃណាមួយគាត់ គេយកទៅហើយ។ គេយកទៅដូចគ្រួសារពីរគ្រួសារទៀតអ៊ីចឹង។ គាត់អត់ហូប

បាយទេ គាត់ស្គម ស្បែកនៅដណ្ដប់ឆ្អឹង។ ហើយក៏គាត់ចាប់ផ្ដើមរៀបចំគំនិតទៅជំនុំជាមួយម៉ែខ្ញុំថា គាត់នឹងធ្វើអត្តឃាត ដើម្បីឲ្យកូនរស់ ព្រោះកូនសាច់ឈាមច្រឡំគេច្រឡំឯង។ គាត់ខុសគេ ឲ្យគាត់ទៅតែឯងទៅ ឲ្យកូននៅរស់ ព្រោះកូនគាត់នៅប្រាំមួយនាក់ទៀត ភ្នែកខ្មៅៗ អាចនៅរស់។ ឥឡូវនៅរស់មែនក្រោយពីប៉ាខ្ញុំធ្វើអត្តឃាតទៅ កូននៅរស់ នៅរស់ទាំងប្រាំមួយនាក់នៅក្នុងសម័យនេះ។ តែប៉ាខ្ញុំស្លាប់ហើយ។ ប៉ាខ្ញុំបានធ្វើអត្តឃាតដើម្បីកូន។ នេះគឺជារឿងពិត មិនមែនជារឿងប្រឌិត និងក្លែងក្លាយទេ មិនមែននៅក្នុងរឿងកុនទេ នេះជារឿងពិត ដែលប៉ាខ្ញុំសុខចិត្តធ្វើអត្តឃាត ដើម្បីកូន គឺដើម្បីកូនៗរស់។ កូនគាត់ប្រាំមួយនាក់ នៅរស់សព្វថ្ងៃនេះ បានរួចរស់ជីវិតដល់សព្វថ្ងៃនេះ ប្រាំមួយនាក់បងប្អូន។

**ស៖** អម្បាញ់មិញនេះ លោកស្រីបានមានប្រសាសន៍ថា គ្រួសារវៀតណាមពីរទៀត ក៏ត្រូវគេយកទៅសម្លាប់ដែរ។ តើក្នុងគ្រួសារវៀតណាមទាំងពីរហ្នឹង ក្នុងមួយគ្រួសារៗ តើមានសមាជិកប៉ុន្មាននាក់ដែរ? លោកស្រីចាំទេ?

**ឆ៖** ចាស អរគុណ នៅចាំ។ គ្រួសារស័ក្ដិ៤ ចុន ហ្នឹង ឪពុកខ្ញុំមិនដែលស្គាល់ទេ គ្រាន់តែថា ឮគេថា កូនស័ក្ដិ៤ ចុនៗ ប៉ុន្តែគ្រួសារហ្នឹងមានកូនស្រីពីរនាក់ ម្ដាយមួយ និងកូនប្រុសបីនាក់។ ហើយគ្រួសារមួយទៀត បងម៉ាក់ អាក្អែលហ្នឹង ប្រពន្ធបង សាអុន ហ្នឹង – បងសាអុន ហ្នឹង គេយកទៅសម្លាប់ថ្ងៃជាមួយគ្នាបង ចាន់ ថន ខ្ញុំនៅទួលស្នួ។ ហើយប្រពន្ធគាត់ប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃខ្ញុំអត់ចាំទេណា គ្រាន់តែថាគេលួចខ្សឹបប្រាប់គ្នាថា “ហ៊ឺ! ប្រពន្ធ សាអុន គេយកទៅទៀតហើយ”។ គាត់មានកូនពីរនាក់ កូនប្រុសមួយ ស្រីមួយ។

[០៩:៤៧:៣៦]

**ស៖** អ៊ីចឹងតាមនេះ គឺគ្រួសារទី១ហ្នឹង គឺសមាជិកប្រាំមួយនាក់ ហើយគ្រួសារមួយទៀតគឺសមាជិកបីនាក់។ ត្រឹមត្រូវដែរទេ លោកស្រី?

**ឆ៖** ចាស គ្រួសារ ស័ក្ដិ៤ ចុន មានប្រាំមួយនាក់ ហើយនិងបងមាក់ អាក្អែល ហ្នឹង មានបងស្រីហ្នឹងដែលជនជាតិវៀតណាមហ្នឹង ហើយកូនគាត់ប្រុសមួយ ស្រីមួយ បីនាក់។

**ស៖** អរគុណលោកស្រី។ ឥឡូវបែរមកនិយាយអំពីបងប្រុសរបស់លោកស្រីវិញម្ដង។ លោកស្រីបានមានប្រសាសន៍ថា លោកស្រីមានបងប្រុសឈ្មោះ ជ្រូក ចាន់ថន និង ចូក ចន្ថា។ តើនៅក្នុងរបបលន់ នល់ ហ្នឹង តើបងប្រុសរបស់លោកស្រីហ្នឹង គាត់នៅកន្លែងណាដែរ?

**ឆ៖** បងប្រុសទី១ ជ្រូក ចាន់ថន ហ្នឹងគាត់ធ្វើប៉ូលិសនៅភ្នំពេញ ដល់ពេល បងចន្ថា ហ្នឹងគាត់

ធ្វើទាហាននៅស្វាយរៀង គាត់បង្ហាត់សេអ៊ី។ ប៉ុន្តែដល់ពេល មិនដឹងគាត់មានការណ៍អី គាត់ឡើងកប៉ាល់ហោះមកភ្នំពេញ។ មកភ្នំពេញហើយ ដល់ពេលថ្ងៃ១៧ មេសា គាត់រំដោះទៅ បានគាត់ទៅភូមិស្រុកវិញ។ គាត់ទៅនៅខាងប្រពន្ធគាត់នៅបាសាក់ ហ្នឹងបង ជ្រូក ចន្លា នៅភូមិសាលាបង្រៀន ភូមិបាយ៉ាប ឃុំបាសាក់ ហ្នឹងបង ជ្រូក ចន្លា។

**ស៖** អរគុណលោកស្រី។ លោកស្រីបានមានប្រសាសន៍ថា ជ្រូក ចាន់ថន ហ្នឹងគាត់គឺជាទាហាន ហើយ ជ្រូក ចន្លា -- អ៎! ជាប៉ូលិស ហើយ ជ្រូក ចន្លា ហ្នឹងគឺជាទាហាន។ តើនៅពេលដែលគាត់ត្រឡប់មកដល់ភូមិកំណើតក្រោយឆ្នាំ៧៥ហ្នឹង តើពេលដែលគាត់មកដល់ហ្នឹង តើពួកខ្មែរក្រហមមានព្យាយាមកំណត់អត្តសញ្ញាណគ្រួសារគាត់ថា ជាទាហាន ឬក៏ជាប៉ូលិសដែរឬទេ?

**ឆ៖** គេស្រង់ស្ថិតិ គេសួរទៅ យើងប្រាប់គេថា គាត់ធ្លាប់ធ្វើទាហាន ធ្វើប៉ូលិសអីចឹងទៅ ដល់មកបានប្រហែលជាកន្លះខែ ឬមួយក៏២០ថ្ងៃ ខ្ញុំអត់ចាំច្បាស់ទេ គេឲ្យគាត់ទៅរៀនសូត្រហ្នឹង បង ចាន់ថន តែបង ចន្លា គាត់ទៅតាមប្រពន្ធគាត់នៅឯបាសាក់ នៅឃុំបាសាក់។

[០៩:៥០:៣២]

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំសូមទាញលោកស្រីត្រឡប់មកក្រោយបន្តិចអំមិញ ខ្ញុំភ្លេចសំណួរមួយ។ ដោយសារតែលោកស្រីមានប្រសាសន៍ថា នៅពេលដែលសម្លាប់គ្រួសារជនជាតិវៀតណាមពីរគ្រួសារហ្នឹង គឺលោកស្រីអត់បានដឹងទេ គឺឮគេប្រាប់។ អីចឹងទេលោកស្រី?

**ឆ៖** ចាស ព្រោះអីនៅក្នុងភូមិ កាលណាមានគេយកអ្នកទៅសម្លាប់អីចឹង គេខ្សឹបប្រាប់គ្នា ថាគ្រួសារហ្នឹង គេយកទៅហើយ គេខ្សឹបប្រាប់គ្នាអីចឹង គេមិនហ៊ាននិយាយឮទេ ខ្សឹបៗប្រាប់គ្នាតៗគ្នា។

**ស៖** អរគុណលោកស្រី។ អីចឹងចាប់តាំងពីពេលដែលគេប្រាប់លោកស្រីហ្នឹងមករហូតដល់ការដួលរលំរបស់របបខ្មែរក្រហម ហើយមកទល់បច្ចុប្បន្ននេះ តើលោកស្រីមានធ្លាប់បានទទួលដំណឹងអំពីក្រុមគ្រួសារទាំងពីរ ឬអំពីសមាជិកក្រុមគ្រួសារទាំងពីរ ឬក៏ធ្លាប់ជួបនៅកន្លែងណាដែរ លោកស្រីមានធ្លាប់ដែរទេ?

**ឆ៖** អរគុណ។ បានអីជួប បើគេយកទៅវ៉ៃចោលបាត់អស់ហើយ គាត់ស្លាប់អស់ហើយ មានស្អីជួបមកទៀត បើស្លាប់សូន្យឈឹងអស់ហើយ។

**ស៖** តើនៅក្នុងអំឡុងរបបខ្មែរក្រហមហ្នឹង មានពេលណាមួយដែលលោកស្រីធ្លាប់ដឹងអំពីមានកិច្ចប្រជុំនៅក្នុងភូមិហ្នឹង ដែលគេពិភាក្សាអំពីជនជាតិវៀតណាមដែរឬទេ?

E1/394.1/Old-1

**ឆ៖** ពេលគេប្រជុំហ្នឹង គេប្រធានសហករណ៍ គឺវាបានដឹងច្បាស់ហើយថា គ្រួសារណាវៀត-ណាម គ្រួសារណាមិនមែនវៀតណាម គឺវាដឹងច្បាស់អ៊ីចឹង វាកំណត់សម្គាល់អ៊ីចឹង វាស្គាល់ដឹងច្បាស់ហើយ ព្រោះអីដូចគ្រួសារខ្ញុំអ៊ីចឹង គេដឹងថាជីតាខ្ញុំអ៊ីចឹង វៀតណាមអ៊ីចឹង គេដឹង។ បើអ៊ីចឹង គេមិនបាច់សួរអីទៀត គេដឹង គេស្គាល់ហើយ។

**សៈ** អរគុណលោកស្រី។ ឥឡូវខ្ញុំបែរមកនិយាយអំពីបងស្រីរបស់លោកស្រីម្តង ដែលគាត់ឈ្មោះថា លោកស្រីបានមានប្រសាសន៍ថាឈ្មោះ ជ្រូក ធីតា ហ្នឹង។ តើនៅពេលហ្នឹង នៅក្នុងរបបខ្មែរក្រហមហ្នឹង គាត់អាយុប៉ុន្មានដែរ លោកស្រីអាចដឹងទេ?

[០៩:៥៣:១៩]

**ឆ៖** បើតាមខ្ញុំគិតនោះ គាត់ខ្ទង់២០ឡើង ព្រោះគាត់ឆ្នាំរក កាលហ្នឹង។ ខ្ញុំមិនសូវដឹងដែរ គាត់អាយុប្រហែល២០ជាង ២១-២២ អីហ្នឹង បងស្រី ធីតា។ តែ២០ឆ្នាំឡើង។

**សៈ** តើគាត់រៀបការនៅពេលណាដែរ បងស្រីរបស់លោកស្រីនោះ ជ្រូក ធីតា ហ្នឹង?

**ឆ៖** កាលដែលខ្ញុំចាំ គាត់ការឆ្នាំ១៩៧៨ ព្រោះក្រោយពីពេលដែលប៉ាខ្ញុំស្លាប់ហើយ បងប្រុសខ្ញុំស្លាប់អស់ហើយ បានគេបង្ខំឱ្យគាត់រៀបការ។

**សៈ** អម្បាញ់មិញ លោកស្រីបានមានប្រសាសន៍ថា គេបង្ខំឱ្យគាត់រៀបការ។ អ៊ីចឹងការរៀបការរបស់គាត់ មិនមែនជាការស្ម័គ្រចិត្ត ឬក៏ជាការជ្រើសរើសរបស់គាត់ទេ ឬយ៉ាងណា?

**ឆ៖** អត់ទេ គាត់រៀបការហ្នឹងបង្ខំ គេស្នើគាត់ហ្នឹង ខាងប្រុសគេស្រឡាញ់គាត់ ប៉ុន្តែគាត់ៗអត់ស្រឡាញ់គេផង ប៉ុន្តែគាត់ខ្លាចគេយកទៅវៃចោល គាត់ព្រមរៀបការទៅ។

**សៈ** តើលោកស្រីមានបានចូលរួមនៅក្នុងពិធីការរបស់បងស្រីរបស់លោកស្រីដែរទេ?

**ឆ៖** ចាស បាន ខ្ញុំបានទៅចូលរួម។ ពេលដែលមុនទៅចូលរួម ខ្ញុំថាខ្ញុំមិនទៅចូលរួមទេ ព្រោះអីខ្ញុំស្អប់ ខ្ញុំមិនចង់ទៅ។ ដល់ពេលហើយម្តាយខ្ញុំគាត់យំអង្វរខ្ញុំថា៖ "ទៅៗកូនអើយ ឱ្យគាត់រៀបការទៅទៅចូលរួមទៅ ក្រែងលោគេយកទៅវាយចោលទៀត។" ខ្ញុំក៏ទៅៗ ចូលរួមបានចូលរួម។ ការបួនគូ នៅអង្គរុន។

**សៈ** តើនៅពេលហ្នឹង លោកស្រីមានឃើញកម្មាភិបាលខ្មែរក្រហមណា ដែលចូលរួមនៅក្នុងការរៀបការនោះដែរឬទេ? មានបានឃើញទេ?

[០៩:៥៥:៥២]

**ឆ៖** ចាស ឃើញ ប៉ុន្តែខ្ញុំអត់ចំណាំគេទេ។ អត់ស្គាល់គេ ដឹងអ្នកណាអ្នកណេី គ្រាន់ថា ហ្នឹងគេជាប្រធានសហករណ៍ ឬមួយក៏ប្រធានអីមួយ បានគេឡើងឲ្យគាត់ប្តេជ្ញាអីអ៊ីចឹង។ គ្រាន់តែដឹងអ៊ីចឹង ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះគេ ថាគេហ្នឹងជាអ្នកណាៗ គ្រាន់ដឹងថា មានកម្មាភិបាលគេមកឲ្យគាត់ប្តេជ្ញា។ គេអង្គុយអ៊ីចឹងទៅ ឲ្យយើងឡើងចាប់ដៃគ្នាប្តេជ្ញានៅនឹងមុខគេហ្នឹង។ គ្រាន់តែដឹងថាកម្មាភិបាល ជួរភូមិ ជួរឃុំ ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះគេទេ។

[០៩:៥៦:៣១]

**ស៖** ខ្ញុំមានមួយសំណួរចុងក្រោយទៀត ចង់សួរពាក់ព័ន្ធជាមួយនឹងអារម្មណ៍របស់លោកស្រី។ អម្បាញ់មិញលោកស្រីមានប្រសាសន៍ថា លោកស្រីស្អប់ អត់ចង់ចូលរួមពិធីរៀបការរបស់បងស្រីលោកស្រីទេ។ តើពិធីរៀបការនុ៎ង វាប៉ះពាល់អារម្មណ៍អ្វីខ្លះដល់លោកស្រី បានជាលោកស្រីស្អប់?

**ឆ៖** ដូចខ្ញុំមិនចូលចិត្ត ដូចថា រៀបការស្ងើស្ងាត់ៗ ចាប់ដៃគ្នាប្តេជ្ញាស្ងាត់ៗ ហើយដូចគ្មានរៀបចំកម្មវិធីអី ហូបចុកអីផង បើខ្ញុំទៅរៀបការបងខ្ញុំ មកវិញ រោងបាយគេឲ្យហូបបាយបុកអំបិលហ្នឹង។

**ស៖** ខ្ញុំសូមដកស្រង់ឯកសារមួយ គឺឯកសារលេខ D109/5/1.2.1, ERN ជាភាសាអង់គ្លេស 00621378, ERN ជាភាសាបារាំង 01204939, ERN ជាភាសាខ្មែរ 00621381។ លោកស្រីបានប្រសាសន៍ -- 80 រហូតដល់ 81 -- លោកស្រីបានមានប្រសាសន៍ថា "បងស្រីធំរបស់ខ្ញុំ ឈ្មោះ ជ្រូក ធីតា ដែលមានអាយុ២០ឆ្នាំ ត្រូវបង្ខំឲ្យរៀបការជាមួយមនុស្សប្រុសម្នាក់ដែលគាត់មិនធ្លាប់ស្គាល់ នៅចុងឆ្នាំ៧៨។ ខ្ញុំចូលរួមក្នុងពិធីការនោះ ពេលនោះ ខ្ញុំឃើញមានគូស្រករតែប្អូនគូប៉ុណ្ណោះរួមទាំងបងស្រី ត្រូវបានប្រមូលផ្តុំរៀបការនៅក្នុងសហករណ៍អង្គរុន ស្ថិតនៅក្នុងកំពង់ចម្លង ស្រុកស្វាយជ្រំ។ ពិធីរៀបការនោះ បានប្រព្រឹត្តទៅនៅម៉ោងដប់ព្រឹក។ ខ្ញុំមានការឈឺចាប់ នៅពេលដែលខ្ញុំបានឃើញបងស្រីធំខ្ញុំ ត្រូវរៀបការដោយបង្ខំ ជាមួយនឹងមនុស្សប្រុសម្នាក់ដែលគាត់មិនស្រឡាញ់។ ហេតុការណ៍នេះ បានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ការយល់ឃើញរបស់ខ្ញុំចំពោះការរៀបការនេះ។ ខ្ញុំគិតថា ថ្ងៃមួយវាសនា ខ្ញុំក៏នឹងទៅរៀបការតាមរបៀបដូចនេះដែរ ព្រោះពេលនោះ ខ្ញុំមានអាយុ១៦ឆ្នាំហើយ។" តើអ្វីដែលខ្ញុំអាននេះ អាចរំឭកការចងចាំលោកស្រីបានដែរឬទេ?

**ឆ៖** ចាស ខ្ញុំធ្លាប់គិតដែរ គិតថា ថ្ងៃណាមួយគេបង្ខំឲ្យខ្ញុំរៀបការជាមួយនឹងមនុស្សដែលខ្ញុំមិនស្រឡាញ់ដូចបងស្រីខ្ញុំដែរ ខ្ញុំគិត។ នៅភូមិអង្គរុន ភូមិដែលគាត់រៀបការនុ៎ង ភូមិអង្គរុន។

[០៩:៥៩:២៩]

**លោក សេង លាង៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមប្រគល់វេទិកានេះ ជូនទៅអង្គជំនុំជម្រះវិញ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់ទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គសវនាការ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី -- លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិនៅក្នុងក្រុមការពារក្តីលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនចង់សួរលោកស្រី។ ទី១ ទាក់ទងនឹងបងប្រុសទាំងពីររបស់លោកស្រី។ កាលពីម្សិលមិញនៅវេលាម៉ោងប្រហែលជា ០៣:៣៧នាទី លោកស្រីបានឆ្លើយថា នៅពេលធ្វើដំណើរមកបានប្រហែលជាកន្លះខែ ទៅ២០ថ្ងៃ (ខ្ញុំមិនចាំទេ) កាលហ្នឹង ក៏បងប្រុសខ្ញុំពីរនាក់ទៀត ជម្លៀសពីភ្នំពេញទៅ គាត់ជាទាហាននិងប៉ូលិស។ ពេលទៅដល់បានប្រហែលជាកន្លះខែ ឬ២០ថ្ងៃដែរ ពួកគេបាននាំគាត់ទៅរៀនសូត្រ យកទៅរៀនសូត្រ។ ពេលដែលយកទៅរៀនសូត្រហ្នឹង បានប្រហែលជាប្រាំទៅប្រាំមួយខែ ក៏ដោះលែងមកវិញ ឱ្យមកធ្វើការជាទម្ងន់នៅក្នុងភូមិ។ អ៊ីចឹងខ្ញុំចង់-- ហើយមិញនេះ លោកស្រីបានថ្លែងថា មូលហេតុដែលគេដឹងថា គាត់ជាទាហាន ប៉ូលិសដោយតាមរយៈការស្រង់ស្ថិតិ។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំចង់សួរថា តើបងទាំងពីររបស់លោកស្រីហ្នឹង ក្រោយពីបន្ទាប់ពីបានស្រង់ស្ថិតិហើយនោះ គេឱ្យគាត់ទៅរៀនសូត្រទាំងពីរនាក់ ឬក៏ទៅរៀនសូត្រតែម្នាក់ណា?

**លោកស្រី សៀង ចានថី៖**

**ឆ៖** ដែលនៅភូមិឫស្សីព្រៃហ្នឹង គេយកបងប្រុសខ្ញុំ បងចាន់ថន ឱ្យទៅរៀនសូត្រ ព្រោះបងចន្ថា គាត់មកដល់ស្នាក់នៅបានដូចខ្ញុំរៀបរាប់អ៊ីចឹង បានប៉ុណ្ណឹង គាត់ទៅខាងប្រពន្ធគាត់នៅឯខាងបាសាក់ឯណោះ តែបងចាន់ថន គេនាំយកទៅរៀនសូត្រ។

[១០:០២:០៦]

**ស៖** បាទ អរគុណ។ ចុះបងចន្ថា បងស្រីរបស់បងឈ្មោះ ចន្ថា ហ្នឹង តើលោកស្រីកត់សម្គាល់ ឬក៏លោកស្រីមានបានដឹងទេថា មូលហេតុអីបានជាគេមិនឲ្យគាត់ទៅរៀនសូត្រ?

**ឆ៖** ព្រោះអីគាត់ទៅនៅខាងប្រពន្ធគាត់ ដល់ពេលអីចឹងដាច់ខ្សែរយៈគ្នា។

**ស៖** តើរវាងបងចន្ថា និងបងចាន់ថន ហ្នឹង តើអ្នកណាដែលត្រូវបានគេយកទៅសម្លាប់មុន?

**ឆ៖** គឺ បងចាន់ថន គេយកទៅសម្លាប់មុន ហើយបានដឹងដំណឹងតាមគេ ដែលគេបានឃើញ ហ្នឹង ដឹងថា បងចន្ថា ក៏ស្លាប់ដែរ ក៏គេសម្លាប់ដែរ សម្លាប់នៅកន្លែងគាប់ជាប់គុកហ្នឹង។

**ស៖** តើលោកស្រីចាំបានទេ បងរបស់លោកស្រីឈ្មោះ ចាន់ថន ហ្នឹងគេយកទៅសម្លាប់នៅក្នុង ឆ្នាំណាដែរ?

**ឆ៖** តាមខ្ញុំចាំ គឺនៅក្នុងខែច្រូតវាចុងឆ្នាំ១៩៧៧ ហើយ ក្នុងខែច្រូត គេយកទៅសម្លាប់នៅទួល ស្លួន។ ទួលស្លួនហ្នឹង ខាងកើតវត្តតាជ័យ។

**ស៖** មុននេះលោកស្រីបានថ្លែងថា មូលហេតុដែលគេយកបងលោកស្រីឈ្មោះ ចាន់ថន ទៅ សម្លាប់ដោយលោកស្រីបានស្តាប់ឮ ដោយសារគាត់ខ្ជិលធ្វើការងារ ហើយលោកស្រីថា ដោយសារគាត់ ឈឺ។ ចុះចំពោះបងប្រុសរបស់លោកស្រីឈ្មោះ ចន្ថា វិញ តើគាត់មានកំហុសអីដែរបានគេយកគាត់ទៅ សម្លាប់?

**ឆ៖** បងប្រុសចាន់ថន ខ្ញុំដែលគេជំនុំគ្នាថាខ្ជិលនោះ កាលនោះនៅខែវស្សាទេ។ គេអត់ទាន់យក ទៅណាទេ គ្រាន់តែគេថា ទុកក៏មិនចំណេញ ដកចេញក៏មិនខាត ប៉ុន្តែគេទុកគាត់ប្រើធ្វើការសិន។ ដល់ ពេលខែច្រូតចុងឆ្នាំ១៩៧៧ បានគេយកគាត់ទៅ។ ហើយ បងចន្ថា ហ្នឹងគាត់នៅភូមិឃុំប្រពន្ធគាត់រស់នៅ ហ្នឹងគឺគាត់ឡើងកាប់ដើមជ្រៃដែលនៅលើដើមត្នោតហ្នឹង យកមកធ្វើទ្រើងននោង ហើយនិងគាត់អត់ចេះ ភ្ជួរ ភ្ជួរទៅគោវាផ្អើលទៅ មុតជើងគោ។ គេថាយើងបំផ្លិចបំផ្លាញរបស់អង្គការ ប្រឆាំងអង្គការ។ រឿង ប៉ុណ្ណឹង ដែលខ្ញុំដឹង។

[១០:០៥:១៥]

**ស៖** អីចឹងមានន័យថា ការសម្លាប់បងរបស់លោកស្រីទាំងពីរ មិនពាក់ព័ន្ធនឹងការអតីតភាព ការងាររបស់គាត់មួយជាប៉ូលិស ហើយមួយទៀតជាទាហាន លន់ នល់ ទេ។ បើខ្ញុំសង្ខេបអីចឹង តើត្រឹម ត្រូវទេបាទ?

**ឆ៖** ចាស គឺទាក់ទង ព្រោះអីវាដឹងថាបងប្រុសខ្ញុំធ្វើប៉ូលិសហើយ ហើយវាដឹងថាបងខ្ញុំធ្វើទាហាន ទាក់ទង ព្រោះកំហុសកាលណាមានបន្តិច គឺវាផ្ដួបចូលគ្នាតែម្ដងសម័យហ្នឹង ព្រោះអីអ្នកដែលគេយកទៅសម្លាប់ជាមួយបងខ្ញុំ បងចាន់ថន ហ្នឹង គាត់សុទ្ធតែទាហានទាំងអស់ហ្នឹង។

**ស៖** កាលដូចខ្ញុំបានរំឭកមិញ ម្សិលមិញលោកស្រីថា បងចាន់ថន របស់លោកស្រីហ្នឹង គឺក្រៅពីស្រង់ស្ថិតិហើយ គាត់ជាប៉ូលិស អ៊ីចឹងគេឲ្យគាត់ទៅរៀនប្រាំមួយខែ ហើយគេលែងគាត់មកវិញ ឲ្យមកធ្វើការធម្មតា។ អ៊ីចឹងបើយើងមើល ប៉ាន់ប្រមាណប្រាំមួយខែ អ៊ីចឹងខ្ទង់ខែ១០ ឆ្នាំ៧៥។ ហើយដល់ឆ្នាំ៧៧ បានគេយកគាត់ទៅសម្លាប់ ហើយលោកស្រីអះអាងអំមិញថា ការយកគាត់ទៅសម្លាប់នេះ គឺដោយសារធ្លាប់ពីខែវស្សាហ្នឹងគឺខែស្ទូងហ្នឹង គឺគេថាគាត់ខ្ជិលការងារ។ នេះចំណុចមួយ។ ចំណុចទី២ បង ចំពោះ បងចន្ថា របស់លោកស្រីគឺលោកស្រីអះអាងថា ដោយសារគាត់មានកំហុស គឺគាត់បានកាប់ដើមជ្រៃ ហើយនិងបានភ្ជួរមុតជើងគោ។ អ៊ីចឹងហើយបានខ្ញុំសួរថា តើទាំងពីរនេះ ជាកំហុសដែលលោកស្រី ដែលគេចាប់បងរបស់លោកស្រីទៅហ្នឹង គឺជាកំហុសដែលទាក់ទងនឹងការប្រព្រឹត្តរបស់គាត់នៅកាប់ដើមជ្រៃ ហើយនិងភ្ជួរមុតជើងគោ ឬក៏ទាក់ទងនឹងប៉ូលិស ឬក៏ទាហាន?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិ!

[១០:០៧:៣៦]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សំណួរដែលសួរនេះហាក់ដូចជាលក្ខណៈច្រំដែល ហើយការស្រង់ ការសង្ខេបនៃខ្លឹមសារដែលដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងនេះ ក៏មិនគ្រប់លក្ខណៈដែរ។ អម្បាញ់មិញ ដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយថា ការដែលគេយកបងរបស់គាត់ទៅសម្លាប់គឺផ្ដួបទៅនឹងមូលហេតុដែលថា បងរបស់គាត់ជាប៉ូលិសនិងជាទាហានផងដែរ។ ដូច្នេះ ការស្រង់ក៏គួរតែស្រង់ឲ្យបានពេញលេញ។ បាទ សូមអរគុណលោកប្រធាន។

**លោក លីវ សុវណ្ណា៖**

សូមគោរពលោកប្រធាន ដោយសារពីម្សិលមិញ ដូចខ្ញុំបាទបានស្រង់ពីប្រតិចារឹក កាលពីម្សិលមិញគឺគាត់ថា បងរបស់គាត់ហ្នឹងគឺបានរៀនសូត្រហើយ គេឲ្យមកផ្ទះវិញ។ ហើយគាត់ក៏ថ្លែងអំមិញហ្នឹង គាត់ថាវាអត់ -- ខ្ញុំសួរថាមូលហេតុអី ដែលគេចាប់បងគាត់យកទៅហ្នឹង? គាត់ថ្លែងថា គេចាប់ទៅ

គឺទាក់ទងនឹងកាប់ដើមជ្រៃ ហើយនិងគាត់ភ្លូរ គាត់អត់ចេះភ្លូរ គាត់ភ្លូរមុតជើងគោ។ អ៊ីចឹងហើយបានសំណួរខ្ញុំសួរថា តើវាមានទំនាក់ទំនងយ៉ាងណាដែលចំពោះការប្រព្រឹត្តចំពោះអតីតមន្ត្រីរាជការ រដ្ឋការសម័យ លន់ នល់ ក៏ដូចជាទាហាន លន់ នល់ បាទ។

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយរួចហើយ អំមិញថាវាមានទំនាក់ទំនងគ្នាទាំងពីរ ដោយសារបញ្ហាអតីតជាអ្នកទាហានលន់ នល់ ផង ជាប៉ូលិសជំនាន់លន់ នល់ ផង ហើយគាត់មានកំហុស។ គេចាប់កំហុសគាត់ អ៊ីចឹងបូកទាំងពីរហ្នឹងបានជាគេយកគាត់ទៅសម្លាប់។ ដូច្នេះសំណួរហ្នឹង គាត់ឆ្លើយរួចហើយ។ តទៅមុខទៀត!

**លោក លីវ សុវណ្ណា៖**

អ៊ីចឹងបាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** អ៊ីចឹងលោកស្រីថា វាមានទំនាក់ទំនងគ្នា។ ហេតុអីបានជាគេឲ្យគាត់រៀនសូត្រហើយ រឿងដែលគេក្តាប់បានប្រវត្តិរូបគាត់តាំងពីឆ្នាំ៧៥ ពេលជម្លៀសទៅភ្នំ ហើយរហូតដល់ឆ្នាំ៧៧ បានជាគេយកទៅសម្លាប់? ដូច្នេះ ហេតុអ្វីបានជាលោកស្រីភ្ជាប់ថា វាមានទំនាក់ទំនងគ្នារវាងអតីតការងាររបស់គាត់ ហើយនិងកំហុសរបស់គាត់។

[១០:១០:០២]

**លោកស្រី សៀង ចាន់ថី៖**

**ឆ៖** ខ្ញុំសូមអរគុណ ហើយខ្ញុំសូមឆ្លើយ គឺថាកំហុសរបស់គាត់ ហើយនិងអតីតរបស់គាត់ ដល់អ៊ីចឹងទៅពេលដែលគេជ្រើសរើសក្នុងភូមិហ្នឹង គេថាអ្នកដែលមានកំហុសច្រើន និងអតីតធ្វើអី ហ្នឹងគេយកទៅសម្លាប់ទៅ។ គេជ្រើសរើសអ៊ីចឹង គេចុចឈ្មោះអ៊ីចឹង។

**ស៖** ហេតុអ្វីបានជាលោកដឹងថា អ្នកដែលជ្រើសរើស គេចុចឈ្មោះបែបហ្នឹង?

**ឆ៖** ព្រោះអីបើសិនជាគេយកទៅសម្លាប់ ទាហាននៅក្នុងភូមិហ្នឹងច្រើនណាស់ គ្រូបង្រៀនក៏មាន ទាហានក៏មាន អ្នកនិន្នាការមានច្រើន តែគេ គេត្រូវគេចុចយកតែមួយៗ អ្នកណាដែលត្រូវគេយកទៅវៃចោល។ គេមិនយកទាំងអស់ណា។ អ៊ីចឹងបានខ្ញុំថា សន្និដ្ឋានថា គេចុចឈ្មោះហើយ បានគេយកតែបងខ្ញុំ ហើយនិងពូៗបីនាក់ទៀត ទៅថ្ងៃជាមួយគ្នាគាត់ទុំង ទាំងអស់ប្អូននាក់ទុំង។ ព្រោះទាហាននៅក្នុង

ភូមិច្រើននាក់ណាស់។

**ស៖** អ៊ីចឹងលោកស្រីតាមការសង្កេតរបស់លោកស្រី ទាហាននៅក្នុងភូមិរបស់លោកស្រីច្រើនហ្នឹង តើទាហានសម័យណាដែរ?

**ឆ៖** បើតាមដែលខ្ញុំដឹង ទាហានសម័យណា មានតែទាហានសម័យ លន់ នល់ ហ្នឹង បើខ្ញុំកើតតែជំនាន់ លន់ នល់ ទាន់ជំនាន់ លន់ នល់ ខ្ញុំនៅស្ទើរនៅតូចដែរ។

**ស៖** អ៊ីចឹងកម្មាភិបាលដែលដឹកនាំនៅក្នុងសហករណ៍ ក៏ដូចជាឃុំរបស់លោកស្រី គេដឹងថាអ្នកទាំងអស់ហ្នឹងជាទាហាន លន់ នល់ ដែរទេ?

**ឆ៖** គេដឹង ព្រោះគេស្រង់ស្ថិតិ ប៉ុន្តែអ្នកណាសកម្មការងារអ៊ីចឹង គេទុកយកទៅក្រោយទៅ អ្នកណាដូចថាដូចបងខ្ញុំអ៊ីចឹង គាត់ឈឺច្រើន គាត់មានកំហុសអ៊ីចឹង ហ្នឹងអ្នកហ្នឹងគេចុចឈ្មោះទៅមុនហើយ។ បើគេថាហើយ ទុកក៏មិនចំណេញ ដកចេញក៏មិនខាត មានតែគេយកគាត់ទៅ ទុកអ្នកដែលធ្វើការសកម្មនៅក្រោយទៅ។

[១០:១២:៤០]

**ស៖** អ៊ីចឹងលោកស្រីមានប្រសាសន៍អំមិញថា ទាហាននៅសម័យ លន់ នល់ នៅរស់ច្រើនហ្នឹង តើគាត់ក្រោយ៧៩ គាត់នៅរស់ទេបាទ?

**ឆ៖** មាន គាត់នៅច្រើន ប៉ុន្តែឥឡូវមិនដឹងជាគាត់ទៅណាអស់ ព្រោះឥឡូវហ្នឹង គេចេញទៅរកស៊ីស្រុកឆ្ងាយៗ នៅតំបន់ឆ្ងាយៗអ៊ីចឹងទៅ ខ្ញុំមិនស្គាល់គេអស់ទេ ព្រោះគាត់ចាស់ៗ ហើយខ្ញុំនៅក្មេងស្គាល់តែមុខគេមួយភ្លែតៗហ្នឹង ជំនាន់នុំងមានទៅបានស្គាល់អីជាក់លាក់ រាប់អានអីនេះគ្នា បើរវល់តែធ្វើការរៀងៗខ្លួន គ្រាន់តែដឹង ឃើញៗ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ សូមជម្រាបសួរលោកស្រីដើមបណ្តឹងម្តងទៀត។ អំមិញយើងបានពិភាក្សាគ្នាករណីដែលអតីតអ្នករាជការ។ អ៊ីចឹងមុនហ្នឹងលោកស្រីបានឆ្លើយថា ក្រៅពីទាហាន មានគ្រូបង្រៀន។ ចុះក្រៅពីគ្រូបង្រៀន តើមានអតីតមន្ត្រីរាជការណាទៀត ដែលគាត់ គេនឹងត្រូវបានគេយកទៅសម្លាប់នោះ?

**លោកស្រី សៀង ចាន់ថី៖**

**ឆ៖** ខ្ញុំដឹងមិនអស់ទេ ខ្ញុំដឹងប៉ុន្មាន ខ្ញុំឆ្លើយប៉ុណ្ណឹង ព្រោះអីខ្ញុំនៅក្មេងដែរ កាលនុ៎ង។

**ស៖** បាទ សូមអរគុណ។ តាមការកត់សម្គាល់របស់លោកស្រី តើអតីតទាហានលន់ នល់ ទាំងអស់នោះ ត្រូវទៅចូលរៀន -- ទៅរៀនសូត្រជាមួយនឹងបងរបស់លោកស្រីឈ្មោះ ចាន់ថន ដែរឬទេ?

**ឆ៖** ចាស បានចូលទៅរៀនសូត្រ ហើយមកវិញដូចតែបងខ្ញុំដែរហ្នឹង។

**ស៖** មុនពេលគេឲ្យទៅរៀនសូត្រ តើលោកស្រីមានចាំបានថា មានអង្គប្រជុំណាមួយដែលគេនិយាយថា ការសន្តោស ឬក៏ការយកអតីតមន្ត្រីរាជការសម័យ លន់ នល់ ហ្នឹង ទៅរៀនសូត្រ ទៅអប់រំហ្នឹង តើមានដែលគេបានប្រជុំអីទេ លោកស្រី?

**ឆ៖** ខ្ញុំអត់បានដឹងទេ ព្រោះអីខ្ញុំនៅតូចដែរ ហើយខ្ញុំគ្រាន់តែមកផ្ទះវិញ មកពីរកម្ហូប រកត្រីអីអ៊ីចឹងទៅ បាត់បងខ្ញុំ ខ្ញុំសួរទៅម្តាយ ប៉ាខ្ញុំប្រាប់ថា គេឲ្យទៅរៀនសូត្រ តែប៉ុណ្ណឹង។

[១០:៣៥:៥៤]

**សៈ** បាទ សូមអរគុណលោកស្រី។ ឥឡូវយើងបែរមកករណីគ្រួសារវៀតណាមពីគ្រួសារ។ លោកស្រីបានមានប្រសាសន៍ថា គ្រួសារមួយ គឺស័ក្តិ៤ថុន មានសមាជិកប្រាំមួយនាក់ កូនប្អូន ប្ដីប្រពន្ធពីរ។ អ៊ីចឹងខ្ញុំ -- សំណួរខ្ញុំសួរថា តើគ្រួសារឈ្មោះ ថុន ហ្នឹង ប្ដី ឬប្រពន្ធដែលជាជនជាតិវៀតណាម ឬក៏ទាំងពីរនាក់ប្ដីប្រពន្ធ ជាជនជាតិវៀតណាម?

**ឆៈ** ខ្ញុំសូមឆ្លើយ។ ប្ដីហ្នឹង ខ្ញុំមិនបានស្គាល់ទេ ព្រោះអីគ្រាន់តែឮថា គាត់ហ្នឹងជាប្រពន្ធស័ក្តិ៤ថុន មិនដែលឃើញប្ដីទេ ខ្ញុំមិនបាននិយាយប្ដីទេ ព្រោះអីក្នុងគ្រួសារគាត់ប្រាំមួយនាក់ហ្នឹង គាត់មានម្ដាយ និងកូនប្រាំនាក់។ ម្ដាយជាជនជាតិវៀតណាម។ ស័ក្តិ៤ថុនហ្នឹង ខ្ញុំអត់ដែលស្គាល់ គ្រាន់តែថា ឮឈ្មោះ ថាគាត់ហ្នឹងជាប្រពន្ធស័ក្តិ៤ថុន។

**សៈ** ចុះគ្រួសារវៀតណាមមួយទៀត ដែលលោកស្រីថា ឈ្មោះ ថុន ហ្នឹង តើប្ដី -- ថាឈ្មោះ អ៊ុន គ្រួសារវៀតណាមួយទៀតនុ៎ង ប្ដី ឬប្រពន្ធជាវៀតណាម ឬក៏ទាំងពីរនាក់ប្ដីប្រពន្ធ ជាវៀតណាម?

**ឆៈ** ចាស ប្រពន្ធគាត់ជាជនជាតិវៀតណាម។

**សៈ** ចុះនៅពេលដែលគេយកទៅសម្លាប់នោះ គេមានយកប្ដីគាត់ទៅដែរឬក៏អត់?

**ឆៈ** គេយកទៅសម្លាប់ ប្ដីគាត់គេយកទៅសម្លាប់ថ្ងៃជាមួយបងខ្ញុំ បងប្រុស ចាន់ថន ហ្នឹង។ បានក្រោយមក ប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃ ខ្ញុំអត់ចាំ អត់ដឹងទេណា បានគេយកប្រពន្ធ ហើយនិងកូនទៅតាមក្រោយ ថាឲ្យទៅតាមប្ដី។ តែប្ដី គេយកទៅសម្លាប់ចោលជាមួយបងខ្ញុំ ថ្ងៃជាមួយបងខ្ញុំ បង ចាន់ថន ហ្នឹង។

[១០:៣៨:៥០]

**សៈ** ចុះគ្រួសាររបស់ស័ក្តិ៤ថុន ហ្នឹងវិញ កូនៗរបស់គាត់មានជោគវាសនាម៉េចដែរ?

**ឆៈ** គឺគាត់ស្លាប់ទាំងអស់គ្នាហ្នឹង។ គេយកទៅវៃចោលទាំងអស់គ្នាហ្នឹង ទាំងគ្រួសារហ្នឹង ស្លាប់ទាំងអស់ហ្នឹង មានបានរស់រានមានជីវិតទេ ស្លាប់ទាំងអស់ហ្នឹង។ កូនស្រីត្រូវគេរំលោភទាល់តែស្លាប់ ហើយកូនប្រុសបីនាក់ទៀត គេយកទៅវៃចោលនុ៎ង។

**សៈ** មុននេះ លោកស្រីបានមានប្រសាសន៍ថា កូនរបស់គាត់ធ្វើការងារជាមួយកងរបស់លោកស្រី។ អ៊ីចឹងតើលោកស្រីស្គាល់ឈ្មោះកូនៗរបស់គាត់ទេ បាទ? ហើយបើស្គាល់ឈ្មោះអីខ្លះទៅ បាទ?

**ឆៈ** ខ្ញុំមិនបានស្គាល់ដល់ត្រកូលទេ គ្រាន់តែថា ឮគេហៅ ដូចបងស្រី បងស្រអែម វ៉ាន់ឌី ហ្នឹង ហើយស្រីទូច ហ្នឹង គេហៅកាទូចៗ ហ្នឹង ធ្វើការរែកដីជាមួយគ្នាខ្ញុំ ពីរនាក់ស្រីៗហ្នឹង។ ហើយបើ បងគឺ

បងគោ ហើយនិងម៉ៅ នោះ ខ្ញុំគ្រាន់តែស្គាល់គាត់ថា បងគី បងគោ បងម៉ៅ កូនស័ក្តិ៤ ថុន ហ្នឹង ប៉ុន្តែ អត់ដែលបានស្តីគ្នាទេ គ្រាន់តែស្គាល់ឈ្មោះអ៊ីចឹង។

**ស៖** មុននេះក៏លោកស្រីបានមានប្រសាសន៍ថា លោកស្រីអត់បានឃើញការសម្លាប់ផ្ទាល់ទេ មានគេប្រាប់ តើអ្នកប្រាប់លោកស្រី អ្នកណាគេបាទ?

**ឆ៖** បើអ្នកឃើញអ្នកចាប់រំលោភហ្នឹង គឺប៉ាខ្ញុំផ្ទាល់ហ្នឹង បានគាត់មកខ្សឹបប្រាប់ខ្ញុំ បានគាត់ភ័យខ្លាចហ្នឹង។ ហើយបើបងប្រុស ហើយនិងម្តាយគាត់ហ្នឹង ខ្ញុំគ្រាន់តែឮអ្នកភូមិគេខ្សឹបប្រាប់គ្នាថា "ហ៊ឺ! កូនគ្រួសារស័ក្តិ៤ ថុន គេយកទៅវៃចោលហើយ" គេលួចខ្សឹបប្រាប់គ្នាអ៊ីចឹង មិនបាននិយាយកោកកាក អូ៎! គ្រួសារនេះគេយកទៅវៃចោលអី មិនបានទេ ខ្សឹបប្រាប់គ្នា តៗគ្នាទៅ។ ដូចថា ក្នុងភូមិយើងហ្នឹង ដល់អ៊ីចឹងមានការជ្រួលច្របល់ មានការភ័យខ្លាចគ្រប់ៗគ្នាហ្នឹង។

[១០:៤១:៣៨]

**ស៖** គេមានប្រាប់ថា គេយកទៅសម្លាប់នៅកន្លែងណាទេ ការខ្សឹបខ្សៀវគ្នាហ្នឹង?

**ឆ៖** ចាស គឺអត់ដឹងទេ គេខ្សឹប គ្រាន់តែថាគេយកទៅហើយ គេយកទៅវៃចោលហើយ អត់ដឹងទេ មិនដឹងគេយកទៅណាទៅណីទេ គ្រាន់តែថាបើស្រីពីរនាក់នោះ ប៉ាខ្ញុំគាត់ទៅយកជីលេខ១ហ្នឹង ឃើញ ជីអាចម៍ហ្នឹង គេឱ្យប៉ាខ្ញុំគាត់ធ្វើអាជីអាចម៍ហ្នឹង ហៅជីលេខ១១ គាត់ទៅឃើញៗបានគាត់ភ័យគាត់មក។ ដូចខ្ញុំនិយាយរៀបរាប់ពីមុនអ៊ីចឹង បានប៉ាខ្ញុំដល់ថ្នាក់ធ្វើអត្តឃាតហ្នឹង ព្រោះឃើញសភាពអស់ហ្នឹងគាត់ខ្លាចកូនគាត់ដូចគេអ៊ីចឹងដែរ គាត់សុខចិត្តធ្វើអត្តឃាតដើម្បីឱ្យកូនរស់។ ខ្លាចវាសនាពួកខ្ញុំដូចពួកបងស្រីៗពីរនាក់នោះ។

**ស៖** បាទ ឥឡូវទាក់ទងនឹងប្រវត្តិរបស់លោកឪពុករបស់លោកស្រី។ ពីម្សិលមិញលោកស្រីបានថ្លែងថា ជីដូនជីតាខាងឪពុករបស់លោកស្រី បានន័យថាឪពុកម្តាយរបស់ឪពុកលោកស្រីជាវៀតណាមរស់នៅខ្មែរ។ ប៉ុន្តែបើ -- ខ្ញុំសូមអនុញ្ញាតដកស្រង់ចម្លើយបន្ថែមរបស់លោកស្រីដែលនៅក្នុងឯកសារលេខ 409/5/1.2.1, ERN ជាភាសាខ្មែរមានលេខ 00621379, ERN ជាភាសាបារាំងមានលេខ 01204938, ERN ជាភាសាអង់គ្លេសមានលេខ 00621377 លោកស្រីបាន -- ចម្លើយរបស់លោកស្រីហ្នឹងបានឆ្លើយថា៖ "ជីតារបស់ខ្ញុំបានធ្វើដំណើរមកពីប្រទេសវៀតណាមក្នុងអំឡុងរបបស្តេចសីហនុទសវត្សរ៍ឆ្នាំ១៩៥០។ គាត់បានរៀបការប្រពន្ធខ្មែរ ហើយបានកូនម្នាក់គឺឪពុករបស់ខ្ញុំ ជាកូនកាត់វៀត-ណាមខ្មែរ។" អ៊ីចឹងតើលោកស្រី ចម្លើយរបស់លោកស្រីហ្នឹង រំឭកការចងចាំរបស់លោកស្រីទេថា តើ

ឪពុករបស់លោកស្រីកើតចេញពីឪពុកម្ដាយវៀតណាម ឬក៏កើតចេញពីឪពុកវៀតណាម ម្ដាយខ្មែរ?

**ឆ៖** តាមដែលខ្ញុំរៀបរាប់ពីម្សិលមិញ ដូចខ្ញុំរៀបរាប់អ៊ីចឹង គឺជីតារបស់ខ្ញុំវៀតណាម យាយរបស់ខ្ញុំវៀតណាម។ គឺវៀតណាមនៅស្រុកខ្មែរ។ ខ្ញុំបាននិយាយពីម្សិលមិញហើយ។

**ស៖** ចុះចម្លើយដែលខ្ញុំអានជូនលោកស្រីស្ដាប់អំមិញ លោកស្រីយល់ថាជាចម្លើយរបស់លោកស្រី ឬក៏មិនមែនទេ?

[១០:៤៥:០០]

**ឆ៖** ចម្លើយដែលអានមិញហ្នឹងមិនមែនទេ ព្រោះអីគាត់ ខ្ញុំមើលដែរឯកសារហ្នឹង គឺគាត់សរសេរទៅ វាខុស។ ខុសដល់ពេលអ៊ីចឹង ពេលដែលខ្ញុំមើលហ្នឹង ហួសពេលនឹងកែហើយ ដែលគាត់សរសេរថាជីតារបស់ខ្ញុំបានវិលមកស្រុកខ្មែរ រៀបការជាមួយប្រពន្ធខ្មែរហ្នឹង មិនមែនទេ។

**ស៖** បាទ អរគុណ។ ឥឡូវចូលដល់ករណីដែលការបង្ខំឲ្យបងស្រីរបស់លោកស្រីរៀបការ។ លោកស្រីថ្លែងអំមិញថា គេបង្ខំបងស្រីរបស់លោកស្រីឲ្យរៀបការ។ អ៊ីចឹងតើសព្វថ្ងៃនេះ បងស្រីរបស់លោកស្រី និងប្ដីដែលរៀបការជំនាន់កម្ពុជាប្រជាធិបតេយ្យនោះ នៅជុំគ្នាជាប្ដីប្រពន្ធដែរឬទេ?

**ឆ៖** គាត់នៅជុំគ្នាតើ ប៉ុន្តែប្ដីហ្នឹងគាត់ធ្វើបាបផ្លូវចិត្ត ផ្លូវកាយបងស្រីខ្ញុំរហូតហ្នឹង។ គាត់ស្រវឹងស្រា គាត់រករឿង ជេរ ធ្វើបាបបងស្រីខ្ញុំ។ រាល់ថ្ងៃហ្នឹង នៅគាត់ចេះតែទ្រាំរស់នៅទៅ ព្រោះគាត់មានកូន មានចៅហើយ។ គាត់នៅជុំគ្នា។ គាត់មិនបានបែកបាក់គ្នាទៅណាទេ លែងគ្នាក៏លែងមិនដាច់ ពេលគាត់មានកូន មានចៅទន្ទឹមៗខ្លួនអស់ហើយ។ គាត់ចេះតែស៊ូទ្រាំរស់នៅទៅ ធ្វើម៉េច តាមពាក្យចាស់គាត់ថាកម្ម តាមផលកម្មរបស់គាត់។

**ស៖** តើគាត់មានកូនប៉ុន្មាននាក់ដែរ ជាមួយនឹងប្ដីគាត់ហ្នឹង បាទ?

**ឆ៖** កូនគាត់ប្រាំបីនាក់ ស្លាប់មួយ នៅសល់ប្រាំពីររាល់ថ្ងៃ។

[១០:៤៧:៤០]

**ស៖** តើលោកស្រីដឹងពីរបៀបស្នើឲ្យរៀបការម៉េច ព្រោះអំមិញលោកស្រីថា ខាងបុរសបានស្នើមកខាងបងស្រីរបស់លោកស្រីសុំរៀបការ។ តើគេស្នើហ្នឹង ស្នើតាមរយៈឪពុកម្ដាយ ឬក៏ស្នើតាមរយៈអ្នកណា?

**ឆ៖** រឿងហ្នឹងខ្ញុំដឹងមិនសូវច្បាស់ដែរ ព្រោះខ្ញុំនៅតូចដែរ ឮតែគេថា ស្នើៗអង្គការការៗ។ ប្រហែលគេស្នើតាមប្រធានភូមិ ប្រធានអីហើយយ៉ាងមើលទៅ ឮតែគេថាស្នើៗ។ ពាក្យ “ស្នើៗ” ហ្នឹង

មិនដឹងថា ម៉េចម៉ាអី គេថា ឮប៉ាខ្ញុំម៉ែខ្ញុំ ឮម្ដាយខ្ញុំថា "គេស្នើបងអ្អែងការ"។ មិនដឹងគេស្នើតាមរយៈណា បែបគេស្នើតាមប្រធានភូមិប្រធានក្រុមអី មកសួរម្ដាយខ្ញុំដែរមើលទៅ បែបអ៊ីចឹងហើយ ព្រោះយើងមានតែបានចាប់អារម្មណ៍អីការងារអ៊ីចឹងៗ ព្រោះយើងរវល់តែទៅធ្វើការបាត់ៗ។ គ្រាន់តែឮម៉ែថាគេស្នើអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី អ្វីដែលលោកស្រីដឹង អាចឆ្លើយថាដឹង អ្វីដែលមិនដឹង ឆ្លើយថាមិនដឹងទៅ មិនអាចឆ្លើយថាប្រហែល ឬក៏ទំនងអ៊ីចេះអ៊ីចុះបានទេ ព្រោះនេះជាសក្ខីកម្មរបស់លោកស្រីដែលអង្គជំនុំជម្រះយកពិចារណា ដើម្បីវាយតម្លៃថាតើវាមានជាភស្តុតាង ដែលមានប្រយោជន៍នៅក្នុងការវិភាគស្វែងការពិតនៅក្នុងក្ដីនេះដែរអត់។ អ៊ីចឹងរឿងដែលប្រហែល រឿងទំនង ហាក់ដូចជាអី គឺមិនច្បាស់លាស់ គឺមិនអាចយកជាបានការទេ ហើយវាអាចប្រើពេលវេលាឥតប្រយោជន៍នៅក្នុងកិច្ចដំណើរការសវនាការ។

**សួរដោយលោក លីវ សុវណ្ណ៖**

**ស៖** លោកស្រី ពេលដែលម្ដាយលោកស្រីប្រាប់លោកស្រីថា គេស្នើបងលោកស្រីរៀបការហ្នឹង គាត់បានប្រាប់មុនដែលបងស្រីលោកស្រីរៀបការ ឬក៏ក្រោយបងស្រីលោកស្រីរៀបការ?

[១០:៤៩:៤៧]

**លោកស្រី សៀង ចាន់ថី៖**

**ឆ៖** គាត់ប្រាប់មុនពេលរៀបការ។

**ស៖** គាត់មាននិយាយអ្វីបន្ថែមប្រាប់លោកស្រីទៀតទេ?

**ឆ៖** គាត់ប្រាប់ គាត់ថាបងអ្អែង គេស្នើឲ្យរៀបការហើយ ខ្ញុំថា អូ៎! មិនដឹងការស្អីទេ ឲ្យរៀបការស្អីទេ ខ្ញុំមិនទៅការទេ។ គាត់ថា អ្អែងទៅការដែរអី ខ្ញុំថាខ្ញុំមិនទេ។ ទៅៗកូនអើយ ក្រែងលោនេះអ្អែងតែអ៊ីចឹងខ្លាចគេយកវ៉ៃចោលទៀត ឲ្យបងទៅការទៅ ហើយទៅការបងទៅ។ គាត់ប្រាប់អ៊ីចឹង។

**ស៖** ចុះមុនពេលដែលបងស្រីរៀបការហ្នឹង បងស្រីរបស់លោកស្រីមាននិយាយប្រាប់អ្វីដល់លោកស្រីដែរទេ?

**ឆ៖** គាត់គ្រាន់តែប្រាប់ថា គាត់អត់បានស្រឡាញ់។

**ស៖** ចុះក្រោយរៀបការហើយ គាត់មានប្រាប់អីលោកស្រីទេ?

**ឆ៖** អត់ទេ គាត់ការហើយ ក៏គាត់រួមរស់នៅជាមួយហ្នឹងទៅ ព្រោះខ្លាចអង្គការ។ ការហើយៗ មានគាត់មានអីប្រាប់ទៀត រឿងប្តីប្រពន្ធគាត់ គ្មានប៉ាននិយាយអីទេ។ ហើយខ្ញុំក៏មិនទៅសួរនាំអីគាត់ដែរ ព្រោះគាត់រៀបការហើយ។ យើងធ្វើការរៀងៗខ្លួនទៅ។

**ស៖** ចុះហេតុអ្វីបានជាលោកស្រីថ្លែងថា គេ បងស្រីរបស់លោកស្រីរៀបការដោយបង្ខំ?

**ឆ៖** ចុះខ្ញុំឆ្លើយប្រាប់ហើយ ថាគាត់មិនស្រលាញ់នោះ មិនស្រលាញ់បុរសនុ៎ង បង្ខំគាត់ហើយ បើគាត់ស្រឡាញ់ គេមានថាបង្ខំម៉េច។

**លោក លីវ សុវណ្ណា៖**

បាទ ខ្ញុំបាទ ខ្ញុំសូមអរគុណលោកស្រី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខាងក្រុមមេធាវីការពារលោក ខៀវ សំផន អត់មានសំណួរទេបាទ។ សូមអរគុណ។

[១០:៥២:៥៥]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅកញ្ញា ជា ស៊ីវហ៊ាង ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងផ្តល់សក្ខីកម្មបន្ទាប់ពីដើមបណ្តឹងរូបនេះ?

យ៉ាងម៉េចទៅមេ -- សហមេធាវីការពារក្តីលោក -- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធានសាជាថ្មី សូមអធ្យាស្រ័យ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីក៏មានសំណួរសម្រាប់សួរទៅជនជាប់ចោទតាមរយៈលោកប្រធានដែរ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

មានបានបញ្ជូនមកមន្ត្រីច្បាប់ជាន់ខ្ពស់ទេ?

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន បានបញ្ជូនហើយលោកប្រធាន។ បាទ គឺនៅថ្ងៃម្សិលមិញនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ មិនអីទេ។

សូមអញ្ជើញលោកស្រី សៀង ចាន់ថី ជាចុងក្រោយនេះ តើលោកស្រីមានការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាអ្វីបន្ថែមចុងក្រោយទេ ឬក៏មានសំណួរអ្វីចង់សួរទៅចំពោះជនជាប់ចោទតាមរយៈយើងជាប្រធានអង្គជំនុំជម្រះដែរឬទេ? បើសិនបើមានសូមអញ្ជើញ!

[១០:៥៥:00]

**លោកស្រី សៀង ចាន់ថី៖**

ចាសអរគុណ។ ខ្ញុំមានសំណួរ។ សំណួរទី១ ខ្ញុំគ្រាន់តែឆ្ងល់ថា តើហេតុអ្វីបានជារបបរបស់កម្ពុជាប្រជាធិបតេយ្យសម្លាប់មនុស្ស ហើយនិងរើសអើងចំពោះជនជាតិដទៃ សម្លាប់ៗមនុស្សដូចជាជនជាតិវៀតណាម ចាម ចិន ដែលរស់នៅក្នុងរបបនោះ? ហើយសំណួរទី២ ខ្ញុំចង់សួរគាត់ថា ហេតុអ្វីបានជាគាត់មិនយកថ្ងៃជ័យជម្នះ១៧ មេសា ដែលមហាលោតផ្លោះ មហាអស្ចារ្យរបស់គាត់ហ្នឹង ទៅអភិវឌ្ឍន៍ប្រទេសជាតិ បែរជាយកពាក្យស្លោកដែលគាត់តែងតែស្រែកថា “ជយោ! មហាលោតផ្លោះ មហាអស្ចារ្យ” មកបំផ្លិចបំផ្លាញប្រជាជន និងបំផ្លាញជាតិ? គ្រាន់តែខ្ញុំចង់សួរគាត់ប៉ុណ្ណឹង។

អរគុណ ដល់អង្គតុលាការទាំងមូល។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី សៀង ចាន់ថី ថាតាមបទប្បញ្ញត្តិនៃវិធាន២១(១) ចំណុច(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថានៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប ទៅនឹងសំណួរដល់ជនជាប់ចោទ។

ហើយនៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះ បានស្ដាប់ជនជាប់ចោទទាំងពីរនាក់ ឆ្លើយបញ្ជាក់ពីការដែលពួកគាត់សូមរក្សាសិទ្ធិនៅស្ងៀម មិនឆ្លើយតបទៅនឹងសំណួរ។ ហើយសវនាការនៅពេលនោះ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់

ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីរបស់ជនជាប់ចោទ។ នៅក្នុងថ្ងៃសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និងសហមេធាវីការពារក្ដីជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងមកអង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទមានបានសម្រេចចិត្តលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។

[១០:៥៧:២៣]

ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅឡើយទេ។ ហើយបញ្ជាក់ថា តាមច្បាប់ ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ តុលាការមិនអាចបង្ខំឲ្យជនជាប់ចោទឆ្លើយតបទៅនឹងសំណួរបានទេ។ នេះ ជាសិទ្ធិដែលមានចែងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផង ហើយចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិផង។

អង្គជំនុំជម្រះ អរគុណលោកស្រី សៀង ចាន់ធី។ ការស្ដាប់សក្ខីកម្មរបស់លោកស្រី និងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីបាន ដែលលោកស្រីអះអាងថា បានរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ បានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកស្រី នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិត ក្នុងរឿងក្ដីនេះ។ ឥឡូវនេះ លោកស្រី វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ មានសុខភាពល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រ ក៏សូមអរគុណលោកស្រី ឆាយ ម៉ារីដែត បុគ្គលិកអង្គការ ធី.ភី.អូ ដោយសារលោកស្រីត្រូវនៅអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងផ្ដល់ការថ្លែងរៀបរាប់ទុក្ខសោកវេទនាបន្តបន្ទាប់ទៀតនោះ។ ដូច្នេះលោកស្រីអង្គុយនៅទីនោះចុះ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះ សូមជម្រាបថា ភាគីជាតិ និងសាធារណ

ជនជ្រាបថា ជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-259។ ហើយដោយសារមូលហេតុដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1015 ហ្នឹងគាត់មានបញ្ហាសុខភាព ហើយកំពុងតែទទួលការព្យាបាលពីគ្រូពេទ្យប្រចាំការនៅ អ.វ.ត.ក នេះ សូមជ្រាប។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញ ដើមបណ្ដឹងរដ្ឋប្បវេណី 259 ចូលមកកាន់កន្លែងផ្ដល់ការរៀបរាប់ទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងបន្ទប់សវនាការនេះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១១:០១:០៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ ខូង មួយ។

**ស៖** អរគុណលោកស្រី ខូង មួយ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរឬទេ?

**ឆ៖** នាងខ្ញុំអត់ចាំផង។ ចាំតែ អាយុ៥៨។

**ស៖** បាទ មិនអីទេ។ សព្វថ្ងៃនេះ លោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** រស់នៅ នាងខ្ញុំរស់នៅស្រែចាម ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តកំពត។ មុន ក្រោយមកឥឡូវគេដាក់ខេត្តកំពង់សោម។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតលោកស្រីគាត់ឈ្មោះអី?

**ឆ៖** នាងខ្ញុំឪពុកបង្កើតឈ្មោះ ខេង ខូង ម្ដាយឈ្មោះ យី។

**ស៖** ហើយប្ដីរបស់លោកស្រីឈ្មោះអី ? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីនាងខ្ញុំចាស់ ឈ្មោះ ហុង អ៊ន ស្លាប់ហើយ កូនប្រាំនាក់។

**ស៖** បាទ អរគុណ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកស្រីថា ក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់សិទ្ធិជូនលោកស្រីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីមានជាអាទិ៍ខាងខូចខាត ខាងផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈ ដែលជាបច្ច័យផ្ទាល់

ពីបទឧក្រិដ្ឋដែលកើតមានឡើងពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអង្គហេតុ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទចំនួនពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ដែលលោកស្រីបានអះអាងថា បានប៉ះពាល់ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ហើយនៅក្នុងអង្គហេតុនេះ គឺយើងបាន -- ចម្បងគឺយើងអនុវត្តចំពោះការប៉ះពាល់ទៅលើក្រុមគោលដៅមនុស្សជាក់លាក់ចំពោះជនជាតិចាម ចំពោះជនជាតិវៀតណាម និងចំពោះអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ នេះជាទិសដៅនៃការស្ដាប់សេចក្ដីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនៅក្នុងការតាំងសំណួរ ការថ្លែងរៀបរាប់នេះ ដោយសារតាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺឲ្យមានការតាំងសំណួរដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីរៀបចំនូវការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ពាក់ព័ន្ធនឹងរបៀបវារៈ កម្មវត្ថុនៃការកំណត់ឲ្យធ្វើសវនាការនាពេលចំពោះមុខនាពេលនេះ។

សូមអញ្ជើញ!

[១១:០៥:១៧]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន មេធាវីនាំមុខសូមអនុញ្ញាតផ្ទេរសិទ្ធិក្នុងការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ខូង មួយ ជូនលោកមេធាវី ឡោ ជុនធី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី ឡោ ជុនធី!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ លោកប្រធាន។ ជាដំបូង ខ្ញុំបាទសូមគោរពលោក លោកស្រីចៅក្រម សូមគោរពភាគី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

ខ្ញុំបាទជម្រាបសួរ លោកស្រី ខូង មួយ។ ខ្ញុំបាទ ឡោ ជុនធី មេធាវីមកពីអង្គការជំនួយផ្នែកច្បាប់

នៃកម្ពុជា។ នៅពេលនេះ ខ្ញុំនឹងជម្រាបសួរ លោកស្រីពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុង ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ០៦ មករា ឆ្នាំ១៩៧៩ ដែលលោកស្រីទទួលរងការឈឺចាប់នៅក្នុង ចន្លោះឆ្នាំនេះ បាទ។

**ស៖** ជាដំបូង ខ្ញុំបាទសុំជម្រាបសួរថា តើអ្វីខ្លះដែលធ្វើឲ្យលោកស្រីទទួលការឈឺចាប់នៅក្នុង របបនោះ ដូចជាពាក់ព័ន្ធទៅនឹងឪពុក ម្ដាយ និងសាច់ញាតិជាដើម? សូមលោកស្រីអាចនិយាយ រៀបរាប់ជូនអង្គជំនុំជម្រះនៅពេលនេះឲ្យបានជ្រាប។ បាទ សូម--

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំមកពីមុន ៧៥ នៅកោះសេះ ពេលខ្មែរក្រហមរំដោះខ្ញុំមកស្រែចាម ខ្ញុំក៏បាន នៅជាមួយម្ដាយខ្ញុំ ឪពុកខ្ញុំ។ ពេលឆ្នាំ៧៦ គេឲ្យទ័ព ខ្មែរក្រហមឲ្យខ្ញុំចេញពីឪពុកម្ដាយខ្ញុំ ទៅនៅកង ចល័ត នៅវត្តព្រៃទប់។ ក៏ថ្ងៃខ្ញុំក៏បានសុំ បងជីតង ហ្នឹងទៅលេងផ្ទះ។ ខ្ញុំក៏បានទៅដល់អត់ឃើញឪពុក ម្ដាយ បងប្អូនខ្ញុំ ឃើញតែផ្ទះទទេ។ ដល់ពេលរួចហ្នឹង ខ្ញុំក៏យំនៅចាំដល់ថ្ងៃល្ងាច ម៉ោងប្រហែលបី ចាំ ល្ងាចហ្នឹង ដល់ពេលឃើញតែផ្ទះទទេ ដល់ពេលអ៊ំមួយគាត់នៅជិតហ្នឹង គាត់ប្រាប់ថា ម៉ាកអ្អែងគេយក ទៅវៃចោលហើយ។ ម៉ាកអ្អែងខំស្រែកពេញផ្លូវ ប្រាប់ថាផ្ដាំកូនខ្ញុំ មួយ ផង ថាគាត់ទៅហើយ។ ហើយខ្ញុំ ក៏ចាំរហូតដល់យប់ដេកនៅផ្ទះអ៊ំជិតមួយយប់។ ព្រឹកឡើងខ្ញុំក៏ទៅកងចល័តវិញ។ ដល់ម្ដាយខ្ញុំ គេវៃ ចោលប្អូន ក្មួយ ប្រាំមួយនាក់ ហើយបងស្រីទៀតប្រាំបីនាក់។ ខ្ញុំក៏ទៅកងវិញ។ ខ្ញុំក៏បានយំសោកស្ដាយ ម្ដាយឪពុកខ្ញុំ ខំថែរក្សាខ្ញុំតាំងពីតូច រហូតដល់សព្វថ្ងៃហ្នឹង ខ្ញុំនៅនឹករឭកម្ដាយខ្ញុំ។ ខំឮគេប្រាប់ថា ម៉ាក អ្អែងយំពេញផ្លូវ គេវៃផង ស្រែកផង ស្រែកអូយ!ៗ ពេញផ្លូវ។ គាត់ប្រាប់ខ្ញុំ ខ្ញុំយំស្ដាយម៉ាកខ្ញុំ ខ្ញុំខំថែ រក្សាខ្ញុំ ថ្នាក់ថ្នមខ្ញុំស្រលាញ់។ ដល់សព្វថ្ងៃ ខ្ញុំកំព្រា អត់ឪពុកម្ដាយ បងប្អូនទាំងអស់ជាង១០នាក់ ស្លាប់ អស់។ ដល់ពេលខ្ញុំក៏ទៅកងវិញ។ ខ្ញុំបានសុំមេកងទៅប្រាប់ប្អូនប្រុសមួយនៅយុទ្ធជនដែរ ទៅប្រាប់ប្អូន ឲ្យដឹងដំណឹងថា ម៉ែគេយកទៅវៃចោលហើយ។

[១១:០៩:៥៨]

ដល់ពេលខ្ញុំ ដល់ប្រាប់ប្អូន ទៅដល់អត់ឃើញប្អូននៅទេ ប្អូនគេថា មានយុទ្ធជនហ្នឹងគេប្រាប់ថា ប្អូនបងឯង ខូង កេង ហ្នឹង នៅកង គេយកទៅកងសេរី គេយកទៅបាត់យូរដែរហើយ។ ដល់គេឮ គេ ប្រាប់ខ្ញុំថាគេយកទៅវៃចោលហើយ ដល់ពេលខ្ញុំ ក៏បកមកកងវិញ។ ខ្ញុំក៏បានយំៗសោកថា បងៗគេខំថា កុំយំអី នៅជាមួយបងៗហ្នឹងក៏ដូចឪពុកម្ដាយខ្ញុំយើងដែរ ដល់ពេលខ្ញុំថាអត់ដូចទេ។ ដល់ថ្ងៃមួយហ្នឹង

មានកូនយាយយួនហ្នឹង គេយកទៅវ៉ៃចោល យាយយួនគេយកវ៉ៃចោលដែរ ដល់កូនគាត់ធ្វើកងចល័តជាមួយកងខ្ញុំ ធ្វើកងរយ គេយកទៅវ៉ៃចោលដែរ ហើយមានបងនៅក្នុងហ្នឹងធ្វើការជាមួយគ្នា គេខ្សឹបថា អ្អែងឈប់យំទៅ ប្រយ័ត្នគេយកទៅវ៉ៃចោលដែរ។

**ស៖** បាទ អរគុណ។ អម្បាញ់មិញ លោកស្រីបានរៀបរាប់អំពីព្រឹត្តិការណ៍ដែលលោកស្រីបានវិលត្រឡប់ទៅផ្ទះហើយមិនបានឃើញឪពុកម្ដាយនៅទីនោះ។ សូមជម្រាបសួរថា តើនៅពេលដែលត្រឡប់ដល់ផ្ទះវិញហ្នឹង រង់ចាំគាត់នៅផ្ទះហ្នឹង ឬមួយមានអ្នកណាមកប្រាប់ពីរឿងហេតុដែលកើតឡើងទៅលើឪពុកម្ដាយរបស់លោកស្រី?

[១១:១១:៥៨]

**ឆ៖** នាងខ្ញុំមាន ខ្ញុំរង់ចាំដល់ថ្ងៃល្ងាច អ៊ំជ្រុញ ហ្នឹង គាត់មកប្រាប់ខ្សឹបប្រាប់ខ្ញុំថា ថាម៉ែឪអ្អែងគេយកទៅវ៉ៃចោលហើយ។ គេប្រាប់ខ្ញុំ គេថាម៉ែឪអ្អែងជាចិន-យួន គេយកទៅវ៉ៃចោលហើយ។ ខ្ញុំក៏យំស្រែករហូតដល់យប់ មួយយប់ទល់ភ្លឺ ខ្ញុំអត់បានដេកទេ។ ព្រលឹមឡើង ខ្ញុំក៏បានទៅកងវិញ។ ខ្ញុំឈឺចុកចាប់ណាស់រាល់ថ្ងៃ ខ្ញុំពេលសែនម្ដងៗ សែនហៅម៉ែឪបងប្អូន សែនខាងក្នុងផ្ទះផង នៅក្រៅផ្ទះផង បងប្អូនអត់មានជើងធូប ខ្ញុំកូនចិនកាន់យួន។ សែនតែម៉ែឪមានជើងធូប ចេះតែហៅ ចេះតែនឹករឭកម៉ែខ្ញុំសព្វថ្ងៃខ្ញុំនៅតែខ្លួនមួយ កំព្រា។ ខ្ញុំយកអីប្រៀបមិនបានទេ អ៊ីចឹងបានខ្ញុំចេះតែនឹកឃើញរាល់ថ្ងៃ ដល់នឹកឃើញយំ នឹកឃើញយំឡើងហើមភ្នែកអស់ហើយ។ កំសត់ណាស់ខ្ញុំ ឈឺចាប់យ៉ាងខ្លាំង រកអីប្រៀបមិនបាន មាសប៉ុនដូងទុំក៏ដូរជីវិតម៉ែឪខ្ញុំក៏មិនបានដែរ មាសអីគេយកទៅអស់ហើយ។ កំព្រាម៉ែ ដល់គេរំដោះទៅខ្ញុំក៏បានទៅ -- គេរំដោះហើយ គេហៅខ្ញុំឡើងភ្នំ ខ្ញុំមិនទៅទេ ខ្ញុំទៅរកអ៊ំនៅភូមិ។ ទៅឃើញអ៊ំ ហើយខ្ញុំក៏យំថែមទៀត យំដល់សព្វថ្ងៃរាល់ថ្ងៃហ្នឹង នៅតែយំឲ្យឃើញគេកំព្រាម៉ែកំព្រាឪ ខ្ញុំយំតែរហូត អត់មាន នឹកឃើញការឈឺចាប់យ៉ាងខ្លាំង ហើយខ្ញុំកំសត់ណាស់ កើតមួយជីវិតហ្នឹង ខុសគេ កំព្រាម៉ែកំព្រាឪតាំងពី ហើយម៉ែឪខ្ញុំខំតែរៀតណាម ខំធ្វើការ គេនៅតែយកទៅវ៉ៃចោលទៀត មិនប៉ានឈប់ទេ។

[១១:១៤:២៥]

**ស៖** បាទ អរគុណ។ ថាតើនៅពេលនោះ គេបានទទួលព័ត៌មានថាយ៉ាងម៉េចបានគេនាំឪពុកម្ដាយលោកស្រីហ្នឹងទៅថាទៅសម្លាប់ហ្នឹង ថាតើមានដឹងថាគេចោទពីមូលហេតុអីទេ?

**ឆ៖** ចាស នាងខ្ញុំឮថា មីងនៅកោះខ្សុង អ៊ំកោះខ្សុងហ្នឹង គាត់លួចប្រាប់ តាចាម នៅជិតផ្ទះហ្នឹង គាត់លួចប្រាប់ គេចោទថា ម៉ែឪខ្ញុំយួនចិន និយាយខ្មែរអត់ច្បាស់ គេយកទៅសម្លាប់។ ខ្ញុំឮអ៊ីចឹង ខ្ញុំ

ស្ទួរដំណើងរហូត។

**ស៖** បាទ អរគុណ។ ចាតើឪពុកម្ដាយលោកស្រីហ្នឹង គាត់ជាជនជាតិអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ កុំអាលទាន់ឆ្លើយ!

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស ម្ដាយមីងខ្ញុំ ឪពុកខ្ញុំ ជនជាតិចិន ម្ដាយខ្ញុំជនជាតិវៀតណាម គេចោទថា ចិន យួន គេយកទៅវ៉ៃចោល ខ្ញុំឮគេថាអ៊ីចឹង មិនដឹងដែរ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទ អរគុណ។ ចាតើនៅក្នុងថ្ងៃតែមួយហ្នឹង គេយកក្រុមគ្រួសារលោកស្រីទៅហ្នឹង មានសមាជិកប៉ុន្មាននាក់ដែរ លោកស្រីអាចជម្រាបអង្គជំនុំជម្រះបានទេ?

**ឆ៖** ចាស ក្នុងនាមក្រុមគ្រួសារនាងខ្ញុំ ទាំងអស់ ទាំងបង ទាំងក្មួយ ១៣នាក់ ទាំងម្ដាយឪពុកទៀត។

[១១:១៦:៥៥]

**ស៖** លោកស្រីបានបញ្ជាក់ថា មានបង មានក្មួយ។ អ៊ីចឹងមានន័យថា មានក្រុមគ្រួសារមួយគ្រួទៀត ដែលត្រូវជាក្រុមគ្រួសារបងខាងលោកស្រីហ្នឹង។ តើគាត់មានសមាជិកប៉ុន្មាននាក់ទៀតទៅ?

**ឆ៖** ចាស នាងខ្ញុំ បងថ្លៃខ្ញុំ បងស្រី ទាំងក្មួយ ប្រាំបីនាក់ ក្មួយតូចៗប្រាំមួយនាក់ ទាំងអស់ប្រាំបីនាក់។ ហើយថ្ងៃហ្នឹង ជីដូនមួយខ្ញុំ ទាំងកូនគាត់ ទាំងគាត់ទៀត ប្ដីប្រពន្ធទៀត បួនប្រាំនាក់ទៀត។ ដល់ខ្ញុំនៅកងចល័ត ខ្ញុំអត់ដឹង ទាល់តែកូនអ៊ុំខ្ញុំទៅថ្ងៃជាមួយគ្នាដែរ ហ្នឹងជីដូនមួយ។ គេអត់ឲ្យប្រពន្ធទៅទេ។ ប្រពន្ធថា បើស្លាប់ ស្លាប់ទាំងអស់គ្នាទៅ បើកូនប្ដីទៅហើយ នៅធ្វើអី។ ជីដូនមួយខ្ញុំ ខ្ញុំឮគេប្រាប់អ៊ីចឹង។ ខ្ញុំនៅផ្ទះជាប់គ្នាទាំងអស់ នៅស្រែចាមទាំងអស់គ្នាហ្នឹង។ ប្ដីគាត់វៀតណាមដែរ ហើយគាត់ចិន។

**ស៖** អ៊ីចឹងក្រុមគ្រួសារខាងបងស្រីលោកស្រីហ្នឹង គាត់ជាជនជាតិអីដែរ?

**ឆ៖** ប្ដីគាត់ជនជាតិវៀតណាម។ គាត់ បងខ្ញុំកាត់វៀតណាមចិនដែរ គេចោទ។

**ស៖** បាទ អរគុណ។ ចាតើលោកស្រីបានទទួលព័ត៌មានហ្នឹងពីអ្នកជិតខាងនៅក្នុងភូមិ ចាតើដឹងថា គេយកគាត់ហ្នឹង យកទៅខាងណាដែរៗឬទេ បាទ?

[១១:១៩:៣០]

**ឆ៖** ចាស នាងខ្ញុំដឹងថា អ្នកភូមិប្រាប់ថា យកទៅផ្លូវកន្លែងនាងខ្ញុំនៅស្រែចាមក្រោមហ្នឹង ម្ដាយនៅហ្នឹង យកទៅផ្លូវកោះខ្យង ចុងជ្រោយហ្នឹង យកទៅកន្លែងខ្មោះគុកហ្នឹង ចុងជ្រោយ កោះខ្យង ហ្នឹង ជិតកោះខ្យងហ្នឹង។ គេប្រាប់ថាអ៊ីចឹង ស្រែកពេញផ្លូវ។ ហ្នឹងប្រហែលមួយថ្ងៃ ប្រហែលពីរបីគីឡូដី។

**ស៖** បាទ អរគុណ។ អម្បាញ់មិញ លោកស្រីបាននិយាយថា មានក្រុមគ្រួសារមួយទៀត តើក្រុមគ្រួសារនោះ ពាក់ព័ន្ធអ្វីដែរបាទ?

**ឆ៖** ក្រុមគ្រួសារហ្នឹង ចាសនាងខ្ញុំពាក់ព័ន្ធជាមួយកូន ត្រូវកូនអ៊ំដែរ ហើយប្ដីគាត់វៀតណាម។ អ៊ំខ្ញុំគាត់ចិន។ ពាក់ព័ន្ធគេទៅទាំងអស់ គេអត់ឲ្យប្រពន្ធទៅទេ ប្រពន្ធគាត់ ម្ដាយគាត់ជាមូលដ្ឋាន។ ដល់គេអត់ឲ្យគាត់ទៅ គាត់ថា បើស្លាប់ ស្លាប់ទាំងអស់គ្នា គាត់ក៏ទៅដែរ បើកូនប្ដីទៅអស់ហើយ គាត់នៅធ្វើអី? នៅតែឯងនៅធ្វើអី ងាប់ ងាប់ទាំងអស់គ្នា គាត់ថាអ៊ីចឹង។ ហ្នឹងជីដូនមួយបង្កើតដែរ។

**ស៖** បាទ អរគុណ។ ពេលដែលលោកស្រីបានដឹងព័ត៌មាននេះហើយ ហើយបានត្រឡប់ទៅកងចល័តវិញ។ នៅពេលដែលទៅដល់កងចល័តនោះ អម្បាញ់មិញលោកស្រីបានបញ្ជាក់ថា លោកស្រីយំរហូត ហើយនៅពេលនោះទទួលនូវព័ត៌មានអ្វី ឬមួយដឹងពីថាតើមានបញ្ហាអីកើតឡើង បើនៅតែយំអ៊ីចឹង?

**ឆ៖** ចាសនាងខ្ញុំបានទទួលព័ត៌មាន ណាមួយប្អូន ក៏សួរដំណឹងប្អូន ប្រាប់ប្អូនឲ្យដឹងដំណឹងម្ដាយឪពុកស្លាប់ហ្នឹង ក៏ទៅហើយប្អូនក៏គេយកទៅវៃចោលទៀត។ ខ្ញុំក៏យំតែរហូត មួយ ហើយណាមួយទៀតថាបាននៅពីរនាក់បងប្អូន ដល់គេថាស្លាប់អស់ ត្រឡប់មកវិញនឹកឃើញ ថ្នើរម៉ាន យំថ្នើរហ្នឹង យំមិនប៉ានយំខ្លាំងទេ ហើយខំតែធ្វើការមិនប៉ានឈប់ទៀត ខ្លាចគេវៃចោល។ ខំរស់ ខ្ញុំនៅរស់នេះ សំណាងហើយ អ្នកណាក៏ថាដែរ ក្មេងកូនយួន ក្មេងនៅ អ្នកណាក៏ថា ខ្ញុំសព្វថ្ងៃហ្នឹង ខ្ញុំអាយុវែងដែរ។

[១១:២៣:០៦]

**ស៖** អរគុណ។ សំណួរខ្ញុំ ខ្ញុំចង់ជម្រាបសួរថា នៅពេលដែលលោកស្រីទៅវិញហ្នឹងមានគេលួងលោមឲ្យឈប់យំ ហើយនៅពេលណាដែលលោកស្រីបានឈប់យំហ្នឹង មានមូលហេតុអ្វី?

**ឆ៖** ចាស នាងខ្ញុំបានក្រោយមកអ្នកធ្វើការជាមួយ បងក្នុងកងហ្នឹង គាត់ថា ក្មេងកុំយំ ប្រយ័ត្នកូនយាយយួនហ្នឹង ស្លាប់ហើយ ឥឡូវគេមកយកកូនគាត់ធ្វើកងរយទៀត យាយសៀន១ ហ្នឹង ក៏គេយកទៅបាត់ គេថាគេយកទៅវៃ។ គេខ្សឹបប្រាប់ខ្ញុំ ថាក្មេងឈប់យំទៅប្រយ័ត្នគេយកឯងទៅវៃចោលទៀត។ ខ្ញុំក៏ឈប់យំទៅ។ ខ្ញុំឈប់ នៅតែយប់នឹកឃើញយំតិចៗដែរ មិនអត់ទេ។ នៅនឹកឃើញស្ដាយស្រណោះ ណាមួយខ្ញុំនៅតូច ជាង១០ឆ្នាំ ១៦ឆ្នាំ ខ្ញុំកំសត់ពេក ខ្ញុំចេះតែនៅតែយំ ចង់ឈប់ម៉េច ក៏ខ្ញុំនៅតែយំ ងាប់ៗ

ទៅអត់ខ្លាចទេ។

**ស៖** បាទ អរគុណ។ ចុះរឿងមួយទៀត ដែលលោកស្រីបាននិយាយអម្បាញ់មិញ គឺពាក់ព័ន្ធនឹងប្អូនរបស់លោកស្រី។ នៅក្នុងកងចល័តជាមួយលោកស្រី ឬមួយកងចល័តនៅកន្លែងណា?

**ឆ៖** ចាស នៅកងជាមួយផ្សេងគ្នា។ កងចល័តយុវជនផ្សេង។ កាលនោះ វាមិនឲ្យនៅជាមួយគ្នា ទៅនៅកន្លែងវត្តហ្នឹង ក្រោយគ្នាប្រហែល២០០ម៉ែត្រ ៣០០ម៉ែត្រហ្នឹង នៅផ្សេងពីគ្នា នៅកងផ្សេងៗគ្នា កងចល័តយុវនារីផ្សេង កងយុទ្ធជនផ្សេង ចាស។

**ស៖** ហើយ ក្រោយមកលោកស្រីបានទៅរកប្អូន។ ពេលដែលរកប្អូនមិនបានជួបប្អូនហ្នឹង បានទទួលព័ត៌មានគេជម្រាបប្រាប់លោកស្រីថាដូចម្តេច ពីរឿងប្អូនរបស់លោកស្រីហ្នឹង?

**ឆ៖** ចាស នាងខ្ញុំបានសុំមេកងទៅរកវា ប្រាប់ដំណឹងពីម្តាយឪពុកខ្ញុំស្លាប់។ ដល់ពេលទៅមានយុទ្ធជនម្នាក់គេខ្សឹបប្រាប់ថា ខូង កេង ហ្នឹងគេយកទៅកងសេរី គេយកទៅវ៉ៃចោលហើយ អត់នៅទេយូរដែរហើយ ថាអ៊ីចឹង។ ខ្ញុំក៏បកមកវិញទៅ បកមកវិញយំ ក៏យំ យំតាមផ្លូវរហូត។ ខ្ញុំមិនហ៊ានយំខ្លាំងទេ ខ្ញុំក៏រត់មកកងវិញ ប្រហែលពីរបីរយម៉ែត្រហ្នឹង។ នឹកឃើញខ្ញុំកំសត់មាំម្ល៉េះ មួយដល់មួយ បានប្អូននៅទៅ បានរស់ពីរនាក់ អស់រលីងនៅតែខ្ញុំ។ នេះការឈឺចាប់ណាស់រាល់តែថ្ងៃហ្នឹង។ អ៊ីចឹងឥឡូវ ខ្ញុំប្រាប់កូនៗខ្ញុំ កូនចៅខ្ញុំ គាត់ឯងសំណាងហើយ ម៉ែកំព្រាឪ កំព្រាម៉ែ កូនឯងសំណាងអត់មានលំបាកដូចកាលសង្គមអាពតទេ ម៉ែបាកមាំណាស់។ ប្រាប់ឲ្យកូនខ្ញុំ ចៅខ្ញុំឲ្យដឹង កុំធ្វើគំរូតាម ឲ្យដឹង។

[១១:២៧:៥៦]

**ស៖** បាទ សូមអរគុណ។ តើប្អូនរបស់លោកស្រីដែលឈ្មោះ ខូង កេង ហ្នឹងនៅក្នុងកងចល័ត។ អម្បាញ់មិញលោកស្រីបានលើកឡើងថា មានបញ្ជូនទៅកងសេរី។ តើកងសេរីហ្នឹង មានន័យម៉េចដែរ?

**ឆ៖** ចាស កងសេរី នាងខ្ញុំ កាលសង្គមអាពតហ្នឹង កាលជំនាន់ខ្មែរក្រហមហ្នឹង កន្លែងសេរីហើយ ដឹងតែងាប់ឲ្យហើយ កន្លែងហ្នឹង។ សេរីហ្នឹង យើងធ្វើការងារសកម្មម៉េច គេចោទយើងថាយើងខ្លាំង ប្រឆាំងគេ អត់ធ្វើការងារ គេយកទៅកងសេរី ដឹងតែងាប់ហើយ។ កងសេរីហ្នឹង មិនជឿសួរទៅ។ ខ្ញុំនិយាយការពិត ខ្ញុំអត់កុហកទេ កុហកឲ្យងាប់ខ្ញុំកូនប្រាំចុះ អត់កុហកទេ។ ខ្ញុំសម្តែងការពិតហ្នង។ បងប្អូនខ្ញុំប៉ុន្មាននាក់ ម៉ែឪខ្ញុំស្លាប់ប៉ុន្មាននាក់ ខ្ញុំអត់មានកុហកអីបន្តិច។ បើខ្ញុំកុហកឲ្យឡានបុកខ្ញុំងាប់ចុះ រាល់ថ្ងៃ ខ្ញុំអត់ខ្លាចងាប់ទេ។

**ស៖** បាទ អរគុណ។ ខ្ញុំសុំជម្រាបសួរបន្ត តើឆ្លងតាមអ្វីដែលបទពិសោធន៍ ហើយទទួលការឈឺ

ចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ មកដល់បច្ចុប្បន្ននេះ លោកស្រីនៅតែមានផលពិបាក ហើយនៅតែទទួលនូវឥទ្ធិពលនោះយ៉ាងណាខ្លះដែរ អាចជម្រាបអង្គជំនុំជម្រះបានទេបាទ?

**ឆ៖** ខ្ញុំពិបាក ខ្ញុំទៅក្នុងភូមិ ខ្ញុំឃើញអ៊ំ ឃើញបងប្អូនគេជួបជុំគ្នាបានច្រើន ខ្ញុំពិបាកខ្លាំងណាស់ រកអីប្រៀបមិនបានទេ ពិបាករហូតនឹកឃើញម៉ែឪ បុណ្យទានសែន សំពះផ្នូរជីដូនជីតាអីនឹកឃើញ យំតែរហូត ឈឺចាប់តែរហូត អត់មានភ្លេចបានទេ ហើយខ្ញុំ ខ្ញុំកំសត់ ខ្ញុំចេះតែនឹកឃើញ គេច្រៀងកំសត់ៗ ក៏ខ្ញុំយំដែរ។ ឃើញគេកំព្រាក៏ខ្ញុំអាណិតដែរ កុំឲ្យដូចខ្ញុំទៀត។

**ស៖** លោកស្រីកាលនោះ លោកស្រីបានទទួលការអប់រំអ្វីទេ នៅក្នុងសម័យនោះបាទ?

[១១:៣២:១៥]

**ឆ៖** ចាស នាងខ្ញុំស្ដាប់អត់បានកន្លែងហ្នឹង។

**ស៖** អរគុណ។ ចង់ជម្រាបសួរថាអ៊ីចេះ ថាក្នុងសម័យខ្មែរក្រហមហ្នឹង គឺលោកស្រីបានរៀនសូត្រអីអត់?

**ឆ៖** នាងខ្ញុំសម័យនុ៎ង អត់បានរៀនផង ដឹងតែធ្វើការ ធ្វើស្រែ ធ្វើទំនប់ ជីកប្រឡាយរហូតដល់រំដោះ៧៩ ខំធ្វើការខ្លាចគេយកទៅវ៉ៃចោល។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ បាទឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវ-នាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្ម និងផ្ដល់ការរៀបរាប់ ថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី -- មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ។

**លោក ឡោ ជុនធី៖**

បាទ អរគុណ។ សូមគោរពអង្គជំនុំជម្រះសាជាថ្មី។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំនៅសល់សំណួរតែពីរទេដែលសុំបញ្ជាក់ទៅលោកស្រី ខូង មួយ។ ពាក់ព័ន្ធទៅនឹង លោកស្រីបានទទួលព័ត៌មាននៅពេលដែលទៅដល់ផ្ទះ តើគេបានជម្រាបលោកស្រីថាដូចម្តេច ពីរឿងថា គេនាំឪពុកម្តាយ ហើយនិងប្អូនហ្នឹងទៅហ្នឹង គេនាំទៅខាងស្រុកណា ឬមួយគេនាំទៅខាងណា?

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំបានទទួលដំណឹងអ្នកភូមិប្រាប់ថា គេយកឪពុកម្តាយអូនឯងទៅស្រុកយៀកណាមវិញ ថាឲ្យវេចខោអាវ វេចអីទៅ គេជញ្ជូនទៅស្រុកយៀកណាមវិញ។

**ស៖** បាទ អរគុណ។ នៅសំណួរមួយទៀតដែលពាក់ព័ន្ធទៅនឹង តើលោកស្រីមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ក្នុងរបបខ្មែរក្រហមហ្នឹង លោកស្រីមានបានត្រូវគេហៅទៅរៀបការដែរឬអត់ទេ?

[១៣:៣៤:៣៣]

**ឆ៖** ចាស នាងខ្ញុំ គេមាននៅកងចល័តខ្ញុំ នៅមេកងហៅរៀបការដែរ ដល់ខ្ញុំថា ខ្ញុំអត់មានដឹងអីទេ ខ្ញុំអត់យកទេ។ ហើយហៅក្នុងកងហ្នឹងបួនប្រាំគូ ហៅរៀបការ រៀបការតែប្តេជ្ញាចិត្ត ខ្លះគេអត់ព្រមបង្ខំរៀបការ ក៏ៗប្តេជ្ញាចិត្តទៅ ដល់តែពេល ដល់រួចហ្នឹង អត់ត្រូវគ្នា គេដឹងថាអត់ត្រូវគ្នា គេយកទៅវៃចោល។ ខ្ញុំក៏ឮគេថាអ៊ីចឹង ខ្ញុំក៏ភ័យរន្ធត់ក្នុងខ្លួនយ៉ាងខ្លាំង។ ហើយក៏បានប៉ុន្មានថ្ងៃ គេផ្លាស់ខ្ញុំទៅតានៃទៅទៅធ្វើបង្គី ច្រូតស្បូវ ច្រូតអីនៅនោះទៅ។ ខ្ញុំក៏នៅតែភ័យខ្លាចរហូតដល់គេរំដោះហើយ ៧៩ហ្នឹង ខ្ញុំក៏ភ័យខ្លាចតែរហូត ឡើងស្គមរីងរៃ អត់មានហូបអីក៏នេះដែរ ភ័យរហូតដល់សព្វថ្ងៃ រហូតដល់៧៩លែង។

**លោក ឡៅ ជុនធី៖**

អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហ តំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។

**លោក ចូសេហ្វ អេនឌ្រូ ប៊ីយលី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរមេធាវី និងភាគីទាំងអស់ និងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ អេនឌ្រូ ប៊ីយ។ ខ្ញុំនឹងសួរសំណួរមួយចំនួន ក្នុងនាមសហព្រះរាជអាជ្ញា។

[១៣:៣៦:៣៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ីយលី៖**

**ស៖** ខ្ញុំនឹងចាប់ផ្តើមដើម្បីសួរឡើង -- មើលបញ្ហាឡើងវិញដែលលោកស្រីបានឆ្លើយព្រឹកមិញ។ ព្រឹកមិញលោកស្រីបាននិយាយថា លោកស្រីរស់នៅកោះសី មុនពេលខ្មែរក្រហមបញ្ជូនលោកស្រីទៅស្រែចាម។ តើនៅពេលណាដែលខ្មែរក្រហមបញ្ជូនលោកស្រី ហើយនិងក្រុមគ្រួសារទៅស្រែចាមនោះ?

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំ ខ្មែរក្រហមរំដោះខ្ញុំមកពីកោះសេះ មកនៅសាលារៀនព្រៃនប់ ហើយបានរំលងប្រហែលបួនដប់ថ្ងៃ ខ្ញុំក៏ភ្លេចហើយ បានជូនខ្ញុំទៅស្រែចាមវិញ មកនៅជាមួយឪពុកម្តាយរហូតដល់ឆ្នាំ៧៦ ខ្ញុំក៏បែកឪពុកម្តាយមកនៅកងចល័តវិញ។

**ស៖** សូមលោកស្រីប្រាប់អំពីខែហើយនិងឆ្នាំ ដែលគេបញ្ជូនលោកស្រីទៅស្រុកព្រៃនប់?

**ឆ៖** មក នាងខ្ញុំគេជូនមកពីកោះសេះ ខ្មែរក្រហមបញ្ជូនមកពីកោះសេះមក ឱ្យនាងខ្ញុំឪពុកម្តាយទៅនៅសំណាក់នៅកន្លែងសាលារៀនព្រៃនប់ ឆ្នាំ៧៥ រហូតបាន បួនដប់ថ្ងៃ កន្លះខែ ឱ្យខ្ញុំផ្លាស់ទីលំនៅទៅនៅស្រែចាមក្រោម រែកខោអាវ រែកអីទៅស្រែចាមក្រោម ដើរទៅ។

**ស៖** នៅពេលដែលលោកស្រីចាកចេញពីកោះសេះ តើលោកស្រី ហើយនិងក្រុមគ្រួសារ ត្រូវតែចេញពី ត្រូវចេញ ឬក៏មិនចេញពីកោះសេះនោះបានទេ ឬក៏គេបង្ខំថាត្រូវតែចេញ?

**ឆ៖** ចាស នាងខ្ញុំគេបង្ខំត្រូវតែចេញ បើអត់ចេញគេសុទ្ធតែមានកាំភ្លើង ខ្មែរក្រហម គេបាញ់យើងងាប់ទៅ យើងខ្លាចចេះតែមកទៅ ហើយចង់រត់ទៅកោះហ្នឹង វាជិតស្រុកយួនដែរ ចង់រត់ទៅ រត់ម៉េចបាន គេបង្ខំថា អត់អីទេ មកទៅ គេឲ្យលក់អីវ៉ាន់ធម្មតា កាហ្វេ គុយទាវធម្មតា។

**ស៖** ព្រឹកមិញនេះ លោកស្រីបានជម្រាបតុលាការថា ម្ដាយលោកស្រីជាជនជាតិវៀតណាម ហើយឪពុកជាជនជាតិចិន តើលោកស្រីប្រាប់តុលាការបានទេ ថាតើឪពុកម្ដាយរបស់លោកស្រីនោះកើតនៅប្រទេសណា ស្រុកណា?

[១៣:៤០:០០]

**ឆ៖** ចាស ខ្ញុំដឹងម្ដាយខ្ញុំប្រាប់ថា ម្ដាយខ្ញុំកើតនៅស្រុកយួន ប៉ាខ្ញុំនៅស្រុកខ្មែរ។

**ស៖** តើលោកស្រីដឹងទេ ម្ដាយរបស់លោកស្រីហ្នឹង មករស់នៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំណាដែរ?

**ឆ៖** កាលណោះខ្ញុំនៅតូចៗ។

**ស៖** ព្រឹកមិញនេះ លោកស្រីបានបញ្ជាក់ជូនតុលាការថា ឪពុកមា ម្ដាយមីងដែលរស់នៅក្នុងគ្រួសារ គេចោទថាជាជនជាតិវៀតណាម ពីព្រោះគាត់និយាយភាសាខ្មែរមិនច្បាស់ ដោយរដឹន។ តើលោកស្រីបានដឹង ឬទេថាតើខ្មែរក្រហមគេប្រើពាក្យពេចន៍ ឬក៏គេមានសារអ្វីដែលឲ្យលោកស្រីដឹងថាអាចកំណត់ថាអ្នកណាជាជនជាតិវៀតណាម? អ្នកណាជាជនជាតិអ្វីនោះ?

**ឆ៖** ចាស នាងខ្ញុំបានដឹងម្ដាយឪពុកខ្ញុំនៅនឹងយួរដែរហើយ គេអីមិនដឹង គេនិយាយខ្មែរអត់ច្បាស់ផង ទាំងខ្ញុំអី គេដឹងតែយួនហើយ ហើយប៉ាខ្ញុំចិនក៏និយាយខ្មែរអត់សូវច្បាស់។ ខ្ញុំនិយាយតែចិន-យួន។

**ស៖** ចុះម្ដាយរបស់លោកស្រី តើគាត់និយាយភាសាខ្មែរច្បាស់ដែរឬទេ គឺឬក៏គាត់និយាយភាសាខ្មែររដឹន?

**ឆ៖** ចាស ម្ដាយនាងខ្ញុំនិយាយខ្មែរអត់ច្បាស់ទេ ប៉ែឡាំៗហ្នឹង។

**ស៖** លោកស្រីបញ្ជាក់ព្រឹកមិញថា គេបានបំបែកលោកស្រីពីក្រុមគ្រួសារ នៅពេលដែលគេបញ្ជូនពួកគាត់ទៅធ្វើកងចល័តនៅឆ្នាំ១៩៧៦។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

[១៣:៤២:៤៩]

**ស៖** បន្ទាប់ពីគេបញ្ជូនលោកស្រីទៅស្រុកព្រៃនប់ តើលោកស្រីធ្លាប់បានដឹងទេ ថាតើខ្មែរក្រហម ជាពិសេសគឺជនជាតិវៀតណាម ខ្មែរក្រហមគេប្រព្រឹត្តដូចម្តេច ឬក៏គេប្រព្រឹត្តលើជនជាតិវៀតណាម ខុសពីប្រជាជនខ្មែរដែរឬទេនៅពេលនោះ នៅព្រៃនប់?

**ឆ៖** ចាស កាលហ្នឹង ខ្ញុំបានឮដំណឹងម្តាយខ្ញុំគេយកវ៉ៃចោលហើយ ដល់ពេលរួចហ្នឹង គេប្រព្រឹត្តធ្វើបាបខ្ញុំ ឱ្យខ្ញុំធ្វើការ គេឱ្យខ្ញុំហូបមិនឆ្អែត ឡើងខ្ញុំតូចចិត្តខ្លួនឯង ពេលម្តាយស្លាប់ហើយគេដឹងយើងកូនជនជាតិវៀតណាម គេធ្វើបាបយើងឡើងស្គម ឱ្យយើងហុតបបរមួយវែកប្អូនដប់ម្នែនាក់ ហើយរាវៗ គេដឹងយើងជាជនជាតិវៀតណាម គេធ្វើបាបយើងដែរ។ រហូតដល់សព្វថ្ងៃហ្នឹង ខ្ញុំតូចចិត្តឡើងចុកចាប់ក្នុងខ្លួនរកអីប្រៀបមិនបានទេ។ បាយជាមួយអំបិលៗវេចក្នុង ដាក់លាក់ក្នុងខោអាវ អត់ហ៊ានឱ្យគេដឹងទេ អត់មានអីហូបទេ គេធ្វើបាបខ្ញុំជាខ្លាំងឡើងស្គមរីងរៃ ប្អូនខ្ញុំវិញនៅតែគូទ ដូចចង្ក្រានអីចឹង បីជ្រុងឡើងស្គម។ ដល់ខ្ញុំនឹកឃើញរាល់ថ្ងៃស្លាប់ក៏ស្លាប់ទៅ ខ្ញុំឈប់ខ្លាចហើយ ចេះហេតុអីខ្ញុំចេះនៅរស់បានដល់សព្វថ្ងៃហ្នឹង។

**ស៖** លោកស្រីទើបតែបញ្ជាក់ប្រាប់តុលាការថា ដែលគេថាដឹងថាម្តាយរបស់លោកស្រីជាវៀត-ណាម គេមិនឱ្យរបបអាហារគ្រប់គ្រាន់។ តើលោកស្រីបានដឹងដែរឬទេ ថាតើពេលដែលគេដឹងថាអ្នកណាផ្សេងទៀតគេរកឃើញថាជាជនជាតិវៀតណាម ហើយក៏គេឱ្យអាហារតិចតួច របបអាហារតិចតួចទៅអ្នកទាំងអស់នោះ ដូចលោកស្រីដែរ ឬក៏លោកស្រីដឹងបែបនេះដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ ត្រង់ឃើញធ្វើការរាល់តែថ្ងៃ កងចល័តខ្ញុំហូបតែបបរ ដីកប្រឡាយក៏ហូបបបរ ជួនណាអត់មានទឹកផឹក ផឹកតែទឹកប្រៃ។ ឱ្យតែជនជាតិវាងចិនសបន្តិចហ្នឹង គេធ្វើបាបមាំណាស់។ អត់ឱ្យមាននេះទេ ជីកប្រឡាយ ហើយឱ្យធ្វើស្អីៗក៏ខុសគេដែរ ឡើងពិបាកវេទនានិយាយណាស់។

[១៣:៤៦:២១]

**ស៖** បន្ទាប់ពីលោកស្រីបានចូលកងចល័តនៅក្នុងឆ្នាំ១៩៧៦ តើលោកស្រីធ្លាប់បានជួបការប្រជុំណាមួយដែរឬទេ?

**ឆ៖** បានយូរៗប្រជុំម្តង ឱ្យយើងប្តេជ្ញាចិត្ត ខំធ្វើការ។ អ្នកណាអត់ធ្វើការ ប្រយ័ត្នវ៉ៃចោល តែប៉ុណ្ណឹង ប្រជុំតែប៉ុណ្ណឹង អត់មានប្រជុំអីផង។ ឱ្យយើងប្តេជ្ញាចិត្តខំធ្វើការ ខ្ញុំខិតខំធ្វើការ ខ្ញុំខ្លាចគេវ៉ៃ គេវ៉ៃខ្ញុំងាប់ទៀត ខ្ញុំចេះតែខំទៅ។ ខំដល់នៅស្បែកហើយឆ្អឹង។ ខ្ញុំរាល់តែថ្ងៃ នឹកឃើញការឈឺចាប់យ៉ាងខ្លាំង ខ្ញុំឈឺចាប់ខ្លាំង ត្រង់ប្តីខ្ញុំស្លាប់។ រាល់ថ្ងៃក៏ខ្ញុំនៅឈឺចាប់នឹកឃើញ ម្តាយឪពុកស្លាប់ហើយ ប្តីស្លាប់ទៀត

ប្អូនដប់ឆ្នាំចោលខ្ញុំ យំរហូតតាំងពីព្រៃនគរមកដល់ផ្ទះសព្វថ្ងៃហ្នឹង ខ្ញុំកំសត់មាំណាស់ ខ្ញុំមិនចង់និយាយទេ ខ្ញុំនិយាយខ្ញុំទឹកភ្នែកហើយ។

**ស៖** តើលោកស្រីនៅចងចាំដែរឬទេ ថាតើគេនិយាយពាក្យពេចន៍ដូចម្ដេចខ្លះចំពោះប្រជាជនដែលមានជាតិពន្ធុ ឬក៏មានជនជាតិជាវៀតណាម?

**ឆ៖** ស្ដាប់អត់បានត្រង់កន្លែងហ្នឹង។

**ស៖** គឺថាលោកស្រីបានបញ្ជាក់ថា ម្ដងម្កាលគេហៅលោកស្រីទៅប្រជុំពេលដែលនៅកងចល័ត។ ខ្ញុំចង់ដឹងថាតើលោកស្រីបានចាំដែរឬទេ តើក្នុងការប្រជុំទាំងនោះគេមាននិយាយអ្វីខ្លះ ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមដែរឬទេ?

**ឆ៖** និយាយដែរ។ គេឃើញខ្ញុំនិយាយខ្មែរអត់ច្បាស់ គេថា អ្អែងខំនិយាយនៅជាមួយគ្នាកងហ្នឹង ខំនិយាយឲ្យច្បាស់ទៅ។ គេខ្សឹបគ្នា ទៅប្រជុំ ប្រជុំតែយប់ទេ អត់មានប្រជុំថ្ងៃទេ។ មកពីធ្វើការម៉ោងប្រាំ ល្ងាចហូបបាយហើយម៉ោងប្រាំពីរអីបានៗប្រជុំ។ ប្រជុំផងមូសខាំផង អីផង គេអត់ដែលមានប្រជុំផង ខ្ញុំប្រជុំតែយប់។ គេថា យើងខំប្ដេជ្ញាចិត្តធ្វើការរាល់តែថ្ងៃ ខំអ្នក កុមារនៅកងមកពីស្រែអំបិល អី តូចៗគ្នាខ្វាក់ភ្នែក ខ្វាក់មាន់អី រុកគ្នាចង់ងាប់ចង់រស់ហើយ ខ្ញុំឃើញ។ រាល់តែថ្ងៃខ្ញុំឡើងរន្ធត់ ខ្ញុំភ័យ ខ្ញុំឃើញកុមារ ក៏ខ្ញុំភ័យយ៉ាងខ្លាំង។ កុមារខ្វាក់មាន់ ក៏រុកគ្នា ខ្ជិលធ្វើការ គេថា។ គេដាក់ទោស គ្នាកំព្រាម៉ែ កំព្រាឪមកនៅកុមារ នៅកង។ ខ្ញុំឃើញអីចឹង ក៏ខ្ញុំខ្លាច។ មានប្រជុំអី ប្រជុំតែប្ដេជ្ញាចិត្តខំធ្វើការហ្នឹង មានប្រជុំអីផង។ តែអត់ធ្វើការ មានតែគេយកវៃចោល។

[១៣:៥០:០៨]

**ស៖** ព្រឹកមិញ លោកស្រីរៀបរាប់ប្រាប់តុលាការអំពីហេតុការណ៍ដែលកើតឡើងនៅស្រែចាម ពេលដែលលោកស្រីទៅលេងឪពុកម្ដាយ ហើយបានដឹងពីអ្នកភូមិថា គេយកពួកគាត់ទៅសម្លាប់នៅគុកខ្សឹង។ ហើយបន្ទាប់ពីសម្រាកព្រឹកមិញនេះ លោកស្រីបានបញ្ជាក់ថា លោកស្រីបានទទួលព័ត៌មានថាពួកគាត់បានត្រឡប់ទៅប្រទេសវៀតណាម។ សូមលោកពន្យល់ម្ដងទៀត ថាតើៗមានន័យដូចម្ដេច ដែលលោកស្រីថា លោកស្រីបានទទួលដំណឹងថាគេបញ្ជូនគាត់ទៅត្រឡប់ទៅវៀតណាមវិញនោះ?

**ឆ៖** ចុងក្រោយមក ខ្ញុំទទួលដំណឹងអ្នកកោះខ្សឹង អ្នកស្រែចាមអីគេថា ចាស់ទុំហ្នឹងគេថា គេយកម៉ែអ្អែងទៅស្រុកយួន ខ្លះគេថាយកទៅវៃចោល ប៉ុន្តែខ្ញុំដឹងថាយកទៅវៃចោលហើយ អត់មានទៅស្រុកយួនទេ ម៉ែខ្ញុំខំស្រែកផ្ដាំប្រាប់គេថាឲ្យជួយមើលខ្ញុំផង ម៉ែទៅហើយ ម៉ែអត់បានថែរក្សាកូនទេ។ ម៉ែ

ខ្ញុំស្រឡាញ់កូនណាស់ កូនពេលក្តៅរងា ម៉ែអង្អែល ផ្ទិតមួយពីអាពត ផ្ទិតមួយបក់រហូតមួយយប់ទល់ភ្លឺ។ ខ្ញុំអត់ចង់និយាយរឿងម៉ែខ្ញុំពុកខ្ញុំទេ។ រហូតដល់សព្វថ្ងៃហ្នឹង ខ្ញុំកំព្រាឪពុកម្តាយរហូត បងប្អូន មាសកាក់អីទៅអស់អត់មានសល់ នៅក្បាលតែមួយ ក្រវាល់ថ្ងៃ ក្ររហូត។ ខ្ញុំនិយាយរាល់ថ្ងៃ និយាយពិតប្រាកដ ខ្ញុំអត់ចេះនិយាយបំផ្លើសទេ។

[១៣:៥២:៣៧]

**ស៖** ខ្ញុំយល់លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ សូមអភ័យទោសចំពោះសំណួរទាំងអស់នេះដែលធ្វើឲ្យលោកស្រីមានការលំបាកក្នុងការនិយាយ ហើយខ្ញុំសូមជម្រាបថា ខ្ញុំមិនសួរសំណួរនេះទេលើកលែងតែករណីនោះវាមានសារៈសំខាន់ណាស់ ហើយក៏សូមអភ័យទោសដែលខ្ញុំសួរលោកស្រីទៅលើចំណុចដែលមានការលំបាកដល់លោកស្រី។ សូមលោកស្រីជម្រាបតុលាការអំពីឆ្នាំដែលលោកស្រីត្រឡប់ទៅស្រែចាម ដើម្បីទៅមើល -- ទៅលេងក្រុមគ្រួសារកាលនោះ នៅក្នុងឆ្នាំណា?

**ឆ៖** កាលឆ្នាំចុង៧៨ ចូល៧៨ ខ្ញុំបានទៅៗ ក៏ទៅអត់ជួបឪពុកម្តាយញាតិមិត្តបងប្អូនខ្ញុំ ក្មួយខ្ញុំ ខ្ញុំទៅឃើញផ្ទះនៅរលីង ទទេ។ ខ្ញុំក៏នៅដល់ល្ងាច ចាំថ្ងៃល្ងាចហ្នឹងក៏គេសហករណ៍គេមក ចាស់ៗមកពីធ្វើការមក គេលួចប្រាប់ថា ម៉ែឪអ្អែង គេយកទៅវៃចោលហើយ យំស្រែកពេញផ្លូវ ស្រែកជួយផងស្រែកជួយប្រាប់កូនខ្ញុំ មួយ ផង។ ខ្ញុំច្បាស់ថាស្លាប់ហើយ។ រលីងជាង១០នាក់ ទាំងបងទាំងប្អូន ជីដូនមួយខ្ញុំទៀត ខ្ញុំមិននិយាយទេ និយាយតែបងបង្កើតប្អូនបង្កើតមួយម៉ែឪ។ ខ្ញុំដឹងថាងាប់ហើយ ម៉ែខ្ញុំដើរស្រែកពេញព្រៃពេញផ្លូវយកទៅកោះខ្សងនៅចុងជ្រោយ កន្លែងហ្នឹងយកសម្រាប់វៃមនុស្ស។ ស្លាប់ពេញកៀនហ្នឹងទាំងអស់។ ខ្ញុំបានយល់សប្តិ ថាម៉ែខ្ញុំក្លាយជាក្រពើទៀតហើយ ខ្ញុំយល់សប្តិអីចឹង ដល់ពេលខ្ញុំថា បែបគេយកម៉ែខ្ញុំយកទម្លាក់ទឹកហើយ។ អីចឹងបានខ្ញុំមិនចង់និយាយ នឹកដល់ ខ្ញុំខ្លោចចិត្ត និងឈឺចាប់រកអីប្រៀបមិនបានទេ។ កូនមាន់មួយងាប់ឲ្យចំណីស៊ី ងាប់នៅស្តាយ ទម្រាំជីវិតមនុស្ស ជីវិតម៉ែឪបងប្អូន។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីធ្លាប់ចាំឈ្មោះអ្នកណាម្នាក់នៃអ្នកកងឈ្លបដែលមកយកសមាជិកក្រុមគ្រួសារលោកស្រីចេញទៅដែរឬទេ?

**ឆ៖** ខ្ញុំមិនស្គាល់ទេ តែខ្ញុំស្គាល់ វឿន សន ហ្នឹងមួយ គេនៅកង -- សហករណ៍ មេសហករណ៍ឈ្មោះ តាវឿន សន ហើយកងទ័ពគេប្អូនប្រាំនាក់ជាមួយគាត់ហ្នឹង។ ពួគេចាស់ៗ អ៊ំជ្រុញ ហ្នឹង អ៊ំជ្រុញហ្នឹងគាត់ប្រាប់អីចឹង គាត់លួចប្រាប់ខ្ញុំ។

[១៣:៥៦:៣៧]

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលលោកស្រីនៅស្រុកព្រៃនប់ តើលោកស្រីបានដឹង ថាតើខ្មែរក្រហមបានធ្វើបញ្ជី ឬក៏កត់ត្រាពួកប្រជាជនវៀតណាម ឬក៏ជនជាតិភាគតិចអ្វីដែរ ឬទេ កាលនោះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ខ្ញុំនៅកងចល័តៗគេមានអ្នកណាដឹង កងចល័តគេកត់ដែរ តែឥឡូវខ្ញុំភ្លេចហើយ នៅសហករណ៍ខ្ញុំម៉េចដឹង បើមិនដែលបាននៅផ្ទះផងហ្នឹង។ យូរៗទៅ មួយឆ្នាំ កន្លះឆ្នាំបានទៅផ្ទះមួយភ្លែតៗហ្នឹង។

**ស៖** ខ្ញុំនឹងអានសេចក្តីដកស្រង់ពីរ អំពីកំណត់ហេតុស្តាប់ចម្លើយមនុស្សមួយចំនួននៅព្រៃនប់ ដើម្បីរំឭកការចងចាំរបស់លោកស្រី អំពីការប្រមូលបញ្ជី ការចុះបញ្ជី គឺឯកសារ E3/5506 ជាចម្លើយ -- កំណត់ហេតុស្តាប់ចម្លើយរបស់ សៅ ផន។ ហើយគាត់និយាយថា កាលនោះគាត់នៅស្រែចាម នៅស្រុកព្រៃនប់ ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ហើយបានឃើញគេយកមនុស្សជាច្រើន យកទៅគុកកោះខ្យង។ នៅក្នុងសំណួរចម្លើយ១៩ និង២០ គាត់និយាយថា -- ដែលខ្ញុំត្រូវផ្តោតអារម្មណ៍ទៅលើសំណួរទី២នេះ។ ចម្លើយទី១៩៖ “នៅពាក់កណ្តាលឆ្នាំ១៩៧៧ គឺមានការឃោសនា គឺថាគេនឹងប្រមូលជនជាតិវៀតណាមឲ្យត្រឡប់ទៅប្រទេសវៀតណាមវិញ ហើយៗនិងក្រុមគ្រួសារមួយចំនួនដែលនៅវៀតណាម ហើយនៅក្នុងសហករណ៍របស់ខ្ញុំ មានសមាជិកជនជាតិវៀតណាម១០គ្រួសារ ហើយនិង -- ហើយអ្នកទាំងអស់នោះ គេត្រូវចុះឈ្មោះអ្នកទាំងនោះ ហើយគេបានប្រមូលអ្នកទាំងនោះ ហើយដឹកតាមឡាន ហើយក្រោយមក គឺគេដឹកប្រជាជនវៀតណាមទាំងអស់នោះ យកចេញទៅ ហើយយកសម្លាប់ចោល។ សំណួរ៖ តើៗបានឃើញគេសម្លាប់ដែរឬទេ? គាត់ឆ្លើយថា៖ គាត់បានឃើញគេចងដៃ ហើយដើម្បីដឹកតាមឡានហ្សេអឹមសេ ទៅកោះខ្យង។”

[១៣:៥៩:១១]

បាទ ហើយនៅក្នុងចម្លើយ គឺ E3/5501 ជាបទសម្ភាសន៍របស់ ឈុន លន ជាអនុប្រធានភូមិនៅស្រុកព្រៃនប់ អង់គ្លេស ERN 00373309, ខ្មែរ 00368651, បារាំង ERN 00426222។ ហើយគាត់និយាយដូចតទៅនេះ៖ “គេឲ្យខ្ញុំប្រមូលស្ថិតិប្រជាជនជាឧទាហរណ៍ មានចាមប៉ុន្មាន ចិនប៉ុន្មានហើយយួនមានប៉ុន្មាន ខ្មែរកម្ពុជាក្រោមប៉ុន្មាន។ បន្ទាប់ពីធ្វើបញ្ជីរួច ខ្ញុំបញ្ជូនបញ្ជីនោះទៅគណៈស្រុកតាចិន។ ហើយគាត់និយាយថា ខាងក្រោមបន្តិចហ្នឹង នៅអង់គ្លេស ERN00373310, ខ្មែរ 00368653

បារាំង 00426224 ហើយគាត់និយាយថា សូមដកស្រង់៖ “នៅពេលនោះ ជនជាតិយួនខ្មែរកម្ពុជាក្រោមត្រូវបានគេចាប់ទាំងអស់ ហើយយកទៅសម្លាប់ចោល អ្នកការ -- គេចាប់អ្នកទាំងនោះនៅពេលយប់ ហើយអ្នកទាំងអស់នោះត្រូវគេបញ្ជូននៅទីសន្តិសុខកោះខ្យង។” ហើយនេះជាសេចក្តីដកស្រង់រាងវែងបន្តិច ហើយបុគ្គលពីរនាក់នេះគឺម្នាក់ចុងក្រោយ គាត់និយាយអំពីថា គាត់ធ្វើបញ្ជី ហើយគេប្រមូលជនជាតិវៀតណាម ហើយគេដឹកយកទៅកោះខ្យង ហើយយកទៅសម្លាប់នៅទីនោះ។ តើអាចធ្វើឱ្យលោកស្រីនឹកឃើញ ឬក៏ចងចាំដែរឬទេថានៅព្រៃនប់កាលណោះ ក៏គេមានធ្វើបញ្ជីពីជនជាតិវៀតណាមក្រោយមកគេប្រមូលទៅដាក់មន្ទីរសន្តិសុខ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប។ អញ្ជើញលោកមេធាវីគង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ លើមូលដ្ឋានពីរ ទី១ ដូចសហព្រះរាជាអាជ្ញារងអន្តរជាតិបានលើកថាវាវែងពេកការដកស្រង់នេះ ហើយទី២ ខ្ញុំធ្លាប់ជំទាស់រួចហើយ គឺថាអង្គហេតុដែលសហព្រះរាជអាជ្ញាលើកយកមកសួរនេះ វាជាអង្គហេតុទូទៅ ដែលមិនទាក់ទងទៅនឹងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងទេ ហើយបើសិនជាព័ត៌មានដែលអាចឧទាហរណ៍ លោកស្រីគាត់បានរស់នៅកោះសេះដែលមិនជាកោះខ្យងទេ ហើយព័ត៌មានដែលអ្វីដែលអ្នកស្រីនឹងផ្តល់នៅពេលនេះ វាគ្រាន់តែជាការ វាយប្រមាណ វាយស្មានទៅលើអង្គហេតុ ដែលជាអង្គហេតុទូទៅមិនជាប់ពាក់ព័ន្ធទៅនឹងការឈឺចាប់ផ្ទាល់របស់អ្នកស្រី។ បាទ សូមអរគុណ។

[១៤:០២:២៣]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ ទី១ ពាក់ព័ន្ធទៅនឹងបញ្ហាសម្រង់ថាវែងពេកនេះ គឺថាអង្គជំនុំជម្រះមិនដែលកំណត់អំពីការដកស្រង់នេះថាវែងខ្លីនោះទេ ហើយការជំទាស់ទី២ ពាក់ព័ន្ធទៅនឹងថាវាទូទៅពេក ក៏ប៉ុន្តែតាមពិតខ្ញុំសួរជាក់លាក់ដែលទីកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណី គាត់ប្រាប់ថា គាត់បានធ្វើដំណើរទៅកោះសេះ ខុសពីអ្វីដែលមេធាវីការពារក្តីបានជំទាស់នេះ គឺនៅមុនឆ្នាំ១៩៧៥ ដែលខ្មែរក្រហមបានបង្ខំគាត់ឱ្យចាកចេញពីទីនោះ។ ដូច្នេះ ខ្ញុំសូមអង្គជំនុំជម្រះអនុញ្ញាតឱ្យខ្ញុំបន្តការតាំងសំណួរទៅទៀត។

[១៤:០៥:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៩:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ករណីនេះអង្គហេតុ អ៎! អង្គជំនុំជម្រះសម្រេចថា បដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក គង់ សំអុន ចំពោះសំណួរនេះ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីអាចឆ្លើយតបនឹងសំណួរនេះ បើសិនបើលោកស្រីចងចាំនូវសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ប៉ុន្តែសហព្រះរាជអាជ្ញាគួរគប្បីតាំងសំណួរចុងក្រោយរបស់លោក ដើម្បីបន្ត មិនបាច់ដកស្រង់ទេ គឺសំណួរ បំណងនៃការតាំងសំណួររបស់លោកចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះឡើងវិញ ដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីគាត់យល់បាន ហើយនិងគាត់អាចឆ្លើយតបទៅនឹងសំណួររបស់លោកបាន។

**លោក ចូសេហ្វ អេនឌ្រូ ប៊ីយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ីយលី៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំនឹងមិនអានសម្រង់ដ៏វែងនេះទៀតទេ ប៉ុន្តែសម្រង់នេះបានរៀបរាប់អំពីការរៀបចំបញ្ជីឈ្មោះជនជាតិវៀតណាមនៅក្នុងស្រុកព្រៃទប់ ហើយនិងការប្រើប្រាស់បញ្ជីនេះ ដើម្បីធ្វើការចាប់ខ្លួន។ តើបញ្ជីនេះឈ្មោះជនជាតិវៀតណាម ឬក៏ជនជាតិភាគតិចដែលត្រូវបានគេរៀបចំឡើងនៅឯស្រុកព្រៃទប់ហ្នឹង ជួយរំឭកដល់ការចងចាំរបស់លោកស្រីទេ?

**លោកស្រី ខូង មួយ៖**

**ឆ៖** ខ្ញុំសូមនិយាយម្ដងទៀត ភ្លេចទៅ អត់នឹកឃើញ។ សំណួរហ្នឹងនិយាយម្ដងទៀត។

**ស៖** មិនថ្វីទេលោកស្រី។ ប៉ុន្មាននាទីមុននេះ ខ្ញុំបានអានចម្លើយរបស់បុគ្គលម្នាក់ដែលនៅក្នុងសំណុំរឿងនេះដែរ ដែលគាត់រៀបរាប់អំពីស្រុកព្រៃទប់។ គាត់ថានៅស្រុកព្រៃទប់ហ្នឹង គេធ្វើបញ្ជីឈ្មោះជនជាតិវៀតណាម គេប្រើបញ្ជីឈ្មោះជនជាតិវៀតណាមហ្នឹង គឺខ្មែរក្រហមគេយកបញ្ជីឈ្មោះហ្នឹងយកទៅចាប់ខ្លួនមនុស្ស។ តើលោកស្រីរកនឹកឃើញទេ ថាគេមានរៀបចំធ្វើបញ្ជីឈ្មោះនៅស្រុកព្រៃទប់ដើម្បីចាប់ខ្លួនជនជាតិវៀតណាមនោះ?

[១៤:១២:១៣]

**ឆ៖** សូមទោស ខ្ញុំអត់ដឹងដែរ អត់បានដឹង។ ខ្ញុំនៅកងចល័ត គិតតែពីធ្វើការ អត់ដឹងដែរ។

**ស៖** សូមអរគុណលោកស្រី។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

លោកប្រធានខ្ញុំឃើញថាជិតដល់ពេលម៉ោងខ្ញុំត្រូវអស់ហើយ ក៏ប៉ុន្តែខ្ញុំនឹងមិនសួរ មិនលើស១០ នាទីទៀតទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ព្រឹកមិញនេះ លោកស្រីបានឆ្លើយថា អ្នកភូមិដែលបានប្រាប់លោកស្រីថា គ្រួសាររបស់គាត់ត្រូវបានគេយកទៅកោះខ្យង ហើយលោកស្រីក៏បានឆ្លើយថានៅទីនេះគឺជាគុក។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេ ថាអង្គភាព ឬក៏កងណា ឈ្មោះអី របស់ខ្មែរក្រហមហ្នឹង ដែលទទួលបន្ទុកផ្នែកសន្ដិសុខនៅកោះខ្យងហ្នឹង?

[១៤:១៣:២៦]

**លោកស្រី ខួង មួយ៖**

**ឆ៖** ចាស នាងខ្ញុំអត់ដឹងទេ។ គ្រាន់ដឹងថាអ្នកភូមិនៅជិតម្ដាយខ្ញុំហ្នឹង ឮដំណឹងគេខ្សឹបប្រាប់ថា នៅកោះខ្យង ម្ដាយអ្នែងគេយកទៅកោះខ្យងហ្នឹង។ ខ្ញុំដឹងដែរកន្លែងហ្នឹងមានគុកសម្រាប់វ៉ៃមនុស្សដាក់ខ្នោះ កន្លែងហ្នឹងយ៉ាងច្រើន មនុស្សស្លាប់ច្រើនណាស់កន្លែងហ្នឹង។ ម៉ែខ្ញុំក៏គេយកទៅហ្នឹងដែរ បងប្អូនខ្ញុំទាំងអស់។

**ស៖** ខ្ញុំសូមអានសម្រង់នៃកិច្ចសម្ភាសន៍របស់សាក្សីម្នាក់ដើម្បីរំឭកដល់ការចងចាំរបស់លោកស្រី គឺ E3/7750, ERN ជាភាសាអង់គ្លេស 00275052, ខ្មែរ 00206377, បារាំង 00275063។ នេះគឺជាអ្នកទោសស្រីម្នាក់នៅមន្ទីរសន្ដិសុខកោះខ្យង ដែលបានឃើញជនជាតិវៀតណាមនៅទីនោះ គាត់បានឆ្លើយថា គាត់ត្រូវបានកងទ័ពពីរនាក់មកពីកងពលលេខ១ ចាប់ខ្លួនគាត់។ តើចំណុចនេះជួយរំឭកដល់ការចងចាំរបស់លោកស្រីទេថា គុកកោះខ្យហ្នឹងគឺគ្រប់គ្រងដោយកងពលលេខ១?

**ឆ៖** ចាស គុកកោះខ្សង--

**ប្រធានអង្គជំនុំ៖**

កុំៗអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះដដែល ហើយខ្ញុំយល់ថាវាជាសំណួរដែលនិយាយអំពីរៀបចំសវនាការជាទូទៅ។ ហើយយើងនៅពេលនេះយើងរៀបចំសវនាការជាលក្ខណៈពិសេស ដោយផ្ដោតទៅលើផលប៉ះពាល់ និងការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយដែលកាលណាយើងនិយាយអំពីអង្គហេតុដែលជាប់ទាក់ទងទៅនឹងបទចោទដែលត្រូវសាក្សីឡើងមកបង្ហាញក្នុងលក្ខខណ្ឌនៃសវនាការធម្មតានោះ វាធ្វើឱ្យមានការលំបាកក្នុងការសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដែលលោកស្រីមកបង្ហាញនៅទីនេះ គឺបង្ហាញលក្ខណៈការឈឺចាប់ទៅលើអំពើដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនិងអង្គហេតុដែលប៉ះពាល់ផ្ទាល់ដល់រូបលោកស្រី មិនមែនអង្គហេតុជាលក្ខណៈទូទៅនោះទេ។ បាទ សូមអរគុណ។

[១៤:១៦:២២]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ការជំទាស់ប្រហាក់ប្រហែលគ្នានេះ ក៏បានលើកឡើងកាលពីម្សិលមិញផងដែរ។ បញ្ហានេះ គឺថាកើតមានឡើងម្ដងហើយម្ដងទៀត ហើយក៏មាន -- ដើមបណ្ដឹងរដ្ឋប្បវេណីក៏លើកឡើងនៅពេលដែលគាត់រៀបរាប់អំពីការឈឺចាប់របស់គាត់រួចមកហើយផងដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៧:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា ការជំទាស់របស់មេធាវី គង់ សំអុន ហ្នឹងគឺមានមូលហេតុសមស្រប ហើយ ហើយតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិចូលពិនិត្យមើលនូវខ្លឹមសារនៃសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E315/1 ត្រង់កថាខណ្ឌ៨ ដែលចែងច្បាស់អំពីបញ្ហានេះថា អនុលោកតាមការអនុវត្តនេះ អង្គជំនុំជម្រះនឹងតម្រូវឱ្យការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីកម្រិតត្រឹមតែអង្គហេតុទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២ ប៉ុណ្ណោះ។ រីឯការធ្វើសេចក្ដីថ្លែង

ទូទៅពីការឈឺចាប់មិនតម្រូវឲ្យធ្វើការបែងចែកដាច់ពីគ្នារវាងព្យសនៈកម្មដែលកើតមានឡើងដោយអង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពក្នុងរឿង និងព្យសនៈកម្មទូទៅដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ដូច្នេះសូមលោកគិតអំពីចំណុចនេះ ហើយរៀបចំសំណួរណាដែលមានការពាក់ព័ន្ធដែលត្រឹមត្រូវតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងបញ្ហានេះ។

យើងកន្លងមក យើងបានអនុញ្ញាតកាលពីម្សិលមិញ ដោយសារសំណួរមានលក្ខណៈជាការចង់បញ្ជាក់អំពីទម្រង់នៃការអនុវត្តគោលនយោបាយ ចំពោះការប្រព្រឹត្តក្រុមគោលដៅជាក់លាក់។ អ៊ីចឹងហើយយើងបានបញ្ជាក់ម្សិលហើយថាជារឿងសំណួរដែលពាក់ព័ន្ធ ទំនងជាមានការឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយចំពោះក្រុមគោលដៅជាក់លាក់ប៉ុណ្ណោះ។ ចំណែកឯកអង្គហេតុអំមិញនេះ គឺការសំណួរអំមិញនេះ គឺវាមិនឆ្លុះបញ្ចាំងអំពីអង្គហេតុចំពោះគោលដៅជាក់លាក់ចំពោះជនជាតិចាម ឬចំពោះជនជាតិវៀតណាមទេ។

ដើមបណ្តឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយនឹងសំណួរនេះទេ!

[១៤:១៩:៤៧]

**លោក ចូសេហ្វ អេនគូ្រ បិយលើ៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាខ្ញុំឆ្លើយតបទៅវាមិនច្បាស់ក៏មិនដឹង បញ្ហានេះពាក់ព័ន្ធទៅនឹងការកំណត់គោលដៅមកលើជនជាតិវៀតណាមហើយ ជាពិសេស ខ្ញុំរៀបនឹងរៀបរាប់អំពីមន្ទីរសន្តិសុខមួយនេះ ដែលត្រូវបានគ្រប់គ្រងចាត់ចែង ហើយត្រូវបានកោះហៅមកធ្វើជាសាក្សីនៅក្នុងសវនាការផ្នែកនេះផងដែរ។ ហេតុដូច្នេះឯងទើបខ្ញុំសួរ ហើយដើមបណ្តឹងរដ្ឋប្បវេណី ក៏បានឆ្លើយថា គ្រួសាររបស់គាត់ក៏ត្រូវបានគេនាំខ្លួនយកទៅមន្ទីរសន្តិសុខមួយនេះ ហើយសម្លាប់ចោលនៅទីនោះ។ អ៊ីចឹងសក្ខីកម្មរបស់គាត់នេះ គឺថាវាជាសក្ខីកម្មមួយដែលពាក់ព័ន្ធទៅនឹងសវនាការផ្នែកនេះ គឺការកំណត់គោលដៅមកលើជនជាតិវៀតណាម ក្នុងសំណុំរឿង០០២/០២ នេះឯង។ ហើយខ្ញុំនឹងបន្តសួរទៅមុខទៀត ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខមួយនេះ។

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតទេ ដរាបណាសំណួរជាក់លាក់ដែលលោកបាននិយាយហ្នឹង គឺពាក់ព័ន្ធជាមួយនឹងអង្គហេតុ។ យើងបានប្រាប់ហើយថា សំណួរទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងការអនុវត្តគោលនយោបាយ ចំពោះគោលដៅជាក់លាក់ វាជារឿងផ្សេងពីសំណួរដែលពាក់ព័ន្ធនឹងអង្គហេតុជាក់លាក់។

ខ្ញុំមិនមែនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២ទេ – ០០២/០២ទេ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណ លោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីធ្លាប់បានដឹង ឬបានឮខ្មែរក្រហមនិយាយគ្នាអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងជនជាតិភាគតិចវៀតណាមដែរទេ?

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស ខ្លួនខ្ញុំឮដែរ ឮថាម្តាយខ្ញុំជនជាតិវៀតណាម ប៉ាខ្ញុំចិន។ គេថា ដឹងថ្ងៃណាគេយកទៅវាយចោល បានខ្ញុំសន្និដ្ឋានថា ច្បាស់ប៉ាខ្ញុំ ម៉ែខ្ញុំ គេយកទៅហ្នឹង ច្បាស់គេសម្លាប់ចោលហើយ។ ដឹងដែរ ឮដែរហ្នឹង។

**ស៖** តើលោកស្រីឮសម្តីនេះ និយាយចេញពីកម្មាភិបាលខ្មែរក្រហម ឬក៏ឮពីអ្នកណា?

**ឆ៖** ចាស នាងខ្ញុំឮពីសហករណ៍ វឿន សន គេធ្វើកាន់កាប់សហករណ៍កងនៅសហករណ៍កងចាស់ៗ។ ខ្ញុំទៅផ្ទះលេងម្តងៗ គេនិយាយតែរហូត។ ខ្ញុំគ្រាន់បាត់ម៉ែខ្ញុំ ខ្ញុំដឹងតែគេយកទៅវាយចោលហើយ។

[១៤:២៣:៣៤]

**ស៖** ចុះលោកស្រីធ្លាប់ឮខ្មែរក្រហមណាម្នាក់និយាយថា ជនជាតិវៀតណាមណាដែលមិនព្រមចាកចេញពីប្រទេសកម្ពុជាទេ នឹងត្រូវកម្ទេចចោលហើយ? ដែលឮអ៊ីចឹងទេ?

**ឆ៖** ឮតើ មុនៗខ្ញុំនៅភូមិខ្ញុំហ្នឹង មានដែរ គេយកទៅមុន កម្ទេចចោលខ្លះហើយ បានខ្ញុំដឹង។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។

សូមអរគុណ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ជាដំបូងនេះផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក លីវ សុវណ្ណា៖**

សូមអរគុណ លោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាសហមេធាវីជាតិនៅក្នុងក្រុមការពារក្ដី លោក នួន ជា។ ខ្ញុំសូមសួរសំណួរលោកស្រីមួយចំនួន។ ទី១ គឺទាក់ទងនឹងការជម្លៀសប្រជាជនវៀតណាមហ្នឹង ចេញពីកោះសេះ--

[១៤:២៥:០០]

**ប្រធានអង្គជំនុំ៖**

បាទ ឈប់ៗផ្អាកបន្តិចសិន អត់មានការបកប្រែជាភាសាអង់គ្លេស។ មន្ត្រីរដ្ឋបាលតុលាការពិនិត្យមើលបញ្ហាបច្ចេកទេស។

អង្គុយសិនចុះ មានបញ្ហាចំណាយពេលរហូតដល់ ប្រាំនាទីឯណោះ។

បាទ ឥឡូវនេះដល់ពេលវេលាសមស្របៗនឹងសម្រាកដែលហើយ ឥឡូវនេះអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

ហើយមន្ត្រីរដ្ឋបាលតុលាការតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងឲ្យជូនគាត់មកកន្លែងផ្ដល់សក្ខីកម្មវិញ នៅម៉ោងបីខ្វះដប់ប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:២៦ នាទី ដល់ម៉ោង ១៤:៤៧ នាទី)*

[១៤:៤៧:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្ដល់វេទិកាទៅក្រុម

សហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក លីវ សុវណ្ណា៖**

អរគុណលោកប្រធាន។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ជាដំបូងនេះសំណួរខ្ញុំផ្តោតទៅលើការជម្លៀសលោកស្រីចេញពីកោះសេះ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើនៅលើកោះសេះនោះមានប្រជាជនរស់នៅប្រហែលជាប៉ុន្មានគ្រួសារដែរតាមការកត់សម្គាល់របស់លោកស្រី?

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំដឹងថាប្រហែល៥០គ្រួសារដែរ មានទាហាន មានអីនៅហ្នឹង។

**ស៖** គ្រួសារទាំងអស់នោះសុទ្ធតែជាគ្រួសារដែលជាគ្រួសារជនជាតិវៀតណាម ឬក៏មានចម្រុះជនជាតិ?

**ឆ៖** មានចម្រុះទាំងអស់ វៀតណាមផង ខ្មែរផង ចិនផង កោះហ្នឹង។

**ស៖** គ្រួសារជាជនជាតិវៀតណាមមានប្រហែលប៉ុន្មានគ្រួសារដែរ?

**ឆ៖** ខ្ញុំអត់សូវដឹងដែរ មានតែគ្រួសារបងថ្លៃខ្ញុំអី ពីរគ្រួសារ បីគ្រួសារ។

**ស៖** តើការជម្លៀសហ្នឹង គេជម្លៀសទាំងអស់គ្នា ទាំងខ្មែរ ទាំងគ្រួសារវៀតណាម ឬមួយក៏គេជម្លៀសតែគ្រួសារវៀតណាម?

**ឆ៖** ចាស ជម្លៀសទាំងអស់ អត់មានថាវៀតណាម ចិន ខ្មែរអី មក កៀងយើងមកទាំងអស់ តែយើងមិនមកបាញ់ទម្លាក់ទឹកងាប់អស់នៅកោះហ្នឹង សុទ្ធតែទឹក។ កៀងយើងមក យើងមិនមកក៏អត់បានដែរ ត្រូវយើងមកតាម មកស្រែចាមហ្នឹង មកទាំងអស់គ្នា។

[១៥:៥0:00]

**ស៖** សំណួរមួយទៀតពាក់ព័ន្ធនឹងប្តីឈ្មោះ ជ្រុន ប្រពន្ធគាត់ឈ្មោះ ផុន។ តើគាត់មានជាប់សាច់ញាតិអីជាមួយលោកស្រីដែរទេ?

**ឆ៖** ចាស អត់ទេ តែគាត់នៅជាប់ផ្ទះម្តាយខ្ញុំឪពុកខ្ញុំ នៅស្រែចាមហ្នឹងនៅជាប់គ្នាហ្នឹង កងជាមួយគ្នា។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមលើកយកឯកសារលេខ E3/5544 ត្រង់ ERN ជាភាសាខ្មែរ មានលេខ 00375532, ERN ជាភាសាបារាំងមានលេខ 00424096, ERN ជាភាសាអង់គ្លេសមានលេខ 00377836 ដែលជាចម្លើយរបស់លោកស្រី កំណត់ស្ដាប់ចម្លើយរបស់លោកស្រីផ្ទាល់។ ក្នុងនោះលោកស្រីបានថ្លែងថា ខ្ញុំសូមដកស្រង់៖ “ពេលល្ងាចមកដល់ ពួកគេមិនបានត្រឡប់មកពីធ្វើការនោះទេ (នៅដើមឆ្នាំ១៩៧៧) ដូច្នេះ ខ្ញុំទៅផ្ទះពូរបស់ខ្ញុំឈ្មោះ ជ្រុន។” តើចម្លើយរបស់លោកស្រីថា ពូរបស់លោកស្រីឈ្មោះ ជ្រុន ហ្នឹងគឺមានន័យថាម៉េចដែរ បាទ?

**ឆ៖** ពូហ្នឹង មានគាត់នៅផ្ទះជាប់ផ្ទះម៉ែខ្ញុំ។

**ស៖** មុននេះ លោកស្រីបានលើកឡើងថា លោកស្រីមានអ៊ំស្រីម្នាក់។ តើអ៊ំស្រីហ្នឹងគាត់ឈ្មោះអី ហើយត្រូវជាយ៉ាងម៉េចជាមួយលោកស្រីដែរ?

**ឆ៖** ចាស អ៊ំហ្នឹងគាត់ អ៊ំផុន ហ្នឹងប្រពន្ធ តាជ្រុន ហ្នឹងគាត់នៅជាប់ផ្ទះម្ដាយខ្ញុំ។

[១៤:៥២:៥០]

**ស៖** ក្រៅពីឪពុកម្ដាយលោកស្រី តើលោកស្រី ម្ដាយលោកស្រីមានបងប្អូនបង្កើត ឬឪពុកលោកស្រីមានបងប្អូនបង្កើតដែរទេ ដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ចាស នាងខ្ញុំ ម្ដាយខ្ញុំអត់ទេ មានតែបងប្អូននៅស្រុកយួន។ ឪពុកខ្ញុំបងប្អូនគាត់ស្លាប់នៅឆ្ងាយៗនៅថ្មសអី ឥឡូវស្លាប់អស់ហើយ។

**ស៖** តាមការកត់សម្គាល់របស់លោកស្រី ប្រជាជនជម្លៀសមកពីកោះសេះ ដែលរស់នៅក្នុងភូមិជាមួយលោកស្រីនៅឯភូមិចាមហ្នឹង តើភូមិស្រែចាម ឃុំស្រែចាម ស្រុកព្រៃនប់ មានគ្រួសារវៀត-ណាមប្រហែលជាប៉ុន្មានគ្រួសារដែរ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយ ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមសិនណ៎ះ!

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំដឹងប្រហែលមានបួនប្រាំគ្រួសារ ទាល់គ្រួសារជីដូនមួយខ្ញុំមួយ ទាល់បងខ្ញុំម្ដាយខ្ញុំ នៅបីគ្រួសារ គេផ្លាស់មកស្រែចាមក្រោមនៅជាមួយគ្នា។ ទាល់ឥឡូវគេយកទៅរំៃចោលទាំងអស់ជាមួយគ្នាហ្នឹង។ ខ្លះទៅនេះ ខ្លះទៅនោះ មិននៅជុំគ្នាទេ។

[១៤:៥៥:០០]

**ស៖** ឥឡូវចូលដល់ប្អូនលោកស្រីដែលលោកស្រីបានមានប្រសាសន៍មុនហ្នឹងថា ប្អូនលោកស្រីនៅកងចល័តមួយផ្សេងពីលោកស្រី។ គាត់ឈ្មោះ ខូង កេង។ អ៊ីចឹងលោកស្រីអាចលើកបានទេ មូលហេតុអីបានជាគេបញ្ជូនគាត់ទៅកងសេរី?

**ឆ៖** ចាស នាងខ្ញុំដឹងថា វានៅបៀតខ្ញុំដែរ ប្រហែល២០០ម៉ែត្រអ៊ីចឹង កងចល័តយុទ្ធជន នៅមួយកន្លែង កងនារីនៅមួយកន្លែង។ ខ្ញុំទៅធ្វើការជួបគ្នារាល់តែថ្ងៃ ខំធ្វើការងារម៉េច វាចោទថា ប្អូនខ្ញុំហ្នឹងសេរី គេយកទៅដើរហើរទៅណា មិនប្រាប់ គេយកទៅ ចាប់ប្អូនខ្ញុំគេយកទៅដាក់កងសេរីហ្នឹង គេហៅកងសេរីហ្នឹង សង្គមហ្នឹងដឹងតែស្លាប់ហើយ។ ដាក់ខ្នោះ ដាក់អីនៅហ្នឹង ធ្វើការក៏ដាក់ខ្នោះយើងដែរ។

**ស៖** ក្រៅពីប្អូនលោកស្រី តើមានជនជាតិខ្មែរណាមួយ គេបញ្ជូនទៅកងសេរីហ្នឹងដែរទេ តាមការកត់សម្គាល់របស់លោក -- របស់លោកស្រី បាទ?

**ឆ៖** ចាស មានច្រើនដែរ អត់មានថាខ្មែរចាមអីក៏មានដែរ ចិនអីក៏មានដែរ យួនអីក៏មានដែរ មានគ្រប់សាសន៍ ឲ្យតែសេរី។

**ស៖** តើកងសេរី គេឲ្យធ្វើអីខ្លះទៅ លោកស្រីបាន ដែលមានបានឃើញ ដែលបានជួបប្រទះនឹងការងាររបស់កងសេរីទេ?

**ឆ៖** ចាស នាងខ្ញុំដឹងនៅបៀតហ្នឹងដែរ។ ដាំដំឡូង ជីកប្រឡាយទំនប់អី គេមានមេគេដឹកនាំយើងទៅធ្វើអ៊ីចឹងទៅ ជីកប្រឡាយ លើកទំនប់អី ដាំដំឡូងអី ក៏គេហៅទៅធ្វើរហូតហ្នឹង។ គេអត់ៗបាយអត់ទឹក ហូបបបរហ្នឹង ចេះតែទៅធ្វើវាល់ៗល្ងាចអ៊ីចឹងទៅ ទៅទាំងអស់ហ្នឹង។

[១៤:៥៧:២៦]

**ស៖** តើលោកស្រីធ្លាប់បានឃើញអ្នកដែលទៅកងសេរីហើយ ហើយបើគាត់កែប្រែខ្លួនហើយ គេបញ្ជូនឲ្យគាត់មកនៅកងចល័តធម្មតាវិញ ដែលឃើញមានដែរទេ?

**ឆ៖** ចាស នាងខ្ញុំតាំងពីសង្គមហ្នឹង ដឹងតែថាទៅកងសេរីហើយ ដឹងតែងាប់ហើយ។ មិនជឿសួរទៅ សួរចាស់ៗទៅ។

**ស៖** អ៊ីចឹងប្អូនរបស់លោកស្រីដែលបញ្ជូនទៅកងសេរីហ្នឹង ដោយសារគាត់ដើរហើរសេរី មិនមានការអនុញ្ញាត។ មិនមែនដោយសារគាត់ជាកូនដែលមានឈាមជ័រឪពុក ឬម្ដាយជាវៀតណាមទេ។ តើអ៊ីចឹងមែនទេ បាទ?

**ឆ៖** ដឹងមិនដឹង ខ្ញុំមិនដឹងទេ ទាស់តែខ្មែរក្រហមហ្នឹងសាហាវណាស់។ តែពេលវាចង់សម្លាប់

យើង វាចោទយើង។ ទោះបីធ្វើការងារសកម្មម៉េច ក៏វាថាយើងម៉េចក៏បានដែរ វាដាក់កងសេរី សេរីម៉េចក៏ស្រេចតែវាទៅ ខ្ញុំម៉េចដឹង។

**ស៖** ចំពោះលោកស្រីផ្ទាល់ នៅក្នុងកងចល័តរបស់លោកស្រីហ្នឹង មានអ្នកដែលមានជាកូនរបស់ឪពុក ឬម្តាយជាវៀតណាមដូចលោកស្រីដែរទេ?

**ឆ៖** ចាស នាងខ្ញុំអត់ដឹងទេ ទាល់មានកូនយាយឃួនម្នាក់ធ្វើកងរយនៅហ្នឹង គេយកម៉ែឪទៅវ៉ៃចោលហើយ នៅ -- ហើយគេមកយកគាត់ទៅវ៉ៃចោលដែរ នៅកងជាមួយខ្ញុំ កងរយ។

[១៥:០០:០៥]

**ស៖** សូមលោកស្រីបញ្ជាក់ពេលដែលលោកស្រីបានទៅត្រឡប់ទៅភូមិស្រែចាម ដើម្បីទៅលេងឪពុកម្តាយលោកស្រីហ្នឹង ពេលហ្នឹងលោកស្រីបានជួប មានបានជួបជាមួយនឹងកម្មាភិបាលរបស់សហករណ៍ ឬក៏កម្មាភិបាលឃុំណាម្នាក់ទេ?

**ឆ៖** ចាស កាលនាងខ្ញុំទៅភូមិសុំមេកងទៅហ្នឹង ខ្ញុំអត់បានជួបទេ។

**ស៖** តើមេកងរបស់លោកស្រីមានដឹងថាលោកស្រីជា មានម្តាយជាវៀតណាមដែរទេ?

**ឆ៖** ខ្ញុំមិនប៉ានប្រាប់ផង ខ្ញុំនៅធ្វើការរាល់ថ្ងៃខ្ញុំមិនប៉ានឈប់ការងារ ធ្វើឡើងស្តមរីងរៃ ខ្ញុំមិនប៉ានប្រាប់គេណា អត់ប៉ានប្រាប់មេកងណា ដឹងមិនដឹងខ្ញុំមិនដឹងដែរ ខ្ញុំអត់ប៉ានប្រាប់គេទេ ខ្ញុំខ្លាចងាប់ដែរ។

**ស៖** មេកងរបស់លោកស្រីនៅក្នុងជាប្រជាជនដែលរស់នៅក្នុងភូមិស្រែចាមដែរ ឬក៏គាត់មកពីភូមិផ្សេង?

**ឆ៖** ចាស មេកងហ្នឹងច្រើនតែមក ម្តុំកោះកុង ស្រែអំបិល ឈ្មោះចែតងហ្នឹង។

**ស៖** ឥឡូវចូលដល់គ្រួសារលោកស្រី រឿងឪពុកៗលោកស្រីគាត់ជា តាមលោកស្រីអះអាងថាជាជនជាតិចិន។ ចុះមានគ្រួសារណាផ្សេងដែលជាជនជាតិចិន ហើយគេយកទៅចាប់ទៅដូចស្ថានភាពដូចគ្រួសារលោកស្រីទេ?

**ឆ៖** ចាស មានតើ មានចិនខ្មែរ ក៏យកទៅខ្លះដែរ ឲ្យតែកូនកាត់ចិន។

[១៥:០៣:១៥]

**ស៖** ឥឡូវត្រឡប់មកគ្រួសារដែលជម្លៀសមកពីកោះសេះ ដែលលោកស្រីមានប្រសាសន៍ថាមានប៉ុន្មានគ្រួសារ ដែលជាជនជាតិ ពាក់ព័ន្ធនឹងជនជាតិវៀតណាមហ្នឹង ក្រោយឆ្នាំ១៩៧៩ តើពួកគាត់

លោកស្រីដែល ក្នុងហ្នឹងគាត់មានអ្នកណាដែលនៅរស់ដូចលោកស្រី ដែលមានកូននៅរស់ ឬក៏ចៅនៅរស់ដូចលោកស្រីដែរទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។

**លោកស្រី ខូង មួយ៖**

**ឆ៖** ចាស នាងខ្ញុំអីមិនដឹង បើ៧៩មក មាននេះ ខ្ញុំទៅស្រុកឃ្លួនលេងជាមួយបងប្អូនម្ដាយខ្ញុំដែរហ្នឹង មានអ្នកណានៅរស់ បើស្លាប់អស់ហើយហ្នឹង។ អ៊ំខ្ញុំនៅថា "អ្អែងមិនមកស្រុកវៀតណាមវិញ អ្អែងនៅនោះប្រយ័ត្នអាពតម្ដងទៀត ងាប់អស់" គាត់ថាអ៊ីចឹងទៀត ហើយមាននៅរស់អី ងាប់ទាំងអស់ហ្នឹងថាយកទៅងាប់ហើយគ្មានរស់ទេ រស់មិនឃើញ គ្រួសារជីដូនមួយខ្ញុំ បងខ្ញុំ ក្មួយខ្ញុំតូចៗសោះ វៃចោលទាំងអស់។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** មុននេះ លោកស្រីបានលើកឡើងថា លោកស្រី ពេលដែលលោកស្រីយំ ថាប្អូនស្លាប់ហ្នឹងគេក៏បានប្រាប់ថាកុំឲ្យយំ ហើយនៅក្នុងអង្គប្រជុំ គេបានប្រាប់លោកស្រីថាលោកស្រីត្រូវតែខំនិយាយឲ្យទៅជាសំនៀងដូច សំឡេងដូចជាភាសាខ្មែរ។ អ៊ីចឹងតើអ្នកណាដែលប្រាប់លោកស្រីថាឲ្យលោកស្រីខំពុតសំឡេងឲ្យមកជាភាសាខ្មែរនេះ?

[១៥:០៥:០០]

**ឆ៖** ចាស នាងខ្ញុំនៅកងចល័តជាមួយគ្នាហ្នឹង ធ្វើការជាមួយគ្នាហ្នឹង គេអាណិតខ្ញុំ គេប្រាប់ថាមួយអើយកុំយំទៀត កុំនេះ ខំនិយាយ ខំធ្វើការ ខំនិយាយខ្មែរ ខ្មែរៗឲ្យច្បាស់ទៅ ខំធ្វើការងារទៅ។ អ្អែងមើលឃើញកូនយាយយួនហ្នឹង កូនគេធ្វើដល់កងរយ មេឪវៃចោល គេយកកូនទៅវៃចោលទៀត។ ហើយគេប្រាប់ខ្ញុំ ខ្ញុំក៏ខ្លាចភ័យ ឈប់ហ៊ានយំ។ នៅតែលួចយំអ៊ីចឹងយប់ៗ។

**ស៖** តើអ្នកដែលប្រាប់លោកស្រីថា ឲ្យនិយាយឲ្យដូចសំឡេងខ្មែរហ្នឹង គាត់មានជាអ្នកដឹកនាំក្នុងកងចល័ត ឬមួយក៏ជាសមាជិកកងចល័តធម្មតា?

**ឆ៖** ចាស អ្នកដែលធ្វើការជាមួយខ្ញុំធម្មតា។

**ស៖** ទាក់ទងនឹងមុននេះ ដែលលោកស្រីថា ប្ដីលោកស្រី លោកស្រីរងទុក្ខ ប្ដីលោកស្រីក៏ស្លាប់ដែរ ដើម្បីចៀសវាងការភ័ន្តច្រឡំ ខ្ញុំចង់បញ្ជាក់លោកស្រីថា តើប្ដីលោកស្រីស្លាប់នោះ ស្លាប់នៅក្នុងរបប

កម្ពុជាប្រជាធិបតេយ្យ ឬក៏ស្លាប់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ចាស ប្ដីនាងខ្ញុំស្លាប់តាំង៥៦ គាត់ឆ្នាំរោង ដល់ឥឡូវចូល១០ឆ្នាំហើយ ខ្ញុំចេះតែនឹកឃើញប្ដីស្លាប់ហើយ កំព្រាម៉ែកំព្រាឪ កំសត់ខ្ញុំចេះតែនេះទៅ ទើបនឹងស្លាប់កាលឆ្នាំ៥៦ហ្នឹង គាត់អាយុ៥៦ចូល១០ឆ្នាំហើយ។ តែខ្ញុំនឹកឃើញកំសត់ឡើង កាលនឹកឃើញគាត់ស្លាប់ហើយ កំព្រាម៉ែកំព្រាឪ ហើយគាត់ស្លាប់ទៀត ចោលខ្ញុំទៀត។ ខ្ញុំចេះតែនឹកឃើញ ខ្ញុំចេះតែយំ។

**ស៖** តើប្ដីលោកស្រីគាត់ជាជនជាតិខ្មែរ ឬក៏គាត់ជាជនជាតិវៀតណាមដែរ?

**ឆ៖** ចាស ប្ដីនាងខ្ញុំគាត់ចិនដែរ។

**ស៖** គាត់មានកាត់វៀតណាមដែរទេ?

**ឆ៖** អត់ទេ។

**ស៖** មួយទៀត ចូលប្រធានបទថ្មី គឺទាក់ទងនឹងកងចល័តរបស់លោកស្រី។ តើកងចល័តរបស់លោកស្រី តាមលោកស្រីអះអាងអំមិញមានខ្មែរ មានវៀតណាម មានតែលោកស្រី ហើយនិងមានបងជីដូនមួយម្នាក់ ហើយរបប -- ការបែងចែករបបហូបចុក ក៏ដូចជាលក្ខខណ្ឌការងារហ្នឹងរវាងសមាជិកកងចល័តនៅក្នុងកងចល័តលោកស្រីហ្នឹង ខ្មែរ ហើយនិងវៀតណាម គេប្រព្រឹត្តដូចគ្នាដែរ ឬមួយគេបែងចែកដូចគ្នាដែរ ឬមួយក៏ខុសគ្នាយ៉ាងម៉េច?

[១៥:០៩:៣៣]

**ឆ៖** ចាស នាងខ្ញុំដឹងតែខុសតែមេៗកងទេ គេហូបបាយឆ្អែតៗ ជនជាតិចិនខ្មែរអីមិនដឹងទេ ទាល់តែអ្នកធ្វើការដូចខ្ញុំអីចឹង មកពីធ្វើការមក បាយជួនណាឡើងរលួយៗហ្នឹង បើបបរតែមួយវែក ហើយជាមួយអំបិលហ្នឹង អំបិលជួនណាយកលាក់ក្នុងខោអាវទៀត។

**ស៖** ចុះសមាជិកកងចល័តដែលមិនមែនជាមេកងហ្នឹង គឺគាត់ទទួលបានរបបអាហារក៏ដូចជាលក្ខខណ្ឌការងារដូចតែលោកស្រីដែរ ឬមួយយ៉ាងម៉េច?

**ឆ៖** ចាស មេកងគាត់មកជូនទៅធ្វើការ មេកងម្នាក់ៗអីចឹង ដល់មកវិញគេហូបបាយ នៅមេៗគេជុំគ្នា គេមិនហូបជាមួយកងចល័តណា គេហូបឆ្អែតទៅ ហើយយើងហូបអីហូបទៅ បបរមួយវែកៗចេះតែហូបទៅជាមួយអំបិល។ អំបិលគ្រួសហៅពងត្រី។

**ស៖** ខ្ញុំចង់បញ្ជាក់លោកស្រី ខ្ញុំអត់និយាយពីមេកងទេ ខ្ញុំនិយាយពីសមាជិកកង ក្រៅពីលោកស្រីសមាជិកកងផ្សេងៗដែលគាត់ធ្វើការជាមួយលោកស្រីហ្នឹង គាត់ទទួលបានរបបអាហារដូចលោកស្រី

ដែរឬមួយយ៉ាងម៉េច?

**ឆ៖** ចាស អ្នកធ្វើការជាមួយហ្នឹង សមាជិកក្នុងក្រុមជាមួយហ្នឹង ហូបដូចតែគ្នាហ្នឹង បបរៗ ទាំងអស់គ្នាទៅ បាយជ្រាយទាំងអស់គ្នាទៅ មួយវែកៗអ៊ីចឹង។

**ស៖** ទាក់ទងនឹង តាមចម្លើយរបស់លោកស្រី ថាមានគេស្នើលោកស្រីឲ្យរៀបការ ប៉ុន្តែលោកស្រីបានប្រកែក។ បន្ទាប់ពីលោកស្រីប្រកែកទៅតើអ្នកស្នើលោកស្រីហ្នឹង គាត់មានថាអីដែរទេ? ហើយអ្នកណាជាអ្នកស្នើឲ្យលោកស្រីរៀបការ?

**ឆ៖** ចាស មេកងខ្ញុំ ស្នើឲ្យខ្ញុំយកការ ហើយដល់ពេលខ្ញុំ ខ្ញុំថាខ្ញុំអត់ដឹងអីផង ខ្ញុំអត់យកទេ ហើយក៏គេសួរក្នុងកងខ្ញុំធ្វើការជាមួយគ្នាហ្នឹង ខ្លះគេស្ម័គ្រចិត្ត ខ្លះគេអត់ស្ម័គ្រទាល់តែបង្ខំ។ រៀបការហើយ អត់ត្រូវគ្នាគេយកទៅវៃចោលបួនប្រាំគូ។

[១៥:១២:៣៩]

**ស៖** ចំពោះលោកស្រី ដែលលោកស្រីពេលគេស្នើលោកស្រី លោកស្រីបានប្រកែក។ អ៊ីចឹងតើគេមាន ធ្វើអីដាក់លោកស្រីដែរទេ? ឬមួយក៏គេប្រកែកហើយវាចប់ត្រឹមប៉ុណ្ណឹង?

**ឆ៖** ចាស ដល់រួចហ្នឹង ខ្ញុំមេកងរយហៅខ្ញុំទៅពិន័យទៅ។ ហៅខ្ញុំបួនប្រាំនាក់ទៅពិន័យធ្វើបង្គីច្រូតស្រូវក្នុងនុំងទៅ។ ខ្ញុំភ័យខ្លាចដែរ ដល់បានទៅហ្នឹងខ្ញុំអត់ -- គេរកអត់ឃើញអត់អី ខ្ញុំចេះតែ គេផ្លាស់ខ្ញុំទៅហ្នឹង ទៅតានៃវិញទៅ។

**ស៖** អ៊ីចឹងលោកស្រីថា មានបួនប្រាំនាក់ត្រូវពិន័យហ្នឹង តើករណីទាំងបួនប្រាំនាក់ហ្នឹង សុទ្ធតែអ្នកដែលប្រកែកមិនព្រមរៀបការហ្នឹង ឬមួយក៏មានករណីផ្សេងៗគ្នា?

**ប្រធានអង្គជំនុំ៖**

ទាន់ កុំអាល់ទាន់!

**លោកស្រី ខូង មួយ៖**

**ឆ៖** ខ្លះគេយក ខ្ញុំឃើញគេយកថ្ងៃហ្នឹងប្រាំគូ -- បួនប្រាំគូហ្នឹង មកកន្លែងវត្តព្រៃទប់ ជាប់កងខ្ញុំនៅដែរ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បន្ទាប់ពីគេពិន័យឲ្យក្រុមលោកស្រីបួនប្រាំនាក់ហ្នឹងធ្វើបង្គីធ្វើអីហ្នឹង បន្ទាប់ពីហ្នឹងហើយ មានហេតុការណ៍អីកើតឡើងទៀតដែរឬទេ?

**ឆ៖** នាងខ្ញុំអត់ដឹងដែរ ខ្ញុំទៅផ្លាស់ទៅតានៃហើយ អត់ដឹង មានដល់ពេល ថ្ងៃខ្ញុំមិនទាន់ទៅឮគេថា យកទៅវៃចោល ខ្លះអត់ត្រូវគ្នា។

**ស៖** ខ្ញុំចង់បញ្ជាក់ករណីលោកស្រីផ្ទាល់។ លោកស្រីថា បន្ទាប់ពីលោកស្រីប្រកែកអត់រៀបការ មេក្រុមបានពិន័យលោកស្រីឱ្យទៅធ្វើបង្គី ធ្វើអី។ អ៊ីចឹងបន្ទាប់ពីហ្នឹងមក តើលោកស្រីត្រូវមកធ្វើការកងចល័តធម្មតាវិញ ឬមួយក៏យ៉ាងម៉េច?

[១៥:១៥:០០]

**ឆ៖** ចាស ពាក្យមិញហ្នឹង ខ្ញុំអត់ថាពិន័យទេ គ្រាន់ថាមេកងខ្ញុំឱ្យទៅធ្វើបង្គីនៅតានៃ ប្អូនប្រាំនាក់គេដកទៅ ផ្លាស់ទៅប្អូនប្រាំនាក់ ធ្វើបង្គីរែកដី។

**ស៖** អ៊ីចឹងសុំទោស ដោយខ្ញុំស្តាប់ច្រឡំ។ អ៊ីចឹងមានន័យថា គេមិនមែនពិន័យលោកស្រីទេ គឺគេផ្លាស់ការងារលោកស្រីទៅធ្វើការនៅភូមិ ឬទីតំបន់មួយឈ្មោះ តានៃ អ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** ខ្ញុំចង់បញ្ជាក់លោកស្រីចុងក្រោយមួយទាក់ទងនឹង អំមិញលោកស្រីថា លោកស្រីអត់មានអ៊ំទេ ប៉ុន្តែនៅលើកំណត់ហេតុយកចម្លើយរបស់លោកស្រី ដែលឯកសារលេខ E3/5544 ត្រង់ ERN ជាភាសាខ្មែរលេខ 00375533, ជាភាសាបារាំងមានលេខ 00424097, ជាភាសាអង់គ្លេសមានលេខ 00377836។ នៅក្នុងសំណួរចម្លើយហ្នឹង លោកស្រីបានឆ្លើយថា៖ "ចាស ខ្ញុំរស់នៅ និងធ្វើការនៅក្នុងកងចល័តនៅព្រៃនប់រហូតដល់ពួកវៀតណាមចូលមក។ ពេលនោះប្រធានកងបានបង្ខំឱ្យយើងរត់ឡើងភ្នំ ប៉ុន្តែខ្ញុំមិនបានទៅជាមួយនឹងពួកគេទេ។ ផ្ទុយទៅវិញ ខ្ញុំបានព្យាយាមរត់ត្រឡប់មកស្រែចាម ដើម្បីជួបជាមួយនឹងអ៊ំស្រីរបស់ខ្ញុំវិញ។" តើអ៊ំស្រីរបស់លោកស្រីហ្នឹង គាត់ឈ្មោះអីដែរ? ហើយគាត់ត្រូវជាយ៉ាងម៉េចហើយនឹងលោកស្រី?

**ឆ៖** អ៊ំស្រីហ្នឹងគាត់ធ្លាប់នៅជាមួយម្តាយខ្ញុំពីមុនមក នៅស្រែចាម។ ហើយគាត់ក៏នៅណាមិនដឹង ក៏វៀតណាមរំដោះហ្នឹង ៧៩ ហ្នឹង ក៏គាត់ទៅភូមិហ្នឹង ស្រែចាមវិញ។ ខ្ញុំក៏ជួបគាត់ទៅ។

[១៥:១៧:៤១]

**ស៖** គាត់មានជាប់សាច់ញាតិអ្វីជាមួយលោកស្រីដែរក៏អត់ទេ?

**ឆ៖** ចាស គាត់ធ្លាប់នៅ ពីនោះគាត់នៅជាមួយភូមិ ជាមួយម៉ាកខ្ញុំ ប៉ាខ្ញុំដែរ។ ដល់ពេលគាត់ អាពត មិនដឹងគាត់នៅភូមិណា គាត់។ ដល់ ៧៩ គាត់ទៅនឹង ឃើញគាត់ ខ្ញុំរត់ទៅភ្នំហើយ។ ខ្ញុំទៅភូមិវិញ

ថាម្ដាយខ្ញុំស្លាប់នៅហ្នឹង។ ខ្ញុំក៏ទៅជួបគាត់នៅហ្នឹងទៅ។ គាត់ស្គាល់គ្នាជាមួយម្ដាយខ្ញុំ ធ្លាប់នៅ រស់នៅភូមិជាមួយគ្នា។

**សៈ** តើគាត់ជាជនជាតិវៀតណាម ដែរឬក៏មិនមែន?

**ឆៈ** ចាស គាត់ចិន។

**លោក លីវ សុវណ្ណាៈ**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះជូនទៅមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុនៈ**

បាទ សូមអរគុណលោកប្រធាន យើងខ្ញុំអត់មានសំណួរទេ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំៈ**

បាទ ជាចុងក្រោយនេះ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើមានអ្វីចង់ថ្លែងរៀបរាប់នូវសេចក្ដីទុក្ខសោកវេទនា ឬក៏ព្យសនកម្មជាចុងក្រោយ ហើយនិងមានសំណួរអីចង់សួរទៅជនជាប់ចោទដែរឬទេ? បើសិនជាមានបំណងធ្វើដូច្នេះ សូមអញ្ជើញ!

**លោកស្រី ខូង មួយៈ**

ចាស នាងខ្ញុំសុំសួរសំណួរមួយជនជាប់ចោទ។ កូនមាន់ខ្ញុំខំថែរក្សា ឲ្យថ្នាំ ឈឺឲ្យថ្នាំឲ្យអីផឹក ពេលងាប់ទៅខ្ញុំនៅស្ដាយ ទម្រាំជីវិតម្ដាយខ្ញុំប៉ាខ្ញុំមួយ ខ្ញុំតូចៗ បងស្រីខ្ញុំ យកទៅវ៉ៃចោលអ៊ីចឹង ជួយស្រាយ ដោះស្រាយឲ្យខ្ញុំតិចមើល៍យ៉ាងម៉េច? ខ្ញុំឈឺចាប់ណាស់រាល់ថ្ងៃ ខែបុណ្យ ខែទាន សែនថ្ងៃណាក៏ខ្ញុំយំដែរ។ សែននៅដីផង សែនក្នុងផ្ទះផង ពីរបីចំណែក ហេតុតែក្មួយ បង អត់មានជើងធូប ចិនខ្ញុំត្រូវសែនអ៊ីចឹងម្ដងៗខ្ញុំយំ ខ្ញុំសូមសំណូមពរតែប៉ុណ្ណឹងទេ ចប់ហើយ។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណលោកស្រី ខូវ មួយ។ អង្គជំនុំជម្រះ សូមជម្រាបជូនលោកស្រីថា តាមបទប្បញ្ញត្តិនៃវិធាន២១ អនុប្រធានមួយចំណុច(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា នៅគ្រប់ដំណាក់ទាំងអស់នៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវប្រាប់អំពីសិទ្ធិនៅស្ងៀម មិនឆ្លើយតបទៅនឹងសំណួរដល់ជនជាប់ចោទ។ ហើយនៅក្នុងសវនាការកាលពីថ្ងៃ០៨ ខែមករា ឆ្នាំ២០១៥

បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីរនាក់ ឆ្លើយបញ្ជាក់ពីការដែលពួកគាត់សុំរក្សាសិទ្ធិមិនឆ្លើយតបទៅនឹងសំណួរ។ នាពេលសវនាការនោះ អង្គជំនុំជម្រះក៏បានធ្វើការកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែនិងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូង បានទទួលព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬក៏ពីសហមេធាវីការពារក្តីជនជាប់ចោទ។

[១៥:២១:៣៥]

នៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកត់សម្គាល់ -- បានកំណត់ឲ្យជនជាប់ចោទ និង/ឬសហមេធាវីការពារក្តីជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវ ក្នុងការជូនដំណឹងមកអង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទ បានសម្រេចចិត្តលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរដែលអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធដទៃទៀត នៅដំណាក់ណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។

រហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀម មិនឆ្លើយតប មកជាយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។ ហើយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទាំងច្បាប់ជាតិ ទាំងច្បាប់ព្រហ្ម-ទណ្ឌអន្តរជាតិ គឺមិនអាចបង្ខំឲ្យជនជាប់ចោទ ឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីបានឡើយ។ សូមលោកស្រីជ្រាប។

[១៥:២២:៤០]

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ខូង មួយ សវនាការស្តាប់សក្ខីកម្ម និងសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានិងស្ថានភាពព្យសនកម្ម ក្នុងឋានៈជា លោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីដែលលោកស្រីអះអាងថា បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ឥឡូវនេះដល់ -- បានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកស្រី នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្តីនេះ។ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយអង្គជំនុំជម្រះ ក៏សូមអរគុណលោកស្រី ឆាយ ម៉ារីដែត បុគ្គលិកអង្គការ ធី.ភី.អូ ប៉ុន្តែ

ដោយសារលោកស្រីត្រូវបន្តអង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត ដែលអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការបន្តិចទៀតនេះ ដូច្នេះលោកស្រីនៅអង្គុយទីកន្លែងនោះដដែលចុះ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកស្រី ខូង មួយ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងសូមឲ្យអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1014 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ ជាបន្ត។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:២៥:១៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** បាទ ខ្ញុំបាទ ឈ្មោះ អ៊ុច ស៊ុនឡាយ។

**ស៖** អរគុណលោក អ៊ុច ស៊ុនឡាយ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

**ឆ៖** បាទ ខ្ញុំបាទ កើតនៅថ្ងៃចន្ទ ទី០២ ខែតុលា ឆ្នាំ១៩៤៨។

**ស៖** ទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ ទីលំនៅបច្ចុប្បន្ន គឺនៅភូមិវត្ត ឃុំក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។

**ស៖** អរគុណ តើលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បាទ បច្ចុប្បន្នខ្ញុំជាមន្ត្រីចូលនិវត្តន៍។

**ស៖** ប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សា គឹមនី។ មានកូនបីនាក់ ត្រូវពួកប៉ុល ពតសម្លាប់អស់ហើយ។

[១៥:២៦:៤៦]

**ប្រធានអង្គជំនុំ៖**

លោក អ៊ុច ស៊ុនឡាយ ក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែល

ត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ មេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ដែលនាំឲ្យលោកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារជាសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្ម ដែលមានចំពោះលោកជាអាទិ៍ គឺការខូចខាតខាងផ្លូវកាយ សម្ភារៈ ឬក៏ផ្លូវចិត្ត ហើយជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ហើយបានកើតឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ។

ហើយដោយសារតាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំតាំងសំណួរចំពោះស្ថានភាពព្យសនកម្ម និងទុក្ខសោកវេទនារបស់លោកនោះ គឺអង្គជំនុំជម្រះផ្តល់វេទិការជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឡើងតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ បាទ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមប្រគល់វេទិកាទៅឲ្យសហសេវិករបស់ខ្ញុំដើម្បីធ្វើការងារនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញបាទ លោក វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

បាទ សូមៗគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

[១៥:២៨:៣៧]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរ ពូស៊ុនឡាយ ខ្ញុំបានទទួលដំណឹងថាពូមានបញ្ហាសុខភាព តែខ្ញុំសុំអនុញ្ញាតឲ្យពូធ្វើការសម្រួលនឹងការឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំមួយចំនួន ដែលពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងចំពោះគ្រួសារពូផ្ទាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ សំណួររបស់ខ្ញុំដំបូងដែលសួរពូៗបានបញ្ជាក់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពូហើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលនោះ ពូបានបាត់បង់នូវសមាជិកគ្រួសារ សាច់ញាតិជាទីស្រឡាញ់របស់ពូសរុបទាំង

អស់ចំនួន១៤នាក់ ក្នុងនោះមានឪពុកបង្កើតរបស់ពូ មានប្រពន្ធរបស់ពូ រួមទាំងកូនរបស់ពូចំនួនបីនាក់ និងសមាជិកគ្រួសារខាងប្រពន្ធពូសរុបទាំងអស់ ១៣នាក់ គឺសុទ្ធតែជាកូនកាត់វៀតណាម។ ខ្ញុំសូមឲ្យពូធ្វើការបញ្ជាក់រៀបរាប់ជូនអង្គសវនាការ អំពីការឈឺចាប់ ដែលប៉ះពាល់ ក៏ដូចជាការរងទុក្ខវេទនារបស់ពូផ្ទាល់ ដែលពាក់ព័ន្ធទៅនឹងការបាត់បង់សាច់ញាតិជាទីស្រឡាញ់របស់ពូ គឺប្រពន្ធពូ និងកូនតូចៗរបស់ពូចំនួនបីនាក់ រួមទាំងសមាជិកគ្រួសារខាងប្រពន្ធពូ ដែលពូអះអាងថាសុទ្ធតែជាកូនកាត់វៀតណាមនោះជូនអង្គសវនាការបាទ។

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** ខ្ញុំបាទសូមគោរពលោកប្រធាននៃអង្គជំនុំជម្រះ អស់លោក លោកស្រី ជាចៅក្រមទាំងអស់ ក៏ដូចជាលោក លោកស្រីជាមេធាវីផងដែរ។ ខ្ញុំបាទ បានបាត់បង់ជីវិតមនុស្សនៅក្នុងក្រុមគ្រួសារខ្ញុំបាទហ្នឹងសរុប១៣នាក់ហ្នឹង គឺពិតប្រាកដមែន។ ក្នុងនោះ មានឪពុកក្មេកខ្ញុំឈ្មោះ ចាយ គីមអេង ហៅ អ៊ី ជាស្មៀនឃុំក្រចេះ ហើយម្ដាយក្មេកខ្ញុំឈ្មោះ ធី បេ ជាកូនកាត់វៀតណាម។ រីឯប្រពន្ធខ្ញុំបាទឈ្មោះ សា គីមនី មិនដែលចេះនិយាយភាសាវៀតណាមទេ រៀនតែកម្ពុជារហូតដល់ថ្នាក់អនុវិទ្យាល័យខេត ប៊ុនស៊ុន ហើយប្អូនរបស់ សា គីមនី ឈ្មោះ សា គីមណា។ កូនប្អូនមួយទៀត គឺចាន់ សម្បត្តិ, ចាន់ វិសាល, ចាន់ស្រីពៅ ហើយដោយឡែកប្ដីរបស់ សា គីមណា ឈ្មោះ ជិន សាអ៊ីម។ កូនរបស់ ជិន សាអ៊ីម ហ្នឹងឈ្មោះសារៈ សារីន។ សរុបបូកនឹងកូនខ្ញុំបាទ សុធារៈ សុធារ៉ា សុធីតា ថែមទៀត គឺ១៣នាក់។ នៅក្នុងអំឡុងដែលពួក ប៉ុល ពត ចូលកាន់កាប់ ព្រោះខេត្តក្រចេះកាលហ្នឹងរំដោះមុនគេ ការដែលចាត់ចែងសហករណ៍ និងការរៀបចំក្រុមហ្នឹងក៏បានមុនគេដែរ។ ដូច្នេះ ខ្ញុំបាទនៅតែជាប្រជាជនប្រភេទទី២ ប៉ុណ្ណោះដែលគេដាក់ទិសចេញពីឃុំគគរ ឲ្យទៅនៅភូមិទួលមនោរម្យ ក្នុងសហករណ៍ក-២ ក្នុងឆ្នាំ១៩៧៣។ ដូច្នេះអតីតភាពជាគ្រូបង្រៀនរបស់ខ្ញុំបាទ គឺបានបញ្ចប់ហើយ គឺក្លាយទៅជាកសិករ ធ្វើការងារពលកម្មគ្រប់បែបយ៉ាងក្នុងនាមជាកងផលិត។

[១៥:៣២:០១]

ទន្ទឹមនឹងការដែលបាត់បង់ក្រុមគ្រួសារប្រពន្ធកូននោះ ឪពុកខ្ញុំបាទដែលជាអាចារ្យវត្ត ឈ្មោះលោកតា អ៊ុច ស៊ុនលី ហៅ តាំង ឆាយ ក៏ត្រូវបាត់បង់ដោយគ្រាន់តែគាត់រកដើមព្រិចងាប់ៗហ្នឹងយកមកដុតដើម្បីធ្វើធូកគាត់នមាស្ការព្រះរតនត្រ័យ ហើយពួកកងឈ្លបដែលបានមើលឃើញ វាថាស្អីព្រះរតនត្រ័យអី ទៅៗព្រះពុទ្ធជាទីពឹងទីរឭកអី។ គឺចាប់ចងអូសយកទៅ ក្នុងនោះការដែលចាប់ចងអូសមាន

ឈ្មោះ សមមិត្តយាន ជាអ្នកមកប្រាប់ថា ឪពូឡាយឯងនោះ ជឿងាប់ហើយលើព្រះពុទ្ធសាសនានោះ។ អាហ្នឹងឲ្យវាទៅកន្លែងព្រះពុទ្ធជាទីពឹងទីរឭកចុះ បាទ។ ខ្ញុំបាទ ក្តៅឈ្លួលអួលណែនក្នុងឱរ៉ាវឿងឪពុកជាទីគោរព ដោយគ្រាន់តែដុតធូករំឭកគុណព្រះរតនត្រ័យក៏ត្រូវពួក ប៉ុល ពត ហ្នឹងចាប់យកចងយកទៅប្រល័យដែរ។

[១៥:៣៣:១៣]

ដោយឡែកប្រពន្ធខ្ញុំបាទ ឈ្មោះ សា គឹមនី និង សា គឹមណា និងកូនតូចៗទាំងបី គឺវាជម្លៀសពី ក-៥ មកដាក់នៅកណ្តាលកោះ គឺកោះទ្រុងមុខវត្តក្រចេះបច្ចុប្បន្នហ្នឹងបាទ ហើយវ៉ៃសម្លាប់នៅក្នុងរណ្តៅមួយក្រោមដើមក្តុល តែក្រោយមកទឹកទន្លេមេគង្គបានជន់ជោរហូរហៀរ ដើមក្តុលនុ៎ងក៏បានបាក់ធ្លាក់ក្នុងទឹកពុំមានសេសសល់នៅ ហៅថា ឆ្អឹងសាកសពនៃឧក្រិដ្ឋកម្មហ្នឹងឡើយ។ តែអ្នកស្រុកបានប្រាប់ថា អាណោចអាធមណាស់ កូនគ្រូឡាយឯងនេះ វារត់ពេញទក់ស្មៅទាំងអស់ហ្នឹង ដោយពីព្រោះពួកវាដេញចាប់ ដើម្បីនឹងចាប់បោកផ្ទប់នឹងគល់ក្តុលហ្នឹង។ ខ្ញុំបាទ ដឹងដំណឹងនេះតាមតែអ្នកស្រុកគេប្រាប់ដោយឈ្មោះលោក ធុល ជាអ្នកបររទេះដឹកពីកណ្តាលកោះទៅដាក់ក្បាលកោះហ្នឹង ដោយបញ្ឆោតថាពួកប្តីហ្នឹងមកពីកាប់ឫស្សី បង្គោងឆ្នោតរួចហើយ។ ពីព្រោះក្នុងឱកាសដែលទឹកជំនាន់ទន្លេមេគង្គឡើងធំនៅឆ្នាំនោះ ឈ្មោះ មឿន និងគណៈសហករណ៍ហ្នឹងបានចាត់តាំងពួកក្រុមដែលជាមានប្រពន្ធជាកូនកាត់វៀតណាម ចៅកាត់វៀតណាមនោះ ឲ្យទៅកាប់ឫស្សីបង្គោងឆ្នោត នៅឯអូរឲ្យង ដែលមានរយៈពេលធ្វើដំណើរហ្នឹងមិនតិចពីពីរយប់ទេ តាមរយៈការចែវទូក។ ខ្ញុំបាទក៏ទៅជាមួយនឹងគេហ្នឹង ក៏ប៉ុន្តែដែលក្តុកក្តួលខ្លាំងមែនទែននោះ គឺពេលដែលត្រឡប់មកវិញ គណៈសហករណ៍បានហៅ អ្នកទាំងនោះរួមទាំងខ្ញុំបាទផង ដើម្បីមកទទួលការអប់រំសតិអារម្មណ៍។

ពេលនោះដែលឈ្មោះ មឿន គណៈសហករណ៍ បានក្រោកឡើងនិយាយថា៖ "សមមិត្តមានគុណសម្បត្តិខ្ពស់ណាស់ជាមួយនឹងបក្សវណ្ណៈកម្មករយើង សមមិត្តបានខិតខំបំពេញការងារកម្ចាត់ធាតុដើម លះបង់ខ្ពស់ជូនបក្សវណ្ណៈកម្មករ កសិករ តែប្រពន្ធកូនរបស់មិត្ត យើងខ្ញុំបានប្រមូលទៅទុកម្ដុំហើយ សូមសមមិត្តកាត់សាច់ស្អុយនេះចេញចុះ! (ខ្ញុំបាទធ្លាប់តែឮថាបោសសម្អាត ធ្លាប់តែឮតែកម្ទេចម្តងនេះគឺថាឲ្យកាត់សាច់ស្អុយហ្នឹងចេញកុំឲ្យនៅអាលោះអាល័យ) សមមិត្តត្រូវលះបង់ខ្ពស់ ហើយនិយាយថាបក្សរបស់ខ្ញុំ។ ក្រោកឈរឡើង! (ឲ្យពួកខ្ញុំក្រោកឈរឡើង) យើងខ្ញុំទាំងអស់គ្នា – យើងខ្ញុំទាំងអស់គ្នា, សូមប្តេជ្ញាចិត្ត – សូមប្តេជ្ញាចិត្ត, លះបង់កាត់សាច់ស្អុយនេះចោល – លះបង់កាត់សាច់

ស្អុយនេះចោល, ដើម្បីកសាង – ដើម្បីកសាងវណ្ណៈកម្មកររបស់បក្សកុម្មុយនីស្តកម្ពុជា – វណ្ណៈកម្មកររបស់បក្សកុម្មុយនីស្តកម្ពុជា ។ល។” គឺថាតែថាទេ រីឯចិត្តនៅក្តុកក្តួលយ៉ាងខ្លាំងមិនអាចលះបាន។ ព្រោះអ្វី? ពីព្រោះកូនប្រពន្ធជាទីស្រលាញ់ដែលមានអនុស្សាវរីយ៍ល្អជាមួយគ្នារាប់ឆ្នាំមកដល់ពេលនេះ តែមួយប៉ព្រិចភ្នែកពួកឃាតករយកទៅសម្លាប់។ ទុក្ខសោកនាដកម្មទាំងអស់នេះ មិនអាចឲ្យខ្ញុំបំភ្លេចបាន។ ទោះបី៣០ឆ្នាំ ៤០ឆ្នាំនេះកន្លងទៅពិតមែន ទឹកភ្នែកបានហូររាប់ខែរាប់ឆ្នាំទៅហើយ តែពេលនេះក៏នៅតែនឹកមិនអាចបំភ្លេចបានសោះឡើយ។

[១៥:៣៧:៣២]

ខ្ញុំបាទ ដូចជាក្តុកក្តួលរំខានចិត្តខ្លាំង សូមមេត្តាអង្គជំនុំជម្រះមេត្តាអភ័យទោស និងសវនាការទាំងមូលមេត្តាយោគយល់ ព្រោះជារឿងផ្ទាល់របស់ខ្ញុំបាទទៅហើយ។ មិនតែប៉ុណ្ណោះ ក្តុកក្តួលជាងហ្នឹងថែមទៀត នោះគឺវាយកសម្លៀកបំពាក់ដែលអ្នកសម្លាប់ទាំងអស់ហ្នឹង មកចែកនៅក្នុងសហករណ៍ទៀតប្រាប់ថា គឺជាជយភណ្ឌ ហើយមីងឡំ មីងដទៃទៀតថា ទេឃើញសំពត់អាវស្បៃ ខោខ្លី ក្រមា អាវយឺតហ្នឹង គឺរបស់ប្រពន្ធកូន អ៊ុច ស៊ុនឡាយ ហ្នឹង របស់ សា គឹមនី។ អានេះកូន សា គឹមនី។ អានេះគឺគេធ្លាប់ឃើញ គេដឹងច្បាស់ថាពិតជាស្លាប់នៅក្បាលកោះទ្រុងហ្នឹងប្រាកដមែន។ ហើយយកថាជារបស់ជយ-ភណ្ឌ។ គួរឲ្យសង្វេគខ្លាំងណាស់ ខ្ញុំបាទហ្នឹងកាន់តែ ហៅថាបាយក៏មិនបាន ទឹកក៏មិនបាន។ ដើរឈ្ងោកមុខគ្រប់ទីកន្លែង ហើយគេចខ្លួនមិនចង់ឲ្យជួបនឹងអ្នកណាទេ ព្រោះបក្សហ្នឹងហាមថា ទោះបីលះបង់យ៉ាងម៉េចគឺមិនឲ្យយំ មិនឲ្យឱនមុខ មិនឲ្យហៅថា ឲ្យគេដឹងថាយើងមិនលះបង់នោះទេ។ បក្សវណ្ណៈអធន បក្សកុម្មុយនីស្តកម្ពុជាគឺខ្លាំងក្លាណាស់ គឺថាមានជោគជ័យធំសម្បើមណាស់។ ហ្នឹងគឺក្នុងឆ្នាំ១៩៧៧។

[១៥:៣៨:៥៦]

ក្រោយមកទៀត ពេលដែលយកប្រពន្ធទៅសម្លាប់ហើយ ឪពុកជាទីស្រលាញ់ដែលវាយកទៅសម្លាប់បាត់ខ្លួនហើយ មកធ្លាក់លើខ្ញុំ គឺគណៈសហករណ៍ហ្នឹងខ្សឹបប្រាប់ថា “ឡាយ ឯងប្រយ័ត្នបន្តិច គេមានឯកសារពីតំបន់៥០៥មក ដាក់ថាមានឈ្មោះ ង្វៀង យ៉ាំងឡាយ បង្កប់នៅសហករណ៍ក-៥នេះបាទ” “ខ្ញុំថាយី ម៉េចមានឈ្មោះខ្ញុំ ខ្ញុំឈ្មោះ អ៊ុច ស៊ុនឡាយតើ! ទេគេថាមានឈ្មោះ ង្វៀង យ៉ាំងឡាយ ច្បាស់តែម្តង រួចអត់មានឡាយ ណាដទៃទៀតទេ ជាខ្មែរ កា.ហ្សេ.បេ បង្កប់ក្នុងសហករណ៍ដើម្បីស៊ើបរូងផ្ទៃក្នុង” ខ្ញុំបាទ កាន់តែក្តុកក្តួល កាន់តែភ័យព្រួយ កាន់តែបារម្ភខ្លាំងឡើង ភ័យញ័ររន្ធត់ដូចកូនសត្វ។ ពេលយប់

ស្លាត់ចេះតែអង្គុយបែរបន់។ យប់ស្ងាត់សូម្បីតែពួកណ្ដុររត់កាត់ព្រួសប្រាសក៏ភ្ញាក់ខ្លួនដូចរន្ទត់ក្នុងបេះដូងស្លុតប្រមាត់ទាំងអស់ ពីព្រោះពួកកងឈ្លបវា មានឈ្មោះ អាឃឿង អាអីជាដើមហ្នឹងគឺដើរតាម ស្ដាប់តាមដាន ស៊ើបអង្កេតថា "មើលពួកអាអស់ហ្នឹង អ្នែងប៉ុនណា ពួកអាវណ្ណៈអសារមូលធន ពួកសក្តិភូមិវាធ្លាប់តែធ្វើគ្រូបង្រៀន វាជិះជាន់គេផង វាត្រូវគេជិះជាន់ផងពួកហ្នឹង ពួកបញ្ញវន្ត។" គឺគេតែងតែប្រជុំថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ គេលើកឡើងពីបញ្ហារើកម្ចាត់វណ្ណៈអ -- វណ្ណៈមូលធន សក្តិភូមិ និងពួកធ្លាប់ជិះជាន់គេហ្នឹងឲ្យអស់ ពីព្រោះកាលដែលនៅផ្ទះនៅគគរ ដែលស្រុកកំណើតខ្ញុំបាទ គេមិនឲ្យនៅទេ គេដេញជម្លៀស គេប្រើពាក្យមួយថា ជម្លៀស ឬដាក់ទិសៗ ឲ្យទៅនៅទួលមនោរម្យ។ ឪពុកខ្ញុំបាទ ក៏គេដាក់ទិសពីភូមិគគរ ឃុំគគរហ្នឹង ឲ្យទៅនៅចង្រ្កង់ ឃុំចង្ក្រង់ ស្រុកចិត្តបុរី បច្ចុប្បន្ននេះជាដើម។ល។ ទាំងអស់នេះហើយ ដែលខ្ញុំភាពក្តុកក្តួល និងទុក្ខសោករបស់ខ្លួនខ្ញុំបាទផ្ទាល់ហ្នឹង នៅតែដក់ជាប់ក្នុងនឹងរហូតដល់ថ្ងៃបានរំដោះ ០៧ មករា ៧៩ ហ្នឹងក៏ឃើញអស់គេទាំងឡាយ គេបានជួបជុំបងប្អូនម៉ែឪកូនប្រពន្ធ។

[១៥:៤១:១៣]

**ស៖** ពូៗ សូមទោស ខ្ញុំសូមកាត់ពូតិច។ សូមពូបញ្ជាក់ពីការឈឺចាប់មួយទៀតឲ្យហើយទៅ គឺពាក់ព័ន្ធនឹងឪពុកក្មេករបស់ពូ តើមានរឿងហេតុការណ៍កើតឡើងចំពោះគាត់ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំដែរទេ? បាទ ពូអាចបញ្ជាក់រឿងហ្នឹងបានទេ?

**ឆ៖** ក្រោយពេលដែលពួក ប៉ុល ពត បានយកម្ដាយក្មេកខ្ញុំបាទឈ្មោះ ធី បេ ហ្នឹងទៅសម្លាប់ គឺគណៈសហករណ៍ឈ្មោះ មឿន បានហៅលោកស្មៀន អ៊ី ដើម្បីរៀបអាពាហ៍ពិពាហ៍ ១១ខ នៅ -- ១១ គូ នៅអូរឫស្សី។ គេហៅថា ក-៥។ ពេលនោះគេប្រាប់ថា "ពូឡាយ ឯងធ្លាប់ធ្វើគ្រូ ដឹងរបៀបរបបរៀបចំឥឡូវទៅរៀបចំចងរូបញញួរកណ្ដៀវទង់បក្សនៅខាងលើ រូបទង់ជាតិនៅខាងក្រោម។ ហើយនៅចាំត្រង់ហ្នឹង រៀបតុ រៀបកៅអីទាំងអស់។" គេថា គេនឹងរៀបចំអាពាហ៍ពិពាហ៍ថ្មីតាមបែបផែនសង្គមនិយម។ ក្នុងនោះ ខ្ញុំមើលឃើញ ៗលោកស្មៀន អ៊ី ដែលជាអតីតឪពុកក្មេកខ្ញុំពីមុនចូលរួមនឹងដែរ។ គាត់ទទូរមុខជាប់ ហើយអត់និយាយស្ដីអីៗទាំងអស់។ ដែលក្រោយពីសម្លាប់ម៉ែក្មេកតែមិនបានប៉ុន្មានខែផង គឺអង្គការបានរៀបការមង្គលការ ១១គូ បង្ខំឪពុកក្មេកខ្ញុំយក មីឡេន ហ្នឹងទៀតបាទ។ ដូច្នេះឃើញថា ទុក្ខជាន់លើទុក្ខផ្ទួនគាត់ទាំងអស់ ទាំងឪពុកក្មេក ទាំងឪពុកបង្កើត មិនអាចនិយាយប្រាប់គ្នាបាន សូម្បីតែលើកដៃថាយ៉ាងណានោះ គ្រាន់បញ្ជាក់ថាចុកណែន ដួលអួលណែននៅដើមទ្រូង ប្រាប់កូន។ ខ្ញុំបាទក៏ឃើញ ខ្ញុំក៏

ក្តុកក្តួលស្រក់ទឹកភ្នែកដែរ "យីបានជាវណ្ណៈអធន អីគេនេះមករៀបចំមង្គលការអី ១១គូ អីយ៉ាងសម្បើមម្ល៉េះ!" បាទ ហើយគេឲ្យអ្នកទាំងអស់ហ្នឹងឡើងប្តេជ្ញាចិត្ត តាមមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ចំណុចទាំងអស់ហ្នឹងហើយ ដែលហៅថាធ្វើឲ្យខ្ញុំបាទនៅតែចងចាំ។ ពេលឃើញគេរៀបការនឹកឃើញដល់ឪពុកក្មេកខ្លួនឯង ចំណាស់ហ្នឹង វានៅបង្ខំឲ្យទៅរៀបការទៀត។ វាថា "បក្សបដិវត្តន៍មិនអាចធ្វើតែពាក់កណ្តាលផ្លូវបានទេ។ បាយអាចហូបកន្លះឆ្អែត តែការធ្វើបដិវត្តន៍ត្រូវធ្វើចប់ចុងចប់ដើម។ ដំណេកអាចដេកកណ្តាលយប់ក៏បានដែរ។" ទ្រឹស្តីរបស់គេហ្នឹងគឺច្រើន ពីព្រោះខ្ញុំយល់ថា គ្រូៗមួយជំនាន់ខ្ញុំចូលធ្វើបដិវត្តន៍ទាំងអស់ ហើយគេតែងទិតៀនមកខ្ញុំថា អាគ្រូឡាយឯងនេះ អ្អែងចង់នៅដល់ណា? អាពត មិនមែន អាពត ទេ។ គេថាៗ អាគកទោះបីឯងរងារ ឬមិនរងារ ក៏ថ្ងៃនៅតែរះ ផ្អិនផ្អារទិសបូព៌ាជានិច្ច។ គិតមែនទែន ចូលជួរជាមួយពួកយើងមក។ ប៉ុន្តែដល់ទីចុងបំផុត មកដល់ពេលនេះអស់លោកគ្រូ អ្នកគ្រូទាំងអស់ហ្នឹងស្លាប់បាត់បង់អស់ហើយ ដល់ពួកបូព៌ាទៅសម្លាប់ ថាពួកក្លៀសានហ្នឹងក្បត់។ បាទ ហើយក្រោយមក គេយកពួកនិរតីមកដាក់ថា ពួកបូព៌ាហ្នឹងក្បត់តទៅទៀត គឺសម្លាប់តគ្នាឯង ដល់ខ្ញុំបាទដឹងច្បាស់ ដោយសារមានមិត្តភក្តិជាគ្រូបង្រៀនជាច្រើនបាទ។

[១៥:៤៤:៥២]

**ស៖** បាទ សូមអរគុណ។ ពូ ខ្ញុំចង់ឲ្យពូបញ្ជាក់ផងដែរថា តើនៅក្នុងភូមិរបស់ពូ ឃុំរបស់ពូនោះនៅសម័យនោះ មុនពេលគេយកប្រពន្ធពូទៅសម្លាប់នោះ ថាតើគេមានប្រជុំដាក់ផែនការពាក់ព័ន្ធនឹងសម្លាប់ជនជាតិវៀតណាមអីទេ ពូបានដឹងជាមុនទេ បាទ?

**ឆ៖** បាទ បញ្ហាថាពាក់ព័ន្ធសម្លាប់ជនជាតិវៀតណាម គេអត់និយាយផ្លូវត្រង់អីទេ។ គេថាអង្គការឲ្យជួបជុំនៅវត្តគគរន៉ុង ឡានទៅរង់ចាំត្រង់ហ្នឹង គឺដឹកជញ្ជូនបងប្អូនដែលជាអណិកជនវៀតណាមបញ្ជូនទៅប្រទេសវៀតណាមដើមវិញ។ ក្នុងនោះ គឺមានច្រើនគ្នា មានឈ្មោះ ហ្គុង, ឈ្មោះ មីង គីមកា, ឈ្មោះ តាបា, ឈ្មោះ យាយហឿង ហើយនិង យាយបេ – យាយ ធី បេ ដែលជាម្តាយក្មេកខ្ញុំបាទនោះដែរ។ ខ្ញុំមិនបាន មិនជូនទេ ពីព្រោះគេអត់មានឲ្យជូនទេ គេឲ្យដឹងនាំខ្លួនទៅ។ អាន៉ុង ខ្ញុំបាទដឹងតែប៉ុណ្ណឹងថាៗឡើងឡានទៅ កាត់តាមភ្នំព្រិចតម្រង់ទៅវៀតណាម បាទ។ គេអត់មានផ្សាយថា អ្នកឯងហ្នឹងជាវៀតណាមមិនអាចនៅបានទេ អ្នកឯងមានប្តី មានប្រពន្ធ កូនប្រសាជាកម្ពុជាក៏ដោយ អត់មាននិយាយប្រាប់ទេ គឺយើងអត់បានដឹងរឿងហ្នឹងទេ បាទ។

**ស៖** បាទ សូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ ខ្ញុំចង់ឲ្យពូធ្វើការរៀបរាប់

បញ្ជាក់ពីអារម្មណ៍ផ្ទាល់ខ្លួនពូ ពាក់ព័ន្ធនឹងក្រោយជ័យជម្នះ នៅពេលខ្មែរក្រហមដួលរលំហ្នឹងទៅ ថាតើអារម្មណ៍ពូបែបណា នៅពេលដែលឃើញគេជួបជុំគ្រួសារ តើពូមានអារម្មណ៍បែបណា ពាក់ព័ន្ធនឹងការឈឺចាប់របស់ពូនេះបាទ?

[១៥:៤៦:៤២]

**ឆៈ** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងអារម្មណ៍របស់ខ្ញុំផ្ទាល់ ខ្ញុំបាទអស់ក្ដីសង្ឃឹមរលីងអស់។ ម៉េចបានអស់ក្ដីសង្ឃឹម? ពីព្រោះក្រុមគ្រួសារដែលជាបង្អែករបស់ខ្លួនស្លាប់បាត់បង់ជីវិត។ ឪពុក លោកអ្នកដែលមានគុណក៏ស្លាប់បាត់បង់ជីវិតដែរ។ ដឹងថាតែបាត់ខ្លួន គឺស្លាប់ហ្នឹងហ្មង។ ហើយឪពុកក្មេក ក៏អស់។ ដូច្នេះពេលខ្លះ ខ្ញុំនឹកថាអាត្មាអញគួរតែសម្លាប់ខ្លួនតាមទៅ ដើម្បីឱ្យវិញ្ញាណក្ខន្ធជាតិក្រោយ បានជួបគ្នា ឬយ៉ាងម៉េច ប៉ុន្តែនឹកឃើញដល់ពាក្យសុភាសិតបារាំងដែលបានធ្លាប់រៀនសូត្រ យល់ដឹងកន្លងមកថា ជីវិតគឺជាការតស៊ូ ជីវិតជាការតស៊ូ ត្រូវតែតស៊ូ ទោះបីខ្លួនឯងបាន មិនបាន កើតមិនកើត សម្រេចមិនសម្រេច ជោគជ័យ ឬមិនជោគជ័យក៏ដោយ ក៏នៅតែចេះតែទ្រាំអ៊ីចឹងទៅ ទ្រាំមើលជីវិតហ្នឹង បាទដើម្បីនឹងតស៊ូជាចុងក្រោយ។ ដែលពេលនោះហើយ ឮសូរផ្គរក្ដួងៗពីកើតមក បញ្ជាក់ថាមានសំឡេងកងទ័ពវាយចូលពីទិសខាងកើត ៗពីស្រុកស្នួលមកចូលមក។

ខ្ញុំបាទត្រេកអរនឹកថា អូ! តែប៉ុណ្ណោះ អ្នកឯង អាស៊ីរួម ហូបរួមហ្នឹង រលំរលាយហើយ។ ពួកអាយោធាអីហ្នឹង កែនកៀរប្រជាជនទៅហើយ។ ខ្ញុំបាទមានតែផ្លូវមួយទៅរស់នៅជាមួយកងទ័ព។ បាទព្រោះអស់ៗក្ដីសង្ឃឹមហើយ។ នៅជាមួយកងទ័ព ប្រាប់ពួកគាត់ហ្នឹង និយាយជាភាសាបារាំងថា ខ្ញុំជាពលរដ្ឋខ្មែរ ប៉ុន្តែទទួលរងគ្រោះខ្លាំងណាស់ ដូច្នេះខ្ញុំនៅតែម្នាក់ឯង សូមរស់នៅជាមួយកងទ័ព។ កងទ័ពមានអី ហូបក៏ខ្ញុំសុំតែបាយហូបដែរ។ បាទ រហូតរៀងៗដរាបមក ឆ្នាំ៨៩ ដែលវៀតណាមលាទៅវិញតែប៉ុណ្ណោះ បាទ។

**លោក វ៉ែន ពៅ៖**

សូមៗអរគុណ ពូ។ ឯកឧត្ដមប្រធាន លោកប្រធាន ខ្ញុំអស់សំណួរហើយ បាទ សូមអរគុណ។

[១៥:៤៨:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីអាចតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណ លោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ ដេវីដ ប៊ិយ។ ខ្ញុំមានសំណួរខ្លះៗ ក្នុងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា។ តើលោកអាចជម្រាបជូនតុលាការម្តងទៀតបានទេថា លោករស់នៅភូមិ ឃុំស្រុកណាដែរ នៅពេលដែលប្រពន្ធកូនរបស់លោកត្រូវបានគេយកទៅសម្លាប់ចោលនោះ?

**លោក អ៊ុច ស៊ុនឡាយ៖**

**ឆ៖** បាទ សូមអរគុណ។ ក្នុងពេលប្រពន្ធកូនពួកខ្ញុំ គេកូនចៅខ្ញុំ វាយកទៅសម្លាប់នៅក្បាលកោះទ្រុង គឺជាដីកោះនៅកណ្តាលទឹក។ ពេលនោះ ខ្ញុំបាទនៅសហករណ៍ ក-២ ហៅថា វាលផ្សិត និងទួលមនោរម្យ ឃុំគគរ ស្រុកក្រចេះ ខេត្តក្រចេះ។

[១៥:៥0:00]

**ស៖** ហើយនៅក្នុងសម័យកម្ពុជាប្រជាធិតេយ្យ តើលោកធ្លាប់ដែលបានដឹងបានឮថា ខ្មែរក្រហមធ្វើការស្រាវជ្រាវរែកមុខ ដើម្បីរកថា អ្នកណាមានដើមកំណើតឈាមជ័រមកពីវៀតណាមនោះទេ?

**ឆ៖** បាទសូមអរគុណ។ កាលដែលៗពួកកងឈ្លប តាមដានដឹងថាជាវៀតណាមហើយនោះវាល្បីសាយសុះអស់ទៅហើយ ពីព្រោះខ្ញុំកើតនៅទីហ្នឹងកន្លែងហ្នឹង ហើយកូនប្រពន្ធខ្ញុំបាទដែលបានរៀបចំមង្គលការតាំងពីមុនឆ្នាំ៧០ ហ្នឹងគឺគេដឹងប្រវត្តិរូបទាំងអស់ ថាអ្នកនេះកូនអ្នកនេះៗ រហូតដល់ថា ក្បាលយួនខ្លួនកម្ពុជាជាដើម...។ល។ ក៏ប៉ុន្តែ ឪពុកក្មេកខ្ញុំគាត់ យើងធ្វើបុណ្យជាមួយមនុស្សខ្មែរទាំងអស់ យើងធ្វើបុណ្យធ្វើទាន ហើយអត់មានអ្នកណាចេះនិយាយភាសាវៀតណាមទេ សូម្បីតែវៀតណាមឈ្មោះគ្នាខ្ញុំសួរនាង សា គឹមនី ជាប្រពន្ធខ្ញុំថា “អូនឯងដឹងគេឈ្មោះគ្នារឿងអីទេ?” វាថា “អត់ដឹងទេ ខ្ញុំអត់បានរៀនសូត្រភាសាវៀតណាមទេ” គ្រាន់តែវាជាប់សែស្រឡាយពូជ តាំងពីយាយបេ មកហ្នឹង តែប៉ុណ្ណឹងទេបាទ អត់មានគេមកតាមដានស្រាវជ្រាវស៊ើបអង្កេតទេ គឺដឹងនៅក្នុងភូមិឃុំនេះមួយៗហ្នឹងបាទ សូមអស់។

**ស៖** ក្រៅពីគេដឹងជាទូទៅថាប្រពន្ធរបស់លោកហ្នឹងមានសាវតារជាតិហ្នឹង ជាប់ខ្សែឈាមជាវៀតណាម ប៉ុន្តែតើលោកមានដែលបានដឹងថាខ្មែរក្រហមនេះ គេមានចាត់វិធានការណាដើម្បីស្រាវជ្រាវស៊ើបសួរ រកឲ្យឃើញថា អ្នកណាមានប្រភពដើមកំណើតជាវៀតណាមនោះដែរទេ?

**ឆ៖** បាទ សូមអរគុណ។ រឿងកាលដែលអង្គការចាត់មនុស្សស្រាវជ្រាវដឹងអីនោះ វាជារឿងរបស់អង្គការ យើងខ្ញុំអត់បានដឹងទេ។ គ្រាន់តែថានៅភូមិឃុំហ្នឹង កូនអ្នកណាធ្វើអី កូនអ្នកណាយ៉ាងម៉េច គឺគេតែងដឹង ពីព្រោះក្នុងភូមិឃុំមួយៗ គេដឹងថានេះ កូនអាចារ្យវត្ត, អ្នកនេះកូនកសិករ, អ្នកនេះកូនកម្មករ, អ្នកនេះយ៉ាងម៉េចយ៉ាងម៉ា គឺដឹងអស់ហើយ ពីព្រោះកន្លែងហ្នឹង ត្រង់ហ្នឹង ចាត់តាំងត្រង់ហ្នឹងយូរយាររាប់ឆ្នាំមកទៅហើយ អ្នកណាក៏ដឹងដែរ។ បាទ បានជាយើងខ្ញុំមិនមានរត់គេចវេះទៅខាងណាសោះឡើយ។ សូមអស់យោបល់។

[១៥:៥៣:១៣]

**ស៖** តើមានបុគ្គលណាម្នាក់ត្រូវបានគេចាប់ខ្លួននៅដំណាលពេលដែលគេចាប់ខ្លួនប្រពន្ធរបស់លោកនោះដែរទេ?

**ឆ៖** បាទ សូមអរគុណ។ មិនមែនមានតែប្រពន្ធកូនខ្ញុំប៉ុណ្ណោះទេ ដែលត្រូវបានដាក់ទិសទៅនៅកោះទ្រុង ដើម្បីគេយកសម្លាប់នោះគឺមានប្រពន្ធកូនអ្នកដទៃ បីបួនគ្រួទៀត មានជាអាទិ៍ប្រពន្ធកូនរបស់លោក យិន យឹម ឈ្មោះនាង អឹម ម៉ាឡែន និងកូនពីរនាក់ គឺអាបារាំង និងស្រីវិច បាទ។ ប្រពន្ធកូនរបស់ គុត ញ៉េវ, ប្រពន្ធកូនរបស់ ប៉ាន់ ហួនសេង, ប្រពន្ធកូនរបស់មនុស្សដទៃទៀត ដូចជា ពូសៀងជាដើម។ល។ ដែលជម្លៀសចេញ ហើយឱ្យប្ដីទៅកាប់ឫស្សីបង្កោងត្នោតសម្រាប់ធ្វើត្នោត ចេញពីមុខពីមាត់។ អាហ្នឹងគឺជាល្បិចកលដ៏ពិសពុលរបស់ពួក ប៉ុល ពតហ្នឹងឯង។ សូមអស់។

**ស៖** ហើយអ្នកដែលលោកទើបតែរៀបរាប់ឈ្មោះអម្បាញ់មិញនេះ តើពួកគាត់ទាំងនោះ មានប្រពន្ធជាជនជាតិវៀតណាមដែរឬ?

**ឆ៖** បាទ សូមអរគុណ។ ពិតប្រាកដហើយ ជាចៅកាត់វៀតណាម។

[១៥:៥៥:០០]

**ស៖** តើលោកអាចជម្រាបជូនតុលាការម្ដងទៀតបានទេថា នៅពេលណាដែលស្ត្រីៗ និង ក្មេងៗទាំងអស់នោះ ត្រូវបានគេចាប់ខ្លួន?

**ឆ៖** បាទ សូមអរគុណ។ មិនមែនចាប់មុនក្រោយទេ គឺបញ្ជូនទាំងគ្រួសារ ម្ដាយកូនៗ គ្រប់គ្រួសារនុំងទៅកោះទ្រុងហ្នឹង ហើយប្ដីៗឱ្យទៅកាប់ឫស្សីបង្កោងត្នោតឯនោះ នៅឆ្ងាយ។ ដូច្នេះ ការដែលទៅសម្លាប់នេះ មិនមែនសម្លាប់មុនក្រោយដោយប្រការណាមួយទេ គឺដាក់រទេះដឹកពីកណ្ដាលកោះហ្នឹងទៅអីក្បាលកោះឆ្ងាយនុំងតែម្ដង។ បាទ សូមអរគុណ។

**ស៖** តើលោកនៅនឹកឃើញដែរទេថា រឿងហ្នឹងកើតឡើងនៅក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទបានជម្រាបបញ្ជាក់ហើយ នៅក្នុងរដូវទឹកឡើងជោរជន់ទន្លេមេគង្គនោះ គឺក្នុងខែ៩។ បាទ យើងខ្ញុំមិនបានដឹងថ្ងៃខែទេ ពីខែ៩ ទឹកផ្តើមលិចជោរជន់ គេហៅថា ទឹកជំនន់ទន្លេមេគង្គលិចធំធេង ដូចមហាសាគរអ៊ីចឹងបាទ។ សូមអស់យោបល់។

[១៥:៥៦:៤៥]

**ស៖** នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក លោកថា នៅក្នុងខែកញ្ញា ឆ្នាំ៧៨។ តើអ៊ីចឹង ដូចដែលលោកបានសរសេរនៅក្នុងពាក្យសុំរបស់លោកហ្នឹង ឬក៏អត់ទេ?

**ឆ៖** បាទ សូមអរគុណ។ គឺពិតប្រាកដក្នុងខែកញ្ញា ហ្នឹងហើយ ដែលជារដូវទឹកជំនន់ឡើងទន្លេមេគង្គហ្នឹងខ្ពស់បំផុត ហើយតុលា អាចស្រុកទៅវិញ។ វិច្ឆិកា ហ្នឹងអាចនៅល្មមដែលគេធ្វើបុណ្យអុំទូកបាននោះ បាទ។ សូមអស់យោបល់។

**ស៖** ប៉ុន្តែឆ្នាំលោក តើលោកនៅតែអះអាងថា ព្រឹត្តិការណ៍ហ្នឹងវាកើតឡើងក្នុងឆ្នាំ១៩៧៨ដដែលឬក៏យ៉ាងណា?

**ឆ៖** បាទ ពិតប្រាកដហើយ គឺនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ហ្នឹងហើយដែលពួក ប៉ុល ពត នាំប្រពន្ធកូនខ្ញុំហ្នឹងទៅសម្លាប់ គឺរដូវទឹកជំនន់នុ៎ងបាទ។ សូមអស់យោបល់។

**ស៖** លោកបានឆ្លើយថា នៅពេលដែលលោកត្រឡប់មកពីកាប់ឫស្សីដើម្បីធ្វើបង្គោងត្នោត អ្នកភូមិនោះ បានប្រាប់លោកថា ប្រពន្ធរបស់លោក ក៏ដូចជាប្រពន្ធអ្នកដទៃទៀត និងកូនៗនោះ ត្រូវបានគេយកទៅសម្លាប់ចោល។ តើលោកនៅនឹកឃើញឈ្មោះអ្នកភូមិដែលប្រាប់លោកអំពីរឿងនេះទេ?

[១៥:៥៨:៤១]

**ឆ៖** បាទ សូមអរគុណ។ អ្នកភូមិមិនមែនតែម្នាក់ទេ ប៉ុន្តែអ្នកភូមិដែលនៅរស់បច្ចុប្បន្ននេះឈ្មោះលោក តាធុល។ លោកតាធុល បច្ចុប្បន្នគាត់ជាអាចារ្យវត្តនៅកោះទ្រុង ឃុំកោះទ្រុង សង្កាត់កោះទ្រុង ស្រុកក្រចេះ ខេត្តក្រចេះ។

**ស៖** លោកបានឆ្លើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ E3/4844, ERN ជាភាសាអង់គ្លេស 00982031, បារាំង 00920490 និងខ្មែរ 00527657។ សូមដកស្រង់៖ "ប្រភពព័ត៌មានលម្អិតពីប្រជាជនរស់នៅភូមិក្បាលកោះដែលបានឃើញការសម្លាប់នេះ ឈ្មោះ តាសែន ក្រោយមកគាត់ឈឺធ្ងន់ ហើយនិងបុរសម្នាក់ទៀតឈ្មោះ ធុល ដែលបានដឹកស្ត្រី និងក្មេងៗតាមរទេះគោយកទៅ

កន្លែងដែលគេសម្លាប់ចោល"។ តើលោកនៅចាំ ទេថា មានមនុស្សពីរនាក់ហ្នឹងមានឈ្មោះ តាសែន មួយ និងឈ្មោះ ធុល ម្នាក់ដែលជាអ្នកបរទេះគោ ដឹកអ្នកទាំងនេះយកទៅកន្លែងសម្លាប់ចោល?

**ឆ៖** បាទ សូមអរគុណ។ គឺពិតប្រាកដមែន ជាក់ស្តែងឈ្មោះ ធុល ហ្នឹងបាននិយាយរាយរ៉ាប់គ្រប់សព្វរហូតដល់ថាមកដល់បច្ចុប្បន្ន តាធុល ហ្នឹងគាត់ថាគួរធ្វើចេតិយមួយ ឬក៏ស្តូកអីមួយនៅទីនោះអីលោកគ្រូ? ខ្ញុំក៏ថា មិនអាចទាន់បានទេ ជាក់ស្តែងចាំមើលទៅមុខទៀត។ រីឯឈ្មោះម្នាក់ទៀតនោះ ខ្ញុំមិនចាំមកដល់ថ្ងៃនេះទេ ដោយសារគាត់ស្លាប់បាត់ហើយ។

**ស៖** ហើយអ្នកភូមិដែលប្រាប់លោកនេះ តើពួកគាត់បានឃើញការសម្លាប់នោះដោយផ្ទាល់ភ្នែក ឬគាត់គ្រាន់តែបានឮពីអ្នកដទៃអំពីការសម្លាប់នេះទេ?

[១៦:០១:២៦]

**ឆ៖** បាទ សូមអរគុណ។ អ្នកភូមិមិនបានឃើញឬមើលទិដ្ឋភាពនេះទេ ពីព្រោះកងឈ្លបគេឃាត់ឃាំង គេប្រាប់អស់ហើយថាអត់មាននរណាទៅតាមទេ ក្រៅតែពីប្តីប្រពន្ធពួកប្រពន្ធៗ និងកូនពួកអ្នកដែលទៅកាប់ឫស្សីព្រោះត្រូវយកអ្នកទាំងអស់នេះឲ្យទៅជួបប្តីៗគេវិញ នៅត្រើយម្ខាងទន្លេមេគង្គឯណោះ។ ដូចច្នេះមានតែឈ្មោះ ធុល ហ្នឹងមួយទេដែលនៅជិតដល់ ចាំ និងឃើញ និងដឹងឮផ្ទាល់ភ្នែក។ បាទ សូមអស់យោបល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។

បាទ អង្គជំនុំជម្រះអរគុណលោក អ៊ុច ស៊ុនឡាយ ដំណើរការសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម និងសក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យបន្តផ្តល់សក្ខីកម្ម និងថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មនៅព្រឹកថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ឆាយ ម៉ារីដែត បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយសម្រួលក្នុងកិច្ចការសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា ព្យសនកម្ម និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីពេញមួយថ្ងៃកន្លងមកនេះ។ ឥឡូវនេះលោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់

មកចូលរួមសវនាការវិញនៅថ្ងៃស្អែកដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០២ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ស្ថានភាពព្យសនកម្មនិងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បន្តបញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-933 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខអូរកន្សែង។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញនៅស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី)*